# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំណាំងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៧ លេខ ៤ ខែ មេសា

ព. ស. ២៥០៧ គ. ស. ១៩៦៥

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


ផ្នែកសាសនា — ទំព័រ

១– សាមគ្គីធម៌ សម្ដេចព្រះពោធិវ័ង្ស រៀបរៀង . . . . . . . ៣២៧

២– អំពីគិហិវត្ត ព្រះមុនីកោសល សួរ ហាយ រៀបរៀង . . . . . ៣៣៨

៣– ព្រះបច្ឆិមវាចារបស់ព្រះដ៏មានព្រះភាគ លោក ប៊ូ ប៉ូ រៀបរៀង . . . . ៣៤១

ផ្នែកអក្សរសាស្ត្រ

៤– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . ៣៤៥

៥– រឿងចៅរលោត លោក ឧ. គាម ស្រាវជ្រាវនិងរៀបរៀង (ត–ចប់) . . . ៣៥៧

៦– ក្រមួនលាបមាត់ លោក មាស ហាំ រៀបរៀង (ត–ចប់) . . . . ៣៦៧

៧– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ–កន ប្រែរៀបរៀង(ត) . . . ៣៨០

៨– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឧ. គាម ស្រាវជ្រាវ (ត) . . . . . ៣៨៦

៩– វិវឌ្ឍន៍នៃអក្សរខ្មែរ លោក ឧ. គាម រៀបរៀង (ត) . . . . . . ៤០០

ផ្នែកកំណត់ទិនប្រវត្តិការណ៍

១០– ពិធីបុណ្យបូជាព្រះសពព្រះ សុមង្គលសីហោចារ្យ ទិត ទឹម . . . . ៤០៨

១១– ការតាំងចៅអធិការ–គ្រូសូត្រក្នុងព្រះរាជអាណាចក្រ កម្ពុជា . . . . ៤១៦



មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០រ០០ ។

## ផ្នែកសាសនា

ពាក្យឃាតមិនឲ្យ ធ្វើការអាក្រក់
ជាការណាមក, ឲ្យធ្វើល្អទៅ,
ឲ្យជុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា ‑

ប.ព.

# សាមគ្គីធម៌

សម្ដេចព្រះពោធិវង្ស រៀបរៀង

(តមក)

## កិច្ចពិសេស

ក្នុងឱកាសដែលកំពុងប្រជុំ អ្នកដែលមកកាន់ទីប្រជុំនោះតើត្រូវធ្វើដូចម្ដេច? កិច្ចនេះមិនមានក្នុងពុទ្ធភាសិត ដែលបាននាំយកមកថ្លែងទុកជាបទមាតិកាខាងដើមនោះទេ ខ្ញុំសូមថ្លែងសេចក្ដីបន្ថែមតាមយោបល់ដែលយល់ឃើញ ដោយធ្លាប់បានសង្កេត បានគិតទុកជាយូរមកហើយ ឃើញថាអ្នកដែលចូលមកកាន់ទីប្រជុំគួរប្រតិបត្តិដូចតទៅនេះ :

១ - ការប្រជុំគ្នាស្ដាប់ធម្មទេសនា, ស្ដាប់សន្និសីទ ឬស្ដាប់បាឋកថានោះ អ្នកមកប្រជុំត្រូវធ្វើឲ្យមានការស្ងប់ស្ងៀម ហើយប្រុងចាំស្ដាប់ដោយយកចិត្តទុកដាក់ ។

២ - ការប្រជុំជំនុំពិនិត្យរឿងរ៉ាវផ្សេងៗ, ប្រជុំគិតបង្កើតការអ្វីមួយ,

ប្រជុំគ្នាបញ្ចេញយោបល់ពាល់គ្នា; ប្រជុំគ្នារិះរកគោលការណ៍ ដើម្បីនឹងដោះបញ្ហាផ្សេង ៗ ។ល។ ការប្រជុំមានប៉ុណ្ណេះជាដើម ពួកអ្នកដែលចូលមកប្រជុំ គួរប្រតិបត្តិដូច្នេះ :

ក) កុំនិយាយភាសាដទៃ ដែលអ្នកប្រជុំផងគ្នាស្ដាប់មិនបានទាំងអស់គ្នា ដើម្បីកុំឲ្យអ្នកស្ដាប់មិនបាននោះ មានសេចក្ដីរង្កៀសចិត្ត រៀរលែងតែក្នុងទីប្រជុំនោះ មានជនបរទេសដែលត្រូវប្រាស្រ័យជាមួយនោះ បើដូច្នេះក៏គង់តែឲ្យមានអ្នកបកប្រែឲ្យស្ដាប់បានទាំងអស់គ្នាដែរ ឬពុំនោះ អ្នកដែលចូលមកកាន់ទីប្រជុំអាចស្ដាប់ភាសាដទៃនោះបានទាំងអស់គ្នា ។

ខ) កុំនិយាយខ្សិបខ្សៀវតែ ២ នាក់ ៣ នាក់ក្នុងទីប្រជុំ ព្រោះជាហេតុនាំឲ្យអ្នកដទៃមានសេចក្ដីរង្កៀសចិត្ត ។

គ) ក្នុងឱកាសដែលអធិបតីទីប្រជុំ ផ្ដើមរឿងអ្វីឡើង; អ្នកប្រជុំត្រូវប្រុងស្ដាប់ ហើយជួយត្រិះរិះដោយគំនិតប្រាជ្ញា ឲ្យឃើញហេតុនិងផលនៃរឿងនោះ ហើយជួយគិតរកផ្លូវឲ្យដំណើររឿងនោះ ៗ បានប្រព្រឹត្តទៅដោយស្រួល ។

ឃ) ក្នុងពេលកំពុងជំនុំពិភាក្សារឿងអ្វីមួយ ៗ; អ្នកប្រជុំត្រូវបើកឱកាសឲ្យម្នាក់ ៗ និយាយតាមការយល់ឃើញរបស់ខ្លួន, មិនត្រូវដណ្ដើមគ្នានិយាយ ឬ និយាយព្រមគ្នាពីរបីនាក់ឡើយ ត្រូវតែចាំស្ដាប់គ្នាម្ដងម្នាក់ ប៉ុន្តែអ្នកដែលបានឱកាសនិយាយនោះសោត ក៏មិនត្រូវនិយាយច្រើនពេក

តែម្នាក់ឯងដែរ ត្រូវទុកពេលឲ្យអ្នកឯទៀតនិយាយផង វៀរលែងតែអ្នកប្រជុំគេសុំឲ្យនិយាយតទៅទៀត ។

ង) ក្នុងពេលកំពុងប្រជុំពិភាក្សាគ្នានោះ អ្នកប្រជុំត្រូវបោះបង់នូវទោសចិត្តចេញ ហើយត្រូវតាំងចិត្តឲ្យបរិសុទ្ធចំពោះកិច្ចការទាំងឡាយ ។

សេចក្ដីប្រតិបត្តិទាំង ៥ ខាងលើនេះ នឹងនាំឲ្យការប្រជុំមិនខាតពេលវេលាផង មិនឲ្យរង្កៀសជិតចិត្តរវាងគ្នានឹងគ្នាផង ឲ្យបានសម្រេចកិច្ចការដែលត្រូវពិគ្រោះប្រឹក្សាគ្នានោះផង ។

ត្រង់បទថា ព្រមព្រៀងគ្នាធ្វើកិច្ចការរបស់សង្ឃនោះ បានសេចក្ដីថា កិច្ចការរបស់សង្ឃត្រូវតែសង្ឃធ្វើដោយព្រមព្រៀងគ្នា ។ ពាក្យថាសង្ឃក្នុងទីនេះ ចំពោះយកគណៈសង្ឃជាបព្វជិត ជាអ្នកបួសក្នុងព្រះពុទ្ធសាសនា គឺបព្វជិតតាំងពី ៤ រូបឡើងទៅហៅថាសង្ឃ ។ កិច្ចការរបស់សង្ឃមានច្រើនយ៉ាង មានឧបោសថកម្មនិងបវារណាកម្មជាដើម សុទ្ធតែជាកិច្ចដែលភិក្ខុសង្ឃត្រូវធ្វើដោយព្រមព្រៀងគ្នា ។ ក្នុងវិន័យបិដកមានពុទ្ធប្បញ្ញត្តិថា ភិក្ខុរូបណាមិនអើពើនឹងកិច្ចការរបស់សង្ឃ ភិក្ខុរូបនោះត្រូវទុក្កដាបត្តិ ។

ខ្ញុំករុណា អាត្មាយល់ឃើញថា ព្រះពុទ្ធភាសិតក្នុងទីនេះពិតជាចំពោះលើគណៈសង្ឃខាងព្រះពុទ្ធសាសនាក៏មែនហើយ ប៉ុន្តែតាមពុទ្ធភាសិតនេះ បើពុទ្ធបរិស័ទជាគ្រហស្ថយកមកប្រតិបត្តិតាមផង ក៏ជាកិច្ច

ប្រសើរណាស់ ព្រោះពាក្យថា «សង្ឃ» មួយម៉ាត់នេះ បានអធិប្បាយខាងដើមរួចម្ដងហើយតើ, ពាក្យថាសង្ឃៈនេះប្រែថាពួកឬក្រុម មនុស្សដែលមានគ្នាច្រើន តាំងពី៤ នាក់ឡើងទៅហៅថាពួកឬក្រុម បើភាសាបាលីថា សង្ឃៈ, កិច្ចការដែលមនុស្សមានគ្នាច្រើនត្រូវធ្វើហៅថាសង្ឃ-ករណីយកិច្ចក៏បាន ដូចជាកិច្ចដែលភិក្ខុសង្ឃត្រូវធ្វើនោះដែរ ។ ដូចជាសមាគមនីមួយ ៗ ដែលមានសមាជិក សមាជិកាប្រមូលគ្នាបង្កើតឡើងហើយបានជ្រើសរើសពួកសមាជិកសមាជិកា ឲ្យតាំងឲ្យជាក្រុមអភិបាលរបស់សមាគម ក្រុមអភិបាលនោះមានគ្នាចំនួន ១២ នាក់ ឬ ១៥ នាក់ជាអ្នកមានភារៈខាងចាត់ចែងកិច្ចការរបស់សមាគម ឲ្យមានដំណើរប្រព្រឹត្តទៅកាន់សេចក្ដីចំរើន ។ ប្រសិនបើក្រុមអភិបាលនោះធ្វើការដោយមិនព្រមព្រៀងគ្នា សមាគមនោះក៏នឹងមិនមានដំណើរប្រព្រឹត្តទៅស្រួលបានឡើយលុះតែក្រុមអភិបាលបានព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាធ្វើការ ទើបកិច្ចការរបស់សមាគមនោះ ៗ នឹងអាចប្រព្រឹត្តទៅកាន់សេចក្ដីចំរើនបាន ។

សេចក្ដីដែលសំដែងមកតាំងពីប៉ុន្មានខាងដើមនេះ គឺសំដែងអំពីសាមគ្គីភាពព្រមព្រៀងគ្នា របស់ពួកក្រុមនីមួយ ៗ ទាំងខាងផ្នែកបព្វជិត ទាំងខាងផ្នែកគ្រហស្ថជាពុទ្ធបរិស័ទ ។ ចំណែកខាងកិច្ចការដែលត្រូវធ្វើដោយព្រមព្រៀងគ្នានោះ ចំពោះតែកិច្ចការដែលត្រូវល្អប្រពៃ ជាការបុណ្យកុសល ឬ ជាកិច្ចការដែលមានប្រយោជន៍ដល់ព្រះពុទ្ធសាសនា, ដល់

ប្រទេសជាតិឬដល់ខ្លួន ។ កិច្ចការទាំងនោះនឹងសម្រេចបានដោយស្រួល ហើយនឹងបញ្ចេញផលផ្តល់សេចក្តីសុខ-ចំរើនដល់អ្នកធ្វើ ។ ចុះប្រសិនបើកិច្ចការដែលធ្វើដោយព្រមព្រៀងគ្នានោះ ជាអំពើបាបអកុសល ជាអំពើនាំឲ្យខូចដល់ព្រះពុទ្ធសាសនា, ដល់ប្រទេសជាតិ ដល់ពួកក្រុម ឬដល់ខ្លួន តែកិច្ចការនោះសម្រេចឬមិនសម្រេច ក៏គង់នឹងសម្រេចបានខ្លះដោយការព្រមព្រៀងគ្នា ប៉ុន្តែកិច្ចការទាំងនោះបើសម្រេចបានប៉ុន្មាន សុទ្ធតែនាំឲ្យបានទុក្ខព្រួយដល់ខ្លួន, ដល់ពួកក្រុមរបស់ខ្លួនមិនខាន ព្រោះអំពើអាក្រក់ អំពើខុសទាំងនោះ ច្បាប់ខាងព្រះពុទ្ធសាសនានិងច្បាប់សម្រាប់ប្រទេស តែងហាមប្រាមមិនឲ្យធ្វើដោយដាច់ខាត មិនដែលអនុញ្ញាតបើកឲ្យធ្វើឡើយ ។

សេចក្តីថ្លែងអំពីសាមគ្គី ដោយនាំយកពុទ្ធភាសិតមកតាំងជាគោលព្រមទាំងសេចក្តីអធិប្បាយ តាមយោបល់ដែលយល់ឃើញខ្លះជាសេចក្តីសង្ខេប សូមសន្មតថាចប់ត្រឹមប៉ុណ្ណេះ ។

លំដាប់តទៅនេះ នឹងថ្លែងអំពីសាមគ្គីភេទ គឺការបែកនៃសាមគ្គីដូចមានសេចក្តីតទៅនេះ :

## សាមគ្គីភេទ

ការបែកធ្លាយនៃសាមគ្គីធម៌ របស់ពួកជនក្នុងសង្គមមួយ ៗ រវាងគ្នានឹងគ្នា ហៅថា "សាមគ្គីភេទ" ។

មនុស្សអ្នកបំបែកសាមគ្គី ឬទំលុះទំលាយនូវសាមគ្គីរបស់ពួកជនក្នុងសង្គមមួយ ៗ ឲ្យបែកបាក់គ្នា ហៅថា «សាមគ្គីភេទក» ៗ

ឥឡូវនេះ នឹងពោលអំពីពាក្យថា «សង្គម» ជាមុនរួចនឹងពោលអំពីការបែកសាមគ្គី និងផលអាក្រក់ដែលកើតអំពីការបែកសាមគ្គីតទៅទៀត ។

ជនទាំងឡាយគ្រប់ប្រភេទ នៅក្នុងប្រទេសកម្ពុជាយើងនេះ ដែលរួបរួមគ្នាជាពួកជាក្រុម ហៅថា «សង្គម» ៗ នោះមានច្រើនប្រភេទទៅទៀត ជាសង្គមតូច សង្គមកណ្ដាល និងសង្គមធំ តាមចំនួនមនុស្សតិចច្រើន ក្នុងសង្គមមួយ ៗ ។ គ្រួសារមួយ ៗ ដែលមានស្វាមី ភរិយា និងកូនប្រុសស្រីនៅរួមជាមួយគ្នា ហៅថា សង្គមតូច ។ សង្គមតូចៗនៅផ្ដុំគ្នាច្រើនក្នុងទីណា ទីនោះហៅថាភូមិ រាប់ជាសង្គម ១ ។ ភូមិច្រើនផ្ដុំគ្នាឡើង ហៅថា ឃុំ រាប់ជាសង្គម ១ ។ ឃុំច្រើនរួមជាមួយគ្នា ហៅថាស្រុក រាប់ជាសង្គម១ ។ ស្រុកច្រើនផ្ដុំឡើងរួមគ្នា ហៅថា ខេត្ត រាប់ជាសង្គម ១ ។ ខេត្តច្រើន រួមគ្នាហៅថារដ្ឋ ឬហៅប្រទេស រាប់ជាសង្គម១ ។

ម្យ៉ាងទៀត ពួកឬក្រុមជនដែលរួបរួមគ្នាជាសមាគមមួយ ៗ ក៏ហៅ-ថាសង្គមមួយៗដែរ ពុំនោះដូចជាសាលារៀនមួយ ៗ ដែលមានបុគ្គលិកសាស្ត្រាចារ្យ និងនិស្សិតតិចក្ដី ច្រើនក្ដី ក៏ហៅថាសង្គមមួយៗដែរ ។

ឯការបែកសាមគ្គី បានសេចក្ដីថា ការរួបរួមគ្នាជាសង្គមបាក់បែកអស់ហើយ គឺគ្មានការរួបរួមគ្នាទេ មានតែការមិនចុះចិត្តគ្នា ឈ្មោះ

ទាស់ទែងគ្នា រករឿងគ្នាទៅវិញទៅមកនិយាយដើមគ្នាពីរឿងអាក្រក់ទៅវិញទៅមក រករឿងប្រឆាំងគ្នាទៅវិញទៅមក ។ល។

មនុស្សដែលនៅក្នុងសង្គមមួយ ៗ សូម្បីក្នុងសង្គមដ៏តូចបំផុត ដូចជាក្នុងគ្រួសារមួយ ៗ កាលបើបែកសាមគ្គីរវាងគ្នានិងគ្នាហើយ គ្រួសារនោះត្រូវទទួលផលអាក្រក់ គឺឥតមានសេចក្ដីសុខសេចក្ដីចំរើនទេ មានតែទុក្ខព្រួយលំបាកចិត្តជានិច្ចនិរន្តរ៍ ដួនកាលឈ្លោះប្រកែកគ្នារហូតដល់ទៅបាក់បែកលែងលះគ្នាក៏មាន ដួនកាលកើតរឿងរ៉ាវធំរហូតដល់រលាយគ្រួសារនោះទៅក៏មាន ។

មនុស្សដែលអាស្រ័យនៅក្នុង ភូមិ ឃុំ ស្រុក ខេត្ត និងក្នុងប្រទេសដែលចាត់ជាសង្គមមួយ ៗ តាមចំនួនមនុស្សតិចច្រើននោះ កាលបើបែកសាមគ្គីរវាងគ្នានិងគ្នាហើយ គឺជាបែកបាក់គ្នាហើយ មិនអាចរួបរួមគ្នាដោយ កាយ វាចា និងចិត្តហើយមិនទុកចិត្តគ្នា ចេះតែរករឿងរកហេតុទៅវិញទៅមកសង្គមនោះ ៗ ឥតមានសេចក្ដីសុខចំរើនទេ មានតែការវិនាសហិនហោចបន្តិចម្ដង ៗ រហូតដល់រលាយរលត់ទៅក៏មាន ។

ក្នុងការបែកសាមគ្គី ដែលរមែងឲ្យផលអាក្រក់ គឺសេចក្ដីវិនាសហិនហោចនោះ គួរនាំយករឿងមួយដែលមានក្នុងគម្ពីរព្រះពុទ្ធសាសនាមកថ្លែងបញ្ជាក់ដោយសង្ខេប ទុកជាឧទាហរណ៍សម្រាប់ពិចារណាដូចមានតទៅនេះ :

មានរដ្ឋ ១ ឈ្មោះវជ្ជី មានពួកក្សត្រលិច្ឆវី ជាអ្នកគ្រប់គ្រងក្សត្រទាំងនោះព្រមទាំងមន្ត្រី បណ្ដារាស្ត្រ និងយុវជនដែលសិក្សាក្នុងសាលារៀន មានសាមគ្គីព្រមព្រៀងគ្នាល្អណាស់ ៗ ក្នុងដែនវជ្ជីនោះ មានការប្រជុំគ្នាញឹកញយណាស់ ពិនិត្យមើលកិច្ចការដែនដីទាំងមូល ព្រមទាំងមានការគោរពគ្នាទៅវិញទៅមក ចេះរក្សាប្រពៃណីធម៌យ៉ាងប្រសើរ ម៉្លោះហើយដែនវជ្ជីនោះមានកិត្តិយសកេរ្តិ៍ឈ្មោះ ផ្សាយចេញឮសាយសុសដល់ប្រទេសនានាថាដែនវជ្ជីជាប្រទេសមានសាមគ្គីមាំមួនណាស់ ឥតមានសត្រូវណាទំនងចូលទៅលុកលុយបាន ៗ ព្រះបាទអជាតសត្តុរាជ សោយរាជ្យនៅក្នុងដែនមគធៈ ជាប្រទេសធំស្តុកស្តម្ភ មានព្រះរាជបំណងនឹងលើកទ័ពទៅវាយដែនវជ្ជីនោះឲ្យខ្ទេចខ្ទី ដោយមានកំហឹងចំពោះពួកស្តេចលិច្ឆវី ក្នុងរឿងសេដ្ឋកិច្ចជាយូរហើយ ប៉ុន្តែពុំអាចនឹងលើកទ័ពចូលទៅបាន ព្រោះបានឮដំណឹងថា ក្នុងដែនវជ្ជីនោះ ពួកក្សត្រលិច្ឆវី មន្ត្រីនិងបណ្ដារាស្ត្រ មានសាមគ្គីព្រមព្រៀងគ្នា ចងបាច់គ្នាមាំមួនណាស់ ៗ ទើបព្រះបាទអជាតសត្តុរាជ ទ្រង់រិះរកមធ្យោបាយផ្សេង ៗ ដើម្បីនឹងលើកទ័ពទៅវាយដែនវជ្ជីនោះ ឲ្យបានដោយងាយ ៗ តមកទ្រង់បានសម្រេចព្រះរាជហឫទ័យថា ត្រូវធ្វើនយោបាយសម្ងាត់ ដើម្បីបំបាក់បំបែកសាមគ្គីរបស់ពួកស្តេចលិច្ឆវីឲ្យបានមុនសិន សឹមលើកទ័ពទៅវាយជាខាងក្រោយ ៗ លុះសំរេចព្រះរាជហឫទ័យដូច្នេះហើយ ទ្រង់បានចាត់ប្រើវស្សការព្រាហ្មណ៍

ជាវិទ្ធយាមាត្យ ជាអ្នកនយោបាយសំខាន់ម្នាក់ឲ្យទៅបំបាក់បំបែកក្នុងដែនវជ្ជី ប៉ុន្តែប្រើឧបាយកលធ្វើជាចាប់ទោសវស្សការព្រាហ្មណ៍នោះដោយដេញចេញអំពីដែនមគធៈ ដើម្បីឲ្យពួកក្សត្រក្នុងដែនវជ្ជី ទទួលវស្ស-ការព្រាហ្មណ៍នោះឲ្យនៅក្នុងដែនវជ្ជីដោយឥតរង្កៀស ។ កាលបើវស្ស-ការព្រាហ្មណ៍ទៅដល់ដែនវជ្ជី ពួកក្សត្រលិច្ឆវី ក្រោយដែលបានដឹងថាព្រាហ្មណ៍នោះត្រូវព្រះបាទអជាតសត្តុរាជបណ្តេញចេញក៏ទទួលវស្សការ-ព្រាហ្មណ៍នោះឲ្យនៅដោយសុខស្រួល ព្រមទាំងឲ្យឋិតនៅក្នុងតំណែងជាវិទ្ធយាមាត្យ ដូចជាកាលនៅក្នុងដែនមគធៈ ។ វស្សការព្រាហ្មណ៍មុនដំបូង បានធ្វើការថ្វាយចំពោះក្សត្រលិច្ឆវីដោយយកចិត្តទុកដាក់ហាក់ដូចជាមានការស្មោះត្រង់ណាស់ចំពោះដែនវជ្ជី នាំឲ្យពួកក្សត្រលិច្ឆវីពេញព្រះរាជហឫទ័យ ឥតមានរង្កៀសអ្វីសោះឡើយ ហើយបានទាំងប្រគល់ឋាន ជាអ្នកបង្ហាត់បង្រៀនវិជ្ជាផ្សេងៗ ដល់ពួកយុវលិច្ឆវីក្សត្រទាំងឡាយផងទៀត ។ វស្សការព្រាហ្មណ៍ បានដឹងថាពួកក្សត្រលិច្ឆវីឥតមានសេច-ក្តីរង្កៀសអ្វីទាំងខ្លួន ឃើញថាពួកក្សត្រទាំងនោះមានការធ្វេសប្រហែសហើយ ក៏ចាប់ផ្តើមធ្វើការវិទ្ធង្សនាបំបាក់បំបែក តាំងពីយុវជនដែលកំពុងសិក្សាដោយវិធីខ្សឹបខ្សៀវ និងយុវជន ១ នាក់ៗរាល់ថ្ងៃ បណ្តាលឲ្យពួកយុវជនកើតមានសង្ស័យអស់ជំនឿគ្នាបន្តិចម្តង ៗ យូរទៅៗ ពួកក្មេងៗក៏បែកគ្នាជាបក្សជាពួក យូរៗទៅទៀតក្សត្រមន្ត្រីក៏បែកបាក់គ្នា តទៅ

ទៀតពួកប្រជាពលរដ្ឋក៏បែកបាក់គ្នាទៀត កើតទៅជាបក្សពួកលែងជឿគ្នាទៅវិញទៅមក រហូតដល់ទៅក្នុងដែនរដ្ឋ បែកសាមគ្គីលែងរួបរួមគ្នាកើត ។

ព្រះបាទអជាតសត្តុរាជ កាលបើបានជ្រាបថា ក្នុងដែនរដ្ឋនោះមានការបែកបាក់សាមគ្គីអស់ហើយ ឥតមានការរួបរួមគ្នាដូចកាលមុនទេ ក៏លើកទ័ពទៅវាយដែនរដ្ឋនោះបានសម្រេចដូចបំណងភ្លាម ៗ ។

និទានកថាសង្ខេបខាងលើនេះ គួរជនទាំងឡាយគ្រប់សង្គមដែលប្រាថ្នាចង់បានសេចក្ដីសុខ-ចំរើន គប្បីរំពឹងពិចារណាយកទុកជាឧទាហរណ៍ ហើយប្រុងប្រយ័ត្នរក្សាសាមគ្គីឲ្យមាំមួន កុំឲ្យបែកបាក់គ្នាឲ្យសោះ បើទុកជាមានហេតុអ្វីកើតឡើងក្នុងសង្គម ជាហេតុគួរឲ្យមានទោមនស្ស គួរឲ្យឈឺចាប់ក្នុងចិត្ត ដែលបណ្ដាលកើតមកអំពីពួកជនក្នុងសង្គមជាមួយ ឬអំពីជនដទៃដែលជាសាមគ្គីភេទកៈ ត្រូវតែខំប្រឹងទប់ចិត្តអត់ធន់ចំពោះហេតុនោះៗឲ្យបាន ហើយត្រូវប្រើស្មារតីប្រយ័ត្ន គិតពិចារណាឲ្យទាន់ពេល កុំឲ្យសង្គមរបស់ខ្លួនប្រេះឆាបាក់បែក កុំឲ្យធ្លាក់ទៅក្នុងសាមគ្គីភេទ ទោះបីមានហេតុដ៏ធ្ងន់យ៉ាងណាក៏ដោយ ត្រូវតែខំប្រឹងទប់ទល់រក្សាសង្គមរបស់ខ្លួន ឲ្យមានសាមគ្គីជាដរាបតទៅ ព្រោះការបែកសាមគ្គីក្នុងសង្គមនីមួយៗ នាំឲ្យមានផលអាក្រក់ច្រើនយ៉ាងណាស់គឺ ;

– សុខកាយសប្បាយចិត្តរលាយអស់ ទុក្ខព្រួយលំបាកកើតឡើង ,

– សង្គមរបស់ខ្លួន ខ្សោយកម្លាំង មានសត្រូវប្រឆាំងកាន់តែច្រើន ,

– ពួកជនក្នុងសង្គម មានចិត្តក្តៅក្រហាយជានិច្ច ,

– កិត្តិយសនិងកេរ្តិ៍ឈ្មោះរបស់សង្គមត្រូវអាប់ឱន ,

– កិច្ចការរបស់ជនក្នុងសង្គម តែងជួបនឹងឧបសគ្គផ្សេងៗ

– ជួនកាលសង្គមរបស់ខ្លួនត្រូវរលាយរលត់ទៅក៏មាន ,

ផលអាក្រក់មានប៉ុណ្ណោះជាដើម កើតឡើងអំពីការបែកសាមគ្គី ។

(នៅមានត)

អ្នកប្រាជ្ញមានចិត្តល្អ សម្បូរទ្រព្យ ហើយ ឥតកម្លាំង ក៏អាចជួយកែខៃឲ្យសម្រេចប្រយោជន៍ បានដោយរួសរាន់

ស្រីហិតោបទេស

# អំពីគិហិវត្ត

(ត)

ព្រះមុនីកោសល ស៊ូរ-ហាយ រៀបរៀង

កូនប្រុសស្រី កាលបើបានពិចារណាឃើញច្បាស់ថា មាតាបិតាជាបុគ្គលមានគុណដ៏ធំទូលាយចំពោះយើងជាកូន ដូចសេចក្តីអធិប្បាយមកហើយនេះ ត្រូវកូនប្រុសស្រីតបឧបការគុណចំពោះមាតាបិតាវិញដោយការទំនុកបំរុងតាមហេតុ ៥ យ៉ាង ដូចបានរៀបរាប់ដោយសង្ខេបមកខាងដើមហើយ ក្នុងលំដាប់នេះសូមធ្វើអត្ថាធិប្បាយម្តងមួយៗ គ្រប់ហេតុទាំង ៥ យ៉ាង ដែលកូនប្រុសស្រីត្រូវបំពេញចំពោះមាតាបិតាដូចសេចក្តីអធិប្បាយតទៅ :

---

១– ករណី: ការចិញ្ចឹមមាតាបិតា ។

កូនប្រុសស្រីត្រូវគិតថា មាតាបិតាបានចិញ្ចឹមអាត្មាអញមកហើយ កូនប្រុសស្រីត្រូវចិញ្ចឹមមាតាបិតាវិញ ដោយយកចិត្តទុកដាក់ចំពោះជីវិតរបស់មាតាបិតាឲ្យរឿយៗ ។ កូនប្រុសស្រីមិនត្រូវសំដែងអាកប្បកិរិយាឆ្គាំឆ្គងចំពោះមាតាបិតាឡើយ ។ ឧបភោគគឺគ្រឿងប្រើប្រាស់ខាងក្រៅខ្លួន ដូចយ៉ាងផ្ទះគ្រែដេក ឬគ្រឿងបរិក្ខារ មានចានឆ្នាំងជាដើមនិងគ្រឿងបរិភោគលេបចូលទៅមានបាយជាដើម ត្រូវកូនប្រុសស្រីផ្គត់ផ្គង់ទំនុកបម្រុងឲ្យមានកុំឲ្យខ្វះខាតតាមសមត្ថភាពនៃខ្លួន ដើម្បីធ្វើឲ្យមាតាបិតាមានសេចក្តីសុខកាយសប្បាយចិត្តជានិច្ចដោយមាតាបិតាតែងគិតថា កូននឹង

បានស៊ុំទោះលស់កម្លាំង ។

២– កិច្ចករណា: ជួយធ្វើការមាតាបិតា ។

កិច្ចការណាមួយជារបស់មាតាបិតា ដែលលោកប្រគល់ឲ្យធ្វើក្តីមិនបានប្រគល់ឲ្យក្តី កាលបើកូនប្រុសស្រីបានដឹងហើយត្រូវទៅទទួលកិច្ចការរបស់មាតាបិតានោះ ធ្វើឲ្យបានសម្រេចតាមគោលបំណងរបស់លោក បើទុកជាកិច្ចការដែលមាតាបិតាមិនបានប្រគល់ឲ្យ ក៏ត្រូវតែទៅជួយធ្វើកិច្ចការនោះឲ្យបានសម្រេច មិនចាំបាច់ឲ្យមាតាបិតាប្រើដោយបង្ខិតបង្ខំឡើយ ។ សូម្បីកូនប្រុសស្រីដែលមានកិច្ចការកំពុងជាប់ធ្វើដោយខ្លួនឯង កាលបើកិច្ចធុរៈណាមួយរបស់មាតាបិតាដល់មកហើយ ក៏គួរឈប់ផ្អាកការងាររបស់ខ្លួនសិន ដើម្បីជួយបំពេញកិច្ចការរបស់មាតាបិតា បង្ហើយឲ្យស្រេចជាមុន សឹមត្រឡប់បែរមកបំពេញកិច្ចការរបស់ខ្លួនជាខាងក្រោយ ។ ការធ្វើកិច្ចណាមួយរបស់មាតាបិតាក្តី ការគោរពប្រណិប័តន៍មានសំពះជាដើមក្តី រាប់ថាជាកិច្ចតែប្រចាំខ្លួនរបស់កូនប្រុសស្រីដោយពិត ដែលកូនប្រុសស្រីត្រូវតែបទបការគុណនៃមាតាបិតាទិងខានពុំបាន ដើម្បីផលានិសង្សក្នុងលោកនេះផង ក្នុងបរលោកផង ទាំងខ្លួនយើងជាកូន ក៏បានឈ្មោះថា មានកតញ្ញូកតវេទិតាធម៌ចំពោះលោកអ្នកមានគុណដោយបរិបូណ៌ ។

៣– កុលវំសឋបន: តម្កល់វង្សត្រកូលមាតាបិតា ។

វង្សត្រកូលរបស់មាតាបិតា ដែលយើងជាកូនបានឃើញបានស្គាល់ផ្ទាល់ខ្លួនមកហើយ ដូចយ៉ាងញាតិសន្តានខាងមាតាក្តី ខាងបិតាក្តី កាលបើមានកិច្ចការណាមួយយើងត្រូវជួយដោះស្រាយកិច្ចការនោះៗ ដោយយកចិត្តទុកដាក់ តាំងអំពីមាតាបិតាមានជីវិតនៅឡើយក្នុងកាលខាងក្រោយដែលមាតាបិតាទទួលអនិច្ចកម្មទៅហើយក៏ដោយ យើងត្រូវទទួលភារៈក្នុងការគ្រប់គ្រងវង្សត្រកូលដោយខ្លួនឯង ។ ញាតិសន្តានទាំងខាងមាតាទាំងខាងបិតា យើងត្រូវទំនុកបម្រុងផ្ទុំផ្តើមសង្គ្រោះដោយឧបាយប្រាជ្ញាឬដោយទ្រព្យសម្បត្តិ ដើម្បីកុំឲ្យត្រកូលរបស់ខ្លួនថ្លស់ធ្លោយធ្លាក់ចុះទៅជាត្រកូលថោកទាប ។

៤– ទាយជ្ជប្បដិបជ្ជនៈ ប្រតិបត្តិនូវទ្រព្យមតិក ។

ពាក្យថា ការប្រតិបត្តិ បានដល់ការប្រព្រឹត្តធ្វើតាមដំបូន្មានដ៏ល្អរបស់មាតាបិតា សំដៅដល់ការយកចិត្តទុកដាក់តម្កល់ខ្លួន ឲ្យសមគួរដល់ឋានៈថាជាកូនមានសីលធម៌ល្អចំពោះមាតាបិតា គួរឲ្យមាតាបិតាមានសេចក្តីសង្ឃឹមកក់ក្តៅទុកចិត្តក្នុងការប្រគល់កេរ្តិ៍មតិក ។ កូនប្រុសស្រីគួរប្រតិបត្តិខ្លួនឲ្យល្អ កាលបើបានទទួលទ្រព្យសម្បត្តិជាកេរ្តិ៍មតិកអំពីមាតាបិតាមកហើយ ត្រូវចេះរៃលកសំចៃរក្សាទ្រព្យសម្បត្តិនោះឲ្យគង់នៅដោយល្អឬឲ្យរីកចម្រើនធំទូលាយទៅទៀត ដោយទ្រព្យជាដើមទុនរបស់មាតាបិតាមិនត្រូវធ្វើខ្លួន ឲ្យធ្លាក់ទៅជាមនុស្សប្រុស្តសីលឬឲ្យទៅជាមនុស្សធ្លាក់ចុះ

ក្នុងផ្លូវអបាយមុខឡើយ ។ កូនប្រុសស្រី ត្រូវជាអ្នកមានព្យាយាមដ៏ល្អ ដើម្បីទប់ទល់ខ្លួនឲ្យឋិតនៅបានយូរជាស្ថាពរ កុំឲ្យធ្លាក់ខ្លួនទៅក្នុងទលិទ្ទ-ភាព (ភាពនៃមនុស្សទលិទ្រ) ។ ព្រោះថាមនុស្ស ដែលមានមារយាទមិនល្អ, ជាអ្នកខ្ជិលច្រអូស, ល្ងង់ខ្លៅមិនអាចតម្កល់ខ្លួនឲ្យទៅជាអ្នកមានធនធានតាំងនៅបានយូរឡើយ ។ ត្រង់នេះមានពុទ្ធភាសិតថា ត្រកូលស្តុកស្តម្ភ តាំងនៅយូរមិនបាន ព្រោះស្ថាន ៤ យ៉ាងគឺ

១- នដ្ឋំ ន គវេសន្តិ មិនស្វែងរកទ្រព្យដែលវិនាស

២- ជិណ្ណំ ន បដិសង្ខរោន្តិ មិនជួសជុលវត្ថុចាស់គ្រាំគ្រា

៣- បរិភោគេ មត្តំ ន ជានន្តិ មិនស្គាល់ប្រមាណក្នុងការប្រើប្រាស់ចាយវាយទ្រព្យសម្បត្តិ ។

៤- ឥស្សរិយេ ទុស្សីលំ ឥត្ថឹ វា បុរិសំ វា ឋបេន្តិ តាំងស្ត្រីឬបុរសទ្រុស្តសីល ក្នុងភាពជាធំគឺជាមេផ្ទះ ។

ស្ថាន ៤ យ៉ាងដូចខាងលើនេះ កាលបើបុគ្គលណាមួយឥតប្រយ័ត្ន-ស្មារតី បណ្តោយខ្លួនឲ្យលុះលង់ទៅក្នុងស្ថានទាំង ៤ យ៉ាងនេះ បុគ្គលនោះមិនអាចនឹងឋិតនៅមាំមួន ថ្កុំថ្កើនបានយូរឡើយ ។

៥- ទក្ខិណា នុប្បទាន ឧទ្ទិសទក្ខិណាទានចំពោះមាតាបិតា ។

ការធ្វើបុណ្យឧទ្ទិសកុសលចំពោះមាតាបិតា ក្នុងកាលដែលលោកទទួលអនិច្ចកម្មនេះ ជាប្រពៃណីមួយរបស់យើងអ្នកកាន់ព្រះពុទ្ធសាសនា

ដែលតែងមានមកតាំងអំពីមុនសម័យពុទ្ធកាល ។ ការធ្វើទក្ខិណានុប្បទាននេះ ទុកជានិមិត្តរូបមួយរបស់កូនប្រុសស្រី ដែលជាអ្នកមានកិច្ចកតញ្ញូកតវេទីតាធម៌ ឬ ទក្ខិណានុប្បទាននេះជាភារៈរបស់កូនប្រុសស្រី ដើម្បីឧទ្ទិសបុណ្យកុសលបញ្ជូនចំពោះលោកអ្នកមានគុណគឺមាតាបិតា ព្រោះកិច្ចទក្ខិណានុប្បទាននេះ លោកសង្គ្រោះថាជាកិច្ចតបស្នងសងគុណចុងក្រោយបំផុតរបស់កូនប្រុសស្រី ។ ដូចបុគ្គលខ្លះ ជាអ្នកមានទ្រព្យទាំងជាអ្នកមានសទ្ធា បានកសាងចេតិយសម្រាប់បញ្ចុះធាតុនៃលោកអ្នកមានគុណ ដើម្បីឲ្យសមគួរដល់តម្លៃគុណនៃមាតាបិតា ឬ គ្រូអាចារ្យ ។ ចេតិយដែលគេកសាងឧទ្ទិសចំពោះលោកអ្នកមានគុណនេះ ក៏អាចរាប់បញ្ចូលថាជាទក្ខិណានុប្បទានដ៏ប្រសើរខ្ពង់ខ្ពស់របស់កូនប្រុសស្រី ឬរបស់សិស្សានុសិស្ស ។

ការទំនុកបំរុងមាតាបិតាដោយស្ថាន ៥ យ៉ាងដូចអធិប្បាយមកហើយនេះ ឈ្មោះថាជាកិច្ចវត្តរបស់កូនប្រុសស្រី ត្រូវធ្វើជាដរាប មិនត្រូវធ្វេសប្រហែសក្នុងការទំនុកបំរុងមាតាបិតានោះឡើយ ។

មួយទៀត អ្នកមានភោគសម្បត្តិត្រូវពិចារណាឲ្យរឿយៗ ចំពោះភោគសម្បត្តិដែលខ្លួនមានបានមកហើយ ដើម្បីឲ្យឃើញច្បាស់ថា ភោគសម្បត្តិទាំងអស់អាចបានមកជាគុណក៏មាន ជាទោសក៏មាន ។ បើអ្នកម្ចាស់ភោគសម្បត្តិមានគំនិតទូលាយវែងឆ្ងាយជាសម្មាទិដ្ឋិកជន ភោគសម្បត្តិរបស់អ្នកនោះក៏រមែងទៅជាគុណ បើភោគសម្បត្តិរបស់ជនពាល

រមែងធ្លាក់ទៅជាទោស ព្រោះហេតុនោះបុគ្គលអ្នកមានភោគសម្បត្តិគួរធ្វើភោគសម្បត្តិឲ្យទៅជាគុណប្រយោជន៍ គឺទំនុកបម្រុងខ្លួន, មាតាបិតាឲ្យជាសុខ, ទំនុកបម្រុងញាតិមិត្រព្រមទាំងសងទុកការពារអន្តរាយផ្សេងៗ និងការបរិច្ចាគទានក្នុងព្រះពុទ្ធសាសនា ។

មាតាបិតាកាលបើបានទទួលការទំនុកបម្រុងអំពីកូនហើយ ត្រូវអនុគ្រោះចំពោះកូនវិញ ដូចសេចក្ដីតទៅនេះ :

មាតាបិតាអនុគ្រោះកូនដោយហេតុ ៥ យ៉ាងគឺ :

១– បាបានិវារណា: ហាមកូនចាកអំពើអាក្រក់

២– កល្យាណនិវេសន: ញុំាងកូនឲ្យតាំងនៅក្នុងអំពើល្អ

៣– សិប្បសិក្ខាបន: ញុំាងកូនឲ្យរៀនសិល្បសាស្ត្រ

៤– បតិរូបទារសំយោជន: ផ្សំផ្គុំកូនឲ្យមានភរិយាស្វាមីសមគួរដល់ត្រកូល ។

៥– សមយេ ទាយជ្ជនិយ្យាទន: ប្រគល់ទ្រព្យមត៌កឲ្យកូនក្នុងសម័យដ៏គួរ ។

ហេតុ ៥ យ៉ាង ដូចរែកញែកមកដោយសង្ខេបនេះឈ្មោះថា ជាកិច្ចវត្តរបស់មាតាបិតា ដែលត្រូវផ្គត់ផ្គង់ទំនុកបម្រុងដល់កូនប្រុសស្រី ដូចសេចក្ដីអធិប្បាយពង្រីកតទៅនេះ :

១– បាបានិវារណា: ហាមកូនចាកអំពើអាក្រក់ ។

ពាក្យថា អំពើអាក្រក់ បានដល់អំពើដោយកាយវាចាចិត្តដែលជាអំពើគួរលះគួរវៀរចេញ មិនត្រូវកាន់មិនត្រូវប្រព្រឹត្ត ។ ពាក្យថាអាក្រក់នេះដូចយ៉ាងការសម្លាប់មនុស្សសត្វ, ការបោកប្រាស់លួចប្លន់, ការប្រព្រឹត្តខុសចំពោះកូនប្រពន្ធអ្នកដទៃ, ការនិយាយកុហក, និយាយញុះញង់, ការនិយាយពាក្យទ្រគោះ, និយាយពាក្យឥតប្រយោជន៍, ការប្រព្រឹត្តលោភលន់, ការព្យាបាទគុំគួន, ការយល់ខុស ។ អំពើទាំងនេះលោកហៅថាអំពើអាក្រក់ ។ មួយទៀតអំពើណាមួយ ដែលគេយល់ថា ជាអំពើអាក្រក់គួរតិះដៀល ដូចយ៉ាងអំពើក្នុងផ្លូវអបាយមុខ ៦ យ៉ាង មានការផឹកសុរាមេរ័យជាដើម ហៅថាអំពើអាក្រក់ដោយហេតុថា ជាអំពើនាំឱ្យវិនាសហិនហោចទ្រព្យសម្បត្តិថោកទាបទាំងខ្លួនឯងឃើញជាក់ច្បាស់ក្នុងបច្ចុប្បន្ន ។ មួយវិញទៀត កិច្ចការដែលទាស់គន្លងខុសផ្លូវសីលធម៌និងអនាម័យ ដូចយ៉ាងការធ្វេសប្រហែស បណ្តែតបណ្តោយក្នុងការរៀបចំទុកដាក់ខ្លួនប្រាណនិងទ្រព្យសម្បត្តិបណ្តោយខ្លួនឱ្យជាមនុស្សស្មោគគ្រោក ជាមនុស្សភាយពាយខ្ជះខ្ជាយទ្រព្យសម្បត្តិ ជាមនុស្សទ្រមក់ខ្ជិលច្រអូស ទាំងនេះហៅថាអំពើអាក្រក់ទាំងអស់ប៉ុណ្ណោះជាដើម ។

មាតាបិតាត្រូវមាននាទីជាអ្នកហាមប្រាមកូនមិនត្រូវបណ្តោយឱ្យកូនប្រព្រឹត្តអំពើអាក្រក់ ដូចរៀបរាប់ដោយសង្ខេបនេះ ។

២– ការប្រាណាធិវេសនៈ ញុំាងកូនឱ្យតាំងនៅក្នុងអំពើល្អ ។

ពាក្យថា ញុំាងកូនឱ្យតាំងនៅក្នុងអំពើល្អ បានដល់ការទូន្មានប្រៀនប្រដៅពន្យល់ណែនាំកូនរឿយ ៗ ឱ្យកូនស្រឡាញ់ពេញចិត្តចំពោះអំពើល្អ ។ ឯពាក្យថា អំពើល្អនេះ ផ្ទុយគ្នានឹងអំពើអាក្រក់ ដូចសេចក្តីអធិប្បាយខាងលើនោះស្រាប់ហើយ ។ មួយទៀត ដូចយ៉ាងមាតាបិតាចេះដឹកនាំកូនឱ្យបែរមុខទៅរកអំពើល្អ គឺឱ្យកូនប្រព្រឹត្តល្អដោយកាយវាចាចិត្ត ស្គាល់គុណទោសត្រូវខុសខ្ពស់ទាប ឱ្យកូនចេះធ្វើបដិសណ្ឋារៈចំពោះចាស់ទុំ សង្ឃ គ្រហស្ថ គោរពទីគ្រប់ជាន់ថ្នាក់ កុំឱ្យមានទង្គង់ក្នុងទីណាមួយ ឱ្យកូនស្គាល់ព្រះពុទ្ធសាសនា ស្គាល់ទានសីលភាវនា ទាំងនេះលោកហៅថា មាតាបិតាញុំាងកូនឱ្យតាំងនៅក្នុងអំពើល្អ ។

៣– សិប្បំ សិក្ខាបេន្តិ ញុំាងកូនឱ្យរៀនសិល្បសាស្ត្រ ។

ពាក្យថា សិល្បសាស្ត្រ សំដៅយកសៀវភៅឬគម្ពីរដែលជាច្បាប់សម្រាប់សិក្សាគ្រប់មុខវិជ្ជា ដើម្បីឱ្យចេះដឹងថ្នឹកស្ទាត់ជំនាញតាមសម័យនិយម មានវិជ្ជាខាងអក្សរសាស្ត្រ គណិតសាស្ត្រប្រវត្តិសាស្ត្រជាដើម ។ មាតាបិតាត្រូវខំស្វាហាប់ដាស់តឿនក្រើនរំលឹកកូនរឿយ ៗ មិនត្រូវធ្វេសប្រហែសឡើយ ព្រោះថាការសិក្សារៀនសូត្រនេះទុកជាជំហានទីមួយរបស់វឌ្ឍនធម៌ដោយហេតុថា ការបម្រើប្រយោជន៍ដើម្បីគ្រួសារខ្លួនឯងក្តី បម្រើប្រទេសជាតិ សាសនាក្តី ត្រូវអាស្រ័យបំណេះវិជ្ជាជាដកប ទើបប្រព្រឹត្តទៅដើម្បីសេចក្តីសុខចំរើនថ្កុំថ្កើងរុងរឿងបាន ។ ការចេះវែលកដោយ

• បាយដ៏ល្អរបស់មាតាបិតាក្នុងការដឹកនាំកូនប្រុសស្រី ឲ្យស្រឡាញ់ការសិក្សា សិល្បវិទ្យាសមគួរតាមកាលសម័យ ឈ្មោះថាជាករណីយកិច្ចមួយដ៏ប្រសើរបំផុតរបស់មាតាបិតា ។

៤– បដិរូបការសញ្ញា ៨ ឆ: ផ្សំផ្គុំកូនឲ្យមានភរិយាស្វាមីសមគួរដល់ត្រកូល ។

ពាក្យថា ផ្សំផ្គុំមិនមែនជាពាក្យលំបាកស្តាប់ទេ បានសេចក្តីថា រៀបចំមង្គលការកូនប្រុសស្រីឲ្យមានគូស្រករតាមប្រពៃណីនិយម ។ ការទុកដាក់កូនប្រុសស្រីឲ្យមានគូស្វាមីភរិយានេះ ជាភារៈលើមាតាបិតាទុកថាជាកិច្ចវត្តមួយរបស់មាតាបិតា ដែលត្រូវទាក់ទងនឹងកូនប្រុសស្រី ។ ករណីនេះទុកជាបញ្ហាមួយរបស់មាតាបិតា ដែលតែងមានការត្រិះរិះភ័យបារម្ភចំពោះជីវិតកូនប្រុសស្រី ព្រោះមាតាបិតាដែលមានគំនិតល្អក្នុងជីវិតអនាគតរបស់កូនប្រុសស្រី តែងមានសេចក្តីត្រិះរិះរឿយៗ អំពីគូវាសនានៃកូនរបស់ខ្លួនដោយគិតថា កូនរបស់អាត្មាអញកាលបើមានគូស្រករតាមប្រពៃណីយ៉ាងនេះហើយ តើអាចនឹងគ្រប់គ្រងគ្រួសារប្រកបដោយសេចក្តីសុខស្រួលប៉ុណ្ណា! ធម្មតាមាតាបិតាច្រើនតែមានគំនិតព្រួយបារម្ភចំពោះកូនប្រុសស្រី ព្រមទាំងចង់ដឹងព្រេងសំណាងរបស់កូនជារឿយ ៗ ព្រោះថាសេចក្តីព្រួយបារម្ភរបស់មាតាបិតា ដែលទាក់ទងនឹងកូនតែងមានជាប្រក្រតីដូចតទៅនេះ :

១) ព្រួយក្រែងកូនទៅជាអ្នកលេងកាប់សម្លាប់

២) ក្រែងកូនទៅជាអ្នកបោកប្រាសលួចប្លន់

៣ ក្រែងកូនទៅជាមនុស្សអ្នកលេងស្រី

៤) ក្រែងកូនទៅជាមនុស្សប្រមឹកស្រុក

៥) ក្រែងកូនទៅជាអ្នកលេងល្បែងភ្នាល់គឺល្បែងស៊ីសង

៦) ក្រែងកូនទៅជាមនុស្សសេពគប់ជនពាល

៧) ក្រែងកូនទៅជាមនុស្សប្រកបដោយទលិទ្ទភាពគឺ ទល់ក្រ ហោមហោមជំពាក់បំណុលគេ ។

កូនប្រុសស្រី ដែលមានគុណសារហើយអាចតម្កល់ខ្លួនបានដោយស្រួល ដែលអាចដោះស្រាយខ្លួន ឲ្យរួចអំពីសេចក្ដីព្រួយបារម្ភរបស់មាតាបិតានោះ ឈ្មោះថា ជាកូនប្រសើរតាមឋានៈនៃខ្លួនជាគ្រហស្ថ ដែលមានគុណសារ ឈ្មោះថាញ៉ាំងមាតាបិតាឲ្យមានសេចក្ដីសប្បាយរីករាយដ៏ក្រៃលែង ។ ព្រោះដំណើរដូច្នេះហើយបានជាមានពាក្យខាងចុងថា សមគួរដល់ត្រកូល សំដៅយកត្រកូលដែលធ្លាប់មានសីលធម៌ មានគំនិតល្អ មានភោគសម្បត្តិ។ ត្រង់មាតិកាធម៌នេះសមដូចបុរាណភាសិតថា «ធ្វើស្រែឲ្យមើលស្មៅ ដាក់ទុកកូនទៅមើលផៅសន្ដាន » ។ ទីដីដែលមានដីជាតិល្អ កាលបើស្មៅដុះលើដីនោះ ស្មៅក៏តែងលូតលាស់ល្អ កាលៈបើកសិករកដីល្អដើម្បីធ្វើស្រែត្រូវមើលស្មៅ បើឃើញថាដីនោះមានស្មៅលូតលាស់ល្អ អាចទាយ

បានជាទីដីនោះ  បើធ្វើស្រែព្រោះព្រួសស្រូវក៏មុខជាល្អដូចស្មៅនោះដែរ សេចក្តីនេះយ៉ាងណា  អ្នកដែលត្រូវការដាក់ទុកកូនទៅ  ឲ្យមានគូស្រករ ត្រូវមើលផៅសន្តាន គឺវង្សត្រកូលរបស់មនុស្សដែលធ្លាប់ល្អតាមត្រូវ កាលបើទុកដាក់កូនទៅចងពន្ធលើត្រកូលនោះ មុខជានឹងបានសេចក្តីសុខចម្រុងចម្រើនលូតលាស់ល្អយ៉ាងនោះដែរ ។ ពាក្យថារៀបចំមង្គលការកូន មានមកក្នុងគម្ពីរចែកមង្គលការនេះមាន ២ យ៉ាងគឺ  អាវាហមង្គល ដោយខាងប្រុសប្រាប់ដំណឹងទៅខាងស្រីថា  សូមឲ្យនាំកូនស្រីមករៀបចំមង្គលការឯផ្ទះខាងប្រុសឯណោះ១ វិវាហមង្គល ដោយខាងស្រីប្រាប់ដំណឹងទៅខាងប្រុសថា សូមឲ្យនាំកូនប្រុសមករៀបចំមង្គលការឯផ្ទះខាងស្រីឯណោះវិញ១ ។

បណ្តាមង្គលការ ២ យ៉ាងនេះ ត្រូវធ្វើមង្គលណាមួយក៏ឥតទាស់ខុសទេ ស្រេចនឹងសេចក្តីព្រមព្រៀងសុខចិត្តគ្នាទៅវិញទៅមក ប៉ុន្តែប្រពៃណីនិយមរបស់ប្រទេសខ្មែរយើង សុទ្ធតែប្រកាន់យកវិវាហមង្គល  ព្រោះប្រទេសយើងលើកតម្កើងខាងកូនស្រីជាងកូនប្រុស  បានជានាំកូនប្រុសទៅរៀបចំមង្គលការខាងស្រីជាដរាប  ដើម្បីគោរពចំពោះត្រកូលខាងស្រី ។

៤– សមយេ ទាយជ្ជនិយ្យាទនៈ  ប្រគល់ទ្រព្យមតិកឲ្យកូនក្នុងសម័យដ៏គួរ ។

ពាក្យថា ទ្រព្យមតិកសំដៅយកទ្រព្យរបស់មាតាបិតា  ដែលត្រូវចែកដល់កូនប្រុសស្រី ។  ការចែកទ្រព្យសម្បត្តិដល់កូននេះមាន  ២ យ៉ាងគឺ

ចែកឲ្យកូន ដើម្បីឲ្យចាយវាយរៀងរាល់ថ្ងៃខែតាមសមគួរដែលអាចចែកបាន ចំពោះកូនដែលនៅក្មេងមិនទាន់មានគូស្រករ ១ ចែកទ្រព្យសម្បត្តិជាសង្ហារិមនិងអសង្ហារិមដោយឲ្យដាច់ដល់កូនទុកជាកេរ្តិ៍ សម្រាប់ជាដើមទុនប្រកបអាជីវៈដោយខ្លួនឯងតទៅ ១ ។ ការចែកទ្រព្យសម្បត្តិដល់កូនប្រុសស្រីនេះ ជាបញ្ហាមួយដែលមាតាបិតាគួរពិចារណាឲ្យហ្មត់ចត់ ដើម្បីកុំឲ្យកូនប្រុសស្រីមានវិវាទទាស់ទែងកើតក្តីដណ្តើមកេរ្តិ៍មត៌កនឹងគ្នា ។ កេរ្តិ៍មត៌កដែលមាតាបិតាត្រូវចែកដល់កូននោះគួរចែកឲ្យជ្រះស្រឡះល្អ តាំងអំពីកាលដែលខ្លួនជាមាតាបិតាមានជីវិតនៅឡើយ មួយទៀតការចែកមត៌កនេះ ត្រូវចែកឲ្យតាមផ្លូវការ គឺឲ្យមានសេចក្តីបញ្ជាក់ជាសក្ខីភាពចំពោះរាជការជាមុខក្រសួងទទួលដីធ្លីជាភ័ស្តុតាងដោយលិខិតបញ្ជាក់ឲ្យត្រឹមត្រូវ ។

មនុស្សក្នុងលោកទោះបីមានជាតិមានភាសាជាច្រើន មានចំនួនរូបមនុស្សជាច្រើនលាននាក់ណាស់ក៏ពិតមែន ប៉ុន្តែបើប្រមូលរួបរួមមកជាគូមានត្រឹមតែ ៦ គូ ឥតមានលើសពីមនុស្ស ៦ គូនេះទៀតទេ ។

## មនុស្ស ៦ គូគឺ

១– មាតាបិតានិងបុត្រប្រុសស្រី

២– ភរិយានិងស្វាមី

៣– គ្រូអាចារ្យនិងសិស្សានុសិស្ស

៤– អ្នកកាន់ការនឹងប្រជាពលរដ្ឋ

៥– អ្នកម្ចាស់ការនឹងកម្មករ

៦– បព្វជិតនឹងកុលបុត្រជាគ្រហស្ថ ។

ព្រះសម្មាសម្ពុទ្ធមានព្រះប្រាជ្ញាញាណយល់ឃើញចំពោះមនុស្ស ៦ គូ ដែលត្រូវទាក់ទងប្រស្រ័យគ្នាជាការចាំបាច់ ទើបទ្រង់សំដែងធម៌ទុកជាច្បាប់ជាកិច្ចវត្ត ឬដែលហៅថា វិន័យសម្រាប់មនុស្សនោះ ឲ្យមានលាក់ខ័ណ្ឌព្រំដែនក្នុងការប្រព្រឹត្តប្រតិបត្តិចំពោះគ្នាទៅវិញទៅមក ដើម្បីឲ្យបានសេចក្ដីសុខ សេចក្ដីចម្រើនព្រមទាំងប្រយោជន៍គ្រប់យ៉ាង, មិនឲ្យមានការឈ្លោះទាស់ទែង មិនឲ្យមានការចងពៀរនឹងគ្នា ឲ្យមានតែសេចក្ដីសុខសាមគ្គីនឹងគ្នាទៅវិញទៅមកគ្រប់មនុស្សទាំង ៦ គូ ។

គិហិវត្តជាវិន័យរបស់គ្រហស្ថជាមាតាបិតានឹងបុត្រប្រុសស្រីជាដើម ដែលព្រះសម្ពុទ្ធជាម្ចាស់ទ្រង់សំដែងទុកមកនេះ ជាការប្រសើរបំផុត សម្រាប់ជាកិច្ចវត្តទូន្មានប្រៀនប្រដៅអប់រំមនុស្សគ្រប់គូទាំងអស់ មា គូគឺ មាតាបិតានឹងបុត្រប្រុសស្រីជាដើម ដែលមានមកក្នុងសិង្គាលសូត្រនៃគម្ពីរទីឃនិកាយបាដិកវគ្គដូចសេចក្ដីពណ៌នាមកនេះឯង ។

កិច្ចវត្តមាតាបិតា នឹង បុត្តធីតា ចប់តែប៉ុណ្ណេះ

# ព្រះបច្ឆិមវាចារបស់ព្រះដ៏មានព្រះភាគ

លោក ប៉ូ ប៊ូ រៀបរៀង

អថខោ ភគវា ភិក្ខូ អាមន្តេសិ ហន្ទទានិ
ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា
អប្បមាទេន សម្បាទេថាតិ ។ អយំ
តថាគតស្ស បច្ឆិមា វាចា ។

គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះឥឡូវនេះតថាគត នឹងប្រាប់អ្នកទាំងឡាយឲ្យបានដឹង សង្ខារទាំងឡាយមានសេចក្ដីសាបសូន្យទៅជាធម្មតា អ្នកទាំងឡាយចូរញុំាងកិច្ចទាំងពួងឲ្យសម្រេចដោយសេចក្ដីមិនប្រមាទចុះ ។ នេះជាបច្ឆិមវាចារបស់ព្រះតថាគត(១) ។

កាលព្រះដ៏មានព្រះភាគបរិនិព្វានហើយ សហម្បតិព្រហ្មក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា

សព្វេវ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ
យត្ថ ឯតាទិសោ សត្ថា លោកេ អប្បដិបុគ្គលោ
តថាគតោ ពលប្បត្តោ សម្ពុទ្ធោ បរិនិព្វុតោតិ ។

---

១) ស្រង់អំពីព្រះត្រៃបិដកបាលី-ប្រែ (ក្នុងគម្ពីរ សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ មហាបរិនិព្វានសូត្រ)

ព្រះសាស្តា ដែលឥតបុគ្គលប្រៀបស្មើ ប្រាជ្ញដ៏ជ្រះព្រះតថាគតជាសម្ពុទ្ធបរិបូណ៌ហើយដោយកម្លាំង ទ្រង់បរិនិព្វានហើយ ក្នុងលោកឯណា ពួកសត្វទាំងអស់មុខជានឹងដាក់ចុះនូវរាងកាយក្នុងលោក(នោះ) មិនបានឡើយ ។

ក្នុងពេលជាមួយគ្នានេះ ព្រះឥន្ទជាធំជាងទេវតាក៏ពោលនូវគាថានេះ ព្រមនឹងការបរិនិព្វានថា

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោតិ

សង្ខារទាំងឡាយមិនទៀងហ្ន៎ មានកិរិយាកើតឡើងហើយសូន្យទៅវិញជាធម្មតា លុះកើតឡើងហើយក៏រលត់ទៅវិញ កិរិយារម្ងាប់នូវសង្ខារទាំងនោះបានទើបនាំមកនូវសេចក្តីសុខ ។

ក្នុងពេលជាមួយគ្នានេះ ព្រះអនុរុទ្ធដ៏មានអាយុក៏ពោលនូវគាថាទាំងនេះ ព្រមនឹងការបរិនិព្វានថា

នាហុ អស្សាសបស្សាសោ ឋិតចិត្តស្ស តាទិនោ
អនេជោ សន្តិមារព្ភ យំ កាលមកាសិ មុនិ ។
អសល្លីនេន ចិត្តេន វេទនំ អជ្ឈវាសយិ
បជ្ជោតស្សេវ និព្វានំ វិមោក្ខោ ចេតសោ អហូតិ ។

ព្រះមុនិនាថអង្គឯណាដែលមិនមានតណ្ហា ទ្រង់ប្រារព្ធនូវអនុបាទិសេសនិព្វានហើយទ្រង់ធ្វើមរណកាល អស្សាសបស្សាសៈនៃព្រះមុនិនាថជាតាទិបុគ្គល ដែលមានព្រះទ័យខ្ជាប់ខ្ជួននោះមិនមានហើយ ។ ព្រះមុនិនាថទ្រង់អត់សង្កត់វេទនាបានដោយចិត្តមិនរួញរា សេចក្ដីរលត់នៃចិត្តក៏កើតមានបីដូចជាការរលត់នៃប្រទីប ។

ក្នុងពេលជាមួយគ្នានេះ ព្រះអានន្ទដ៏មានអាយុក៏ពោលនូវគាថានេះព្រមនឹងការបរិនិព្វានថា

តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
សព្វាការវរូបេតេ សម្ពុទ្ធេ បរិនិព្វុតេតិ ។

កាលដែលព្រះសម្ពុទ្ធប្រកបដោយហេតុដ៏ប្រសើរទាំងពួង ទ្រង់បរិនិព្វានហើយ សេចក្ដីខ្លាចនោះក្ដី សេចក្ដីព្រឺរោមនោះក្ដី ក៏កើតបានប្រាកដ ។

កាលព្រះដ៏មានព្រះភាគបរិនិព្វានហើយ ភិក្ខុទាំងឡាយឯណាដែលមិនទាន់ប្រាសចាករាគៈមាននៅក្នុងទីនុ៎ះ ភិក្ខុទាំងនោះ ពួកខ្លះក៏ផ្គងឡើងនូវកំភួនដៃហើយកន្ទក់កន្ទេញ ផ្ដួលខ្លួនបម្រះននៀលទៅមក បីដូចជាមានជើងដាច់ហើយថា ព្រះដ៏មានព្រះភាគទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសុគតទ្រង់ប្រញាប់បរិនិព្វានពេកណាស់ ព្រះសម្ពុទ្ធដ៏មានចក្ខុក្នុងលោកប្រញាប់បាត់ទៅពេកណាស់ ។ ឯពួកភិក្ខុណាដែលប្រាសចាករាគៈហើយភិក្ខុទាំងនោះមានសតិនិងសម្បជញ្ញៈអត់សង្កត់ដោយគិត

ថា សង្ខារទាំងឡាយមិនទៀងពិត ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្ដីទៀងទាត់ក្នុងខន្ធប្បវត្តិនេះអំពីណា ។

លំដាប់នោះ ព្រះអនុរុទ្ធដ៏មានអាយុប្រាប់ពួកភិក្ខុថា ម្នាលអាវុសោទាំងឡាយ ណ្ហើយ! អ្នកទាំងឡាយកុំសោយសោក កុំខ្សឹកខ្សួលឡើយ ម្នាលអាវុសោទាំងឡាយ សេចក្ដីនេះព្រះដ៏មានព្រះភាគទ្រង់បានសំដែងជាមុនហើយថា សេចក្ដីព្រាត់ប្រាសវិនាសប្រែប្រួលចាកសត្វនិងសង្ខារដែលជាទីស្រឡាញ់ជាទីគាប់ចិត្តទាំងអស់ តែងមានជាធម្មតា ម្នាលអាវុសោទាំងឡាយ ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្ដីមិនព្រាត់ប្រាសនោះក្នុងខន្ធប្បវត្តិនេះអំពីណា ធម្មជាតិឯណាដែលកើតហើយ ដែលមានហើយ ដែលបច្ច័យតាក់តែងហើយ មានសេចក្ដីទ្រុឌទ្រោមទៅជាធម្មតា ធម្មជាតិនោះឯងបុគ្គលនឹងពោលឃាត់ថា កុំទ្រុឌទ្រោមទៅដូច្នេះ (ដោយហេតុឯណា) ហេតុនោះមិនមានឡើយ ម្នាលអាវុសោទាំងឡាយ ទេវតាទាំងឡាយនឹងពោលទោស(១)មិនខាន ។

៚

---

១) អដ្ឋកថា ថា ពួកទេវតាពោលទោសថា លោកម្ចាស់ទាំងឡាយមិនអាចអត់សង្កត់សេចក្ដីសោកចំពោះខ្លួនឯងទៅហើយ ដូចម្ដេចនឹងឲ្យជនដ៏សេសដកដង្ហើមស្រួលបាន ។

**ដែនអក្សរសាស្ត្រ**

| | |
|---|---|
| អក្សរសាស្ត្រខ្មែរ | ខ្មែរគួរថែខ្លួន |
| ឲ្យបានស្ទាប់ខ្លួន | គង់វង្សគត់មត់ |
| ព្រោះអក្សរជាតិ | គោលជាតិប្រាកដ |
| អក្សររលត់ | ជាតិក៏រលាយ |

ប.ព.

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ម៉ាន ខាត់ រៀបរៀង*

**អនាទ** ពុ. កិរិយាមិនមានសំឡេង, ការមិនចេញសំឡេង ។ **អនាទិន** គុ. ដែលមិនចេញសំឡេង ។

**អនាទរ** បុ. ការមិនមានសេចក្ដីគោរព, ការមើលងាយ គុ. ដែលព្រងើយកន្តើយ, ដែលឥតគួរសម ។

**អនាទរណ** នបុ. ការមិនជួយរំលំ, ការមិនយកចិត្តទុកដាក់ ។

**អនាទ្រិត** គុ. ដែលមិនអើពើ, ដែលមិនគោរព ។

**អនាទិ** គុ. ដែលមិនមានដើម, ដែលមានជានិច្ចកាល ។

**អនាយត្ត** គុ. ដែលមិនមែនជាអាយត្ត, ដែលមានឥស្សរភាព ។ បុ. អ្នកបំរើ។ **–វ្ឫត្តិ** គុ. ដែលមិនប្រព្រឹត្តជាអាយត្ត ។ **–វ្ឫត្តិតា** ស្រី. ភាវៈនៃកិរិយាមិនប្រព្រឹត្តជាអាយត្ត, ឯករាជ្យ ។

អនាយម្យ គុ. ដែលមិនគប្បីលាតសន្ធឹង ។

អនាយសិត គុ. (ឆ្ល) ដែលមិនទាន់តាំងឡើង ។

អនាយាស គុ. ដែលមិនប្រឹងប្រែង, បុំ. ការមិនប្រឹងប្រែង ។ –ក្រុត គុ. ដែលធ្វើដោយមិនប្រឹងប្រែង, ដែលធ្វើដោយងាយៗ ។

អនាយុធ គុ. ដែលមិនមានអាវុធ, ដែលមិនមានអំណាច ។

អនាយុឞា ស្រី. នាមមាតានៃពលៈនិងវ្រឹត្រៈ ។

អនាយុឞ្យ គុ. ដែលមិនមានអាយុវែង, ដែលនៅតាមកាលកំណត់អាយុ ។

អនារត គុ. ដែលមិនដាច់គ្នា, ដែលតគ្នារដឹកទៅ ។ អនារតម៌ ក្រ.វិ. តៗគ្នា ។

អនារភ្យ គុ. ដែលមិនគប្បីប្រារព្ធ ។ អនារភ្យ, (អវ្យ. បរស្មៃបទ) មិនមានការប្រារព្ធ (Used in comp. in the sense « detached ») – វាទ បុំ. ការអង្កេតដោយឡែក (Upon sacrifices) ។ អនារភ្យាធីត គុ ដែលនិយាយ ឬ សិក្សា ពុំនោះ អានគួរៀងរាវផ្សេងៗ (Not as part of a regular or authoritative treatise)

អនារម្មណ គុ. ដែលមិនមានការតាំងការ ។

(នៅមានត)

# រឿងចៅរលាដូង

( រឿងព្រេងខ្មែរ )

(ត–ចប់)

លោក ឌ. គាម ស្រាវជ្រាវនិងរៀបរៀង

ពេលដែលចិញ្ចៀនធ្លាក់ទៅក្នុងសមុទ្រ ព្រះរៀមរបស់នាងពៅទាំងពីរព្រះអង្គ ធ្វើជាមាយាស្រែកថា ចិញ្ចៀនធ្លាក់ក្នុងទឹកហើយ ៗ នាងពៅទតទៅក្នុងទឹកសមុទ្រ ឃើញព្រះទម្រង់ច្បាស់លិចទៅសន្សឹមៗ ចាំងរស្មីពីក្នុងទឹក ទើបនាងលោតទៅក្នុងសមុទ្រ ដើម្បីចាប់យកព្រះទម្រង់មកវិញ ៗ ហេតុអ្វីបានជានាងពៅស៊ូប្តូរជីវិតនឹងព្រះទម្រង់! ពីព្រោះនាងពៅខ្លាចចៅរលាដូងបន្ទោសនាង ៗ ព្រះរៀមរបស់នាងពៅទាំងពីរព្រះអង្គ នាំគ្នាលាក់ការណ៍នេះឲ្យឈឹងជាមួយចៅរលាដូង ។

កេត្រាទៅដល់កណ្តាលសមុទ្រហើយ ទើបព្រះរៀមទាំងពីរព្រះអង្គ កុហកចៅរលាដូងថា «ប្អូនពៅយើងធ្វើឲ្យធ្លាក់ព្រះទម្រង់ទៅក្នុងសមុទ្រ ហើយថាភ័យខ្លាចប្អូនរលាដូងឯងស្តីបន្ទោស ទើបវាលោតទៅតាមចាប់ព្រះទម្រង់ ៗ ចៅរលាដូងនៅស្ងៀម ហើយដើរមករកកន្ទេលដែលនាងពៅអង្គុយ ឃើញតែសំពត់ហើយនឹងកន្សែងចង្កូរស្លាមួយប៉ុណ្ណោះ តែរកនាងពៅមិនឃើញ ៗ ចៅរលាដូងតាំងយំៗ លែងបរិភោគបាយទឹក ហើយលែងធ្វើការអ្វីថែមទៀត ក្រៅពីយំឡើយ ៗ ចៅរលាដូងបង្គាប់

ឲ្យនាយគេត្រាចូលទៅឆ្នេរសមុទ្រហើយវិលត្រឡប់ទៅផ្ទះវិញ ។ ព្រះរាជបុត្រីទាំងពីរព្រះអង្គ អង្គុយនៅក្បែរចៅវណ្ណាផូន មានសេចក្ដីស្រងូតស្រងាត់ស្ដាយ ខានទៅដែលធ្លាក់ទៅក្នុងសមុទ្រ តែសេចក្ដីស្នេហាចំពោះចៅវណ្ណាផូនធំជាងនោះទៅទៀត ។

កេត្រាត្រឡប់មកដល់នគរវិញ ចៅវណ្ណាផូនក៏យករឿងនោះទៅទូលព្រះរាជិនីថា ខានទៅធ្វើឲ្យធ្លាក់ព្រះខ្រមង់ទៅក្នុងសមុទ្រ រួចខាចទូលព្រះបង្គំជាខ្ញុំស្ដីបន្ទោសឲ្យ ទើបខានទៅលោតទឹកសមុទ្រទៅ ទូលព្រះបង្គំជាខ្ញុំមិនដឹងសោះរឿងនេះ តែព្រះរៀមទាំងពីរព្រះអង្គបានឃើញហើយប្រាប់រឿងនេះដល់ទូលបង្គំ ។

ព្រះរាជិនីនាំរឿងនេះទៅទូលព្រះរាជា ហើយព្រះរាជាក៏ហៅព្រះរាជបុត្រីទាំងពីរព្រះអង្គមកសួរ តាមពាក្យដែលចៅវណ្ណាផូនទូល ។ ពេលដែលចៅវណ្ណាផូនទៅថ្វាយបង្គំព្រះរាជា ហើយទូលសាសព្វពីរឿងនោះ ព្រះរាជានឹងរាជិនីបានទ្រង់ព្រះសណ្ដាប់ចៅវណ្ណាផូនហើយ ក៏ទ្រង់ព្រះកន្សែងនិកអាណិតចៅវណ្ណាផូនទីងការព្រាត់ប្រាសខានទៅ ។ ដោយសេចក្ដីនឹកអាណិតខានទៅ លាយដោយសេចក្ដីស្នេហាចំពោះចៅវណ្ណាផូនផង ព្រះរាជបុត្រីទាំងពីរព្រះអង្គថា ៉ខ្ញុំឲ្យអូនទៅដោះព្រះខ្រមង់ឲ្យមើល តែមិនដឹងជាដូចម្ដេច បានជាព្រះខ្រមង់នោះធ្លាក់ទៅក្នុងទឹកសមុទ្រ ហើយអូនទៅក៏លោតទៅតាមចាប់ព្រះខ្រមង់ទៅ ។ បើខ្ញុំដឹងថា

អូនពៅប្រុងលោតទៅក្នុងទឹក ម្ល៉េះកូនទាំងពីរចាប់ទៅហើយ នេះកុំឲ្យតែដឹងខ្លួនសោះ ស្រាប់តែមកលោតទឹកទៅ" រឿងនេះតែប៉ុណ្ណេះទេ ។

ព្រះពជាទិងពជិទ្រង់មានព្រះសាវនីយហើយ ក៏លួងលោមចៅរលា-ដូងកុំឲ្យខ្លួញសោកចំពោះនាងពៅពេក ព្រោះចៅឯងមិនមែនជាគូព្រេងជាមួយនាងពៅ ។ ព្រះពជាឃាត់ឲ្យចៅរលាដូងនៅជាមួយក្នុងកំឡុងពេលមួយឆ្នាំសិន សឹមរកប្រពន្ធឲ្យទៀត ។ ចៅរលាដូងឮព្រះពជាទ្រង់មានព្រះបន្ទូលដូច្នោះហើយ គាំងយំសោកសង្រេងសង្រែបោកខ្លួនដោយអាល័យនាងពៅពេក ហើយទូលទៅព្រះពជាថា កូនរកពេលសប្បាយគ្មានទេ រស់នៅដោយអត់បានជួបនាងពៅ វិស័យដូចជា លោកនេះគ្មានមនុស្ស កូនមិនទៅណាទេ នៅបំរើព្រះបិតាមាតាសិន" ។ ពេលណាចៅរលាដូងនឹកឃើញនាងពៅ ចៅរលាដូងនឹកឃើញដល់គ្រាកំសត់ កាលដែលនាងពៅលុកព្រៃតែម្នាក់ឯងយកបាយទៅឲ្យ មិនថាតែចៅរលាដូងម្នាក់ទេ ដែលយំសោកស្តាយនាងពៅ សូម្បីតែប្រជាកស្ត្រតូចធំក៏ស្តាយនាងពៅដែរ ។

និយាយពីព្រះពជបុត្រីទាំងពីរព្រះអង្គវិញ ដោយសេចក្តីស្នេហាពេញទ្រូងចំពោះចៅរលាដូង តែពេលយកអាហារភោជនទៅឲ្យចៅរលា-ដូងបរិភោគម្តងៗ ចេះតែពីញញឹមបិទមាត់មិនជិតទេ រួចដួនកាលពេលខ្លះចៅរលាដូងញញឹមតបមកវិញ សប្បាយចិត្តភ្លេចថាខ្លួនដើរលើដីផង ។ ពេលយប់វិញ ព្រះពជបុត្រីទាំងពីរព្រះអង្គដណ្តើមគ្នាយកម្លូស្លាទៅរៀបចំ

ឲ្យចៅរលាដូនដែលដេកនៅក្នុងបន្ទប់ម្នាក់ឯង ។ ព្រះរាជបុត្រីទាំងពីរបេះតែនាំចៅរលាដូននិយាយពីនេះពីនោះ ដើម្បីឲ្យចៅរលាដូនបំភ្លេចចោលនូវនាងពៅ តែពេលណាចៅរលាដូនឮឈ្មោះនាងពៅភ្លាម ចៅរលាដូនតាំងយំក្បែកខ្សួលភ្លាម ។

នេះនិយាយអំពីនាងពៅដែលលោតតាមចាប់រើសព្រះខម្រង់មកវិញ ។ នាងពៅហែលទៅចាប់បានព្រះខម្រង់យកមកពាក់នៅចង្កេះវិញ ស្រាប់តែទឹកហូរគួចយកទៅក្រោមទៀត តែដោយអំណាចព្រះខម្រង់ នាងពៅក៏ក្លាយខ្លួនទៅជាកូនក្មេងតូចល្មមតែនៅក្នុងសម្បកគ្រុំបាន ។ នាងពៅនៅតែក្នុងសម្បកគ្រុំអស់កាលប្រហែលជាមួយឆ្នាំ ទើបសម្បកគ្រុំផុះអណ្ដែតមកនៅឆ្នេរសមុទ្រ ។

នាងពៅចេញពីសម្បកគ្រុំហើយចូលវិញដូចបំណង តែនាងពៅមិនដឹងថា នាងនៅត្រង់កន្លែងណាឡើយ ម្ល៉ោះហើយនាងពៅគិតតែពីយំសោកស្ដាយចៅរលាដូន ។ នាងពៅមកនៅឆ្នេរសមុទ្រជាងមួយខែ ស្រាប់តែឃើញបុរសម្នាក់មកដើររើសសំបកគ្រុំទៅលក់ ។ នាងពៅឃើញគេមករើសសម្បកគ្រុំដូច្នោះ ក៏រត់ចូលទៅក្នុងសម្បកគ្រុំវិញ ហើយយំសសឹកដូចកូនក្មេង ។ បុរសនោះឮសំឡេងក្មេងយំ តែរកមើលមនុស្សមិនឃើញ ឃើញតែសម្បកគ្រុំចម្លែក បុរសនោះយកសម្បកគ្រុំមកដល់ផ្ទះហើយក៏យកសម្បកគ្រុំចំឡែកនោះ ទៅដាក់ចោលក្រោមដើមឈើមួយនៅខាង

ក្រោយផ្ទះ ៗ បុរសអ្នករើសសម្បកគ្រំនោះមានប្រពន្ធមួយ ចិញ្ចឹមជីវិតតែដោយសាររើសសម្បកគ្រំ ដាអ្នកក្រក្រកោយបានព្រឹកខ្វះល្ងាច ៗ

ថ្ងៃមួយ ប្រពន្ធចេញទៅលក់សម្បកគ្រំ ឯប្ដីទៅរកកាប់ឧស ៗ ពេលម្ចាស់ផ្ទះមិននៅ នាងពៅចេញពីក្នុងសម្បកគ្រំហើយ ក៏យកព្រះខម្រង់ទិព្វមកជប់ឲ្យបានម្ហូបទិព្វទុកឲ្យម្ចាស់ផ្ទះ ហើយចូលទៅក្នុងសម្បកគ្រំវិញ ៗ

ពេលដែលប្ដីប្រពន្ធចូលមកផ្ទះវិញ ឃើញអាហារភោជនស្ងោរម្ហូររៀបយ៉ាងល្អ ហើយមានសេចក្ដីសង្ស័យ ក្រែងលោមាននរណាដាក់ថ្នាំបំពុលតែដោយសេចក្ដីឃ្លានពេក ក៏នាំគ្នាបរិភោគទៅ ៗ ស្វាមីភរិយានាំគ្នាបរិភោគហើយ គ្មានឃើញហេតុគេខអ្វី ក៏ចេះតែនាំគ្នាបរិភោគម្ហូបអាហារនោះជារៀងរាល់ថ្ងៃ ៗ មានថ្ងៃមួយ គ្រួសារនេះចង់ដឹងថា តើនរណាជាអ្នកយកម្ហូបអាហារមក ទើបនាំគ្នាពួនលបចាំមើល ៗ ពេលស្ងាត់នាងពៅក៏ចេញពីសម្បកគ្រំ ហើយមករៀបចំអាហារភោជនទៀត ៗ បុរសក៏ស្ទាត់ឃើញនាងពៅចេញមកធ្វើអាហារភោជនល្អដូច្នោះ ក៏រត់ទៅចាប់ទុកកុំឲ្យចូលទៅក្នុងសម្បកគ្រំវិញ ៗ បុរសសួរថា «នាងឬដែលមកធ្វើម្ហូបនៅទីនេះអម្បាញ់មិញ !

នាងពៅនិយាយទាំងទឹកភ្នែកថា លោកមានគុណរើសខ្ញុំយកមកទុករក្សានៅទីនេះ ខ្ញុំគ្មានអ្វីតបស្នងសងគុណលោក ដូច្នេះហើយបានជាខ្ញុំចេញមករៀបចំអាហារភោជនទុកជូនលោក ៗ

ស្វាមីភរិយា ឃើញនាងពៅមានរូបសម្បត្តិល្អឥតអ្វីប្រៀបបានមាន ពាក់ព្រះខ្សែទម្រង់ទិព្វផង ។ ទឹកភ្នែកនាងពៅដែលហូរចេញមកក្លាយទៅជាដុំពេជ្រមាសដោយអំណាចនៃព្រះខ្សែទម្រង់ទិព្វ ។ ដោយមានហេតុអស្ចារ្យដូច្នោះ បុរសសួរនាងពៅតទៅទៀតថា „នាងបានអង្គុយពីណាមកដើម្បីរៀបចំបាយទឹកឲ្យខ្ញុំ" ។ នាងពៅមិនឆ្លើយសោះចេះតែនៅយំ ទើបបុរសសួរថា ម្តេចបានជានាងយំ មិនឈប់ឈរសោះ? នាងពៅឆ្លើយថា ខ្ញុំមានវិប្បដិសារៈ (សេចក្តីស្តាយក្រោយ) ច្រើនណាស់ ខ្ញុំមានវិប្បដិសារៈនឹកដល់ថ្ងៃដែលខ្ញុំនឹងមានសុខមង្គល ថ្ងៃដែលខ្ញុំនឹងបានសប្បាយ ។ បុរសប្រាប់នាងពៅថា បើដូច្នោះ ចាំខ្ញុំហៅស្រីៗឲ្យបានច្រើន ជជែកលេងជាមួយនាង ហៅស្រីៗមកបុកអង្ករឲ្យនាងមើល តើនាងចូលចិត្តឬទេ!

នាងពៅបានលំហែចិត្តមួយភ្លែតដែរ តែនាងពៅនៅតែមានសេចក្តីសោកសៅនឹកអាល័យពីមាតាបិតាស្វាមីដែលជាទីស្នេហា ។ ទីបំផុតនាងពៅរកមធ្យោបាយអ្វីដោះស្រាយសេចក្តីសោកនេះគ្មាន ទើបនាងសួរទៅបុរសនោះថា លោក! នៅនគរនេះមានស្តេចសោយរាជ្យឬទេ? បុរសប្រាប់នាងពៅថា នគរនេះមានស្តេចសោយរាជ្យប្រកបដោយទសពិធរាជធម៌ណាស់ ។ នាងសួរតទៅទៀតថា ស្តេចនេះមានកូនឬទេ? បុរសឆ្លើយថា ស្តេចនេះមានព្រះរាជបុត្រីពីរព្រះអង្គ ។ ព្រះនាងពៅរៀបការជាមួយចៅលាដួង ។ ថ្ងៃមួយចៅលាដួងចេញសំពៅទៅរកដួញ ស្រាប់តែ

មិនដឹងជាមានការឡកណ្ណ៍ដូចម្ដេច នាងពៅនោះធ្វើឲ្យជ្រុះចិញ្ចៀនទៅក្នុងសមុទ្រ ហើយនាងពៅក៏លោតទៅក្នុងសមុទ្រទៅរកចាប់ចិញ្ចៀនបាត់ដល់សព្វថ្ងៃនេះ ។ ឯព្រះរាជបុត្រីច្បងទាំងពីរព្រះអង្គនៅមានព្រះជន្មនៅឡើយ ។

នាងពៅសួរតបទៅវិញថា ចៅរលោជួងសព្វថ្ងៃនេះ គេនៅជាមួយលួង ឬមួយគេរៀបការប្រពន្ធថ្មីទៀតទៅហើយ? ។ បុរសក៏សត់ឆ្លើយថា នាង! ចៅរលោជួងគ្រាន់តែយំរកនាងពៅអស់មួយឆ្នាំ សព្វថ្ងៃនៅតែយំរកនាងពៅអ៊ិចឹង គ្មានគិតដេកស៊ីទេ ពូអាណិតចៅរលោជួងណាស់ ។ ពេលបុរសប្រាប់នាងពៅនោះ នាងពៅយំអណ្ដឹតអណ្ដក គួរឲ្យអាណិត ទើបបុរសសួរថា ម្ដេចបានជាពេលដែលខ្ញុំហៅឈ្មោះចៅរលោជួងនាងយំសសឹកដូច្នេះ? នាងពៅឆ្លើយថា លោកនិយាយពីប្ដីយំព្រោះអាណិតប្រពន្ធខ្ញុំទឹកទៅគួរឲ្យអាណិតគាត់ណាស់ ដូច្នេះហើយបានជាខ្ញុំយំអាណិតបុរសនោះ ។ ធ្វើម្ដេចទៅគ្មានរកប្រពន្ធឃើញ ។ ស្វាមីភរិយាទុគិតនៅតែមិនមានសេចក្ដីសង្ស័យទៅលើនាងដែលនៅជាមួយថាជានាងពៅ ទើបបុរសថា កូនឪពុក! នាងថាបុត្រីដែលទេវតាបានដាក់ទានឲ្យ ។

នាងពៅដឹងហេតុដូច្នោះហើយ ក៏បង្គាប់ឲ្យប្រពន្ធបុរសនោះ ទៅរកទិញសូត្រយកមកត្បាញសំពត់ហូលពិសេស ។ នាងពៅត្បាញសំពត់ហូលមួយគូ ហើយឲ្យប្រពន្ធបុរសនោះពាក់ចិញ្ចៀនជ្រុះទម្រង់ទៅ

លក់សំពត់ហូល ៗ តែនាងពៅផ្តាំថា ឲ្យយកសំពត់នេះទៅលក់ឲ្យ
តែស្តេចបានហើយ ៗ

ស្ត្រីនោះយកសំពត់ដើរទៅដល់វាំងហើយ ក៏ស្រែកតពាយនាយ លក់សំពត់នោះ ៗ ព្រះរាជនីនៅក្នុងព្រះរាជវាំងឮឈ្មោះសំពត់នោះហើយ ក៏ឲ្យអាមាត្យមកហៅស្ត្រីនោះទៅ ៗ ព្រះរាជនីទតឃើញសំពត់ហូល ហើយពិនិត្យឃើញមានក្បាច់លេចផ្កាក្រូចសំពត់ហូលមួយគូ ដែលនាងពៅត្បាញមុនរៀបការ ព្រះអង្គទតឃើញក្បាច់គ្មានប្លែកដូច្នោះ ក៏ទ្រង់ព្រះកន្សែងហើយហៅព្រះរាជបុត្រីទាំងពីរមកឲ្យជួយពិនិត្យមើល ៗ ព្រះរាជនី ទៅវលាដូង និងព្រះរាជបុត្រីទាំងពីរព្រះអង្គទ្រង់ព្រះកន្សែងនឹកស្រណោះនាងពៅ ទើបព្រះរាជនីមានព្រះបន្ទូលទាំងសសឹកថា នាង! នរណាជាអ្នកត្បាញសំពត់នេះ? ស្ត្រីនោះឆ្លើយថា កូនរបស់ទូលព្រះបង្គំជាអ្នកត្បាញ ៗ ព្រះរាជនីសួរថា កូនរបស់នាងបង្កើតឬ? ក្រាបទូលមិនមែនកូនរបស់ទូលខ្ញុំម្ចាស់បង្កើតទេ ខ្ញុំម្ចាស់រើសបាន ៗ ថ្ងៃមួយខ្ញុំម្ចាស់ទៅឆ្នេរសមុទ្រជាមួយប្តីរបស់ខ្ញុំម្ចាស់ ស្រាប់តែឮសូរសំឡេងទារកយំ តែទៅដល់កន្លែងនោះ រកមើលទារកមិនឃើញ ឃើញតែសម្បកគ្រំមួយធំប៉ៃមួក ទើបខ្ញុំម្ចាស់យកមកទុកនៅខាងក្រោយផ្ទះ ៗ ពេលខ្ញុំម្ចាស់មិននៅ នាងនោះចេញពីសម្បកគ្រំមកបំរើខ្ញុំម្ចាស់សព្វពេល ស្ត្រីនោះនិយាយចប់ហើយ ទើបព្រះរាជាមានព្រះបន្ទូលថា អើនាង! នាងទុកសំពត់នៅនេះចុះ

ខ្ញុំឲ្យគេនៅថែមើលឲ្យ តែនាងនាំយើងទៅមើលកូនស្រីរបស់នាងមើល ។

ចៅលោដូងឃើញចិញ្ចៀនក៏ស្គាល់ថាជាចិញ្ចៀនរបស់ខ្លួន ហើយគិតថានាងពៅលាក់ចិញ្ចៀននេះ តែនាងពៅលោតទៅក្នុងសមុទ្រហើយ នរណាបានចិញ្ចៀននេះទៀត ។ ចៅលោដូងចេះតែដើរតាមស្ត្រីនោះទៅដល់លំនៅរបស់គាត់ហើយ ក៏ចូលទៅក្នុងផ្ទះដែលនាងពៅនៅខាងក្នុង ។ ពេលទៅដល់ស្ត្រីនោះស្រែកហៅនាងពៅឲ្យចេញមកថា កូនស្រី! ចេញមកការយ ព្រះអង្គម្ចាស់នេះចង់ឃើញកូនស្រីឯង! ។ នាងពៅសួរទៅស្រីនោះថា ព្រះអង្គម្ចាស់ណាចង់មើលខ្ញុំ ឲ្យចូលមកក្នុងផ្ទះមក តែថាឲ្យខ្ញុំចេញទៅក្រៅផ្ទះនោះខ្ញុំមិនទៅទេ ។ ចៅលោដូងស្គាល់សំដីនាងពៅក៏ចូលទៅចាប់ឱបរឹតតាមសេចក្តីដែលស្រណោះអាឡោះអាល័យមកជាងមួយឆ្នាំហើយ ឯនាងពៅវិញក៏តាំងតែពីយំរៀបរាប់តាមការដែលនាងបានផ្សងព្រេងមកជាង ១ ឆ្នាំដែរ ។ ទីបំផុតនាងពៅថា បងស្រីតាំងពីរបានធ្វើឲ្យជ្រុះចិញ្ចៀនទៅក្នុងទឹកសមុទ្រ ដូច្នោះហើយបានជាខ្ញុំលោតទៅយកចិញ្ចៀនមកវិញ ដោយខ្លាចបងដេរប្រទេចខ្ញុំ ។

ស្រីនោះទុកឲ្យនាងពៅនឹងចៅលោដូងយំឱបគ្នា សំណេះសំណាលក្នុងការនិកសគ្នា ឯគាត់វិញចេញទៅអង្គុយនៅខាងក្រៅផ្ទះ ។ ប្តីប្រពន្ធឮគេយំរៀបរាប់ខាងក្នុង ទើបដឹងថានារីនេះ ជាព្រះអង្គម្ចាស់ក្សត្រី រួចព្រះអង្គម្ចាស់នោះ ជាចៅលោដូង ។ ចៅលោដូងបានជួបនាងពៅវិញ

ហើយ យំសំណោះសំណាលអស់ចិត្ត ក៏នាំគ្នាទៅថ្លែងអំណរគុណចំពោះបុរសប្ដីប្រពន្ធ ហើយវិលត្រឡប់ទៅព្រះរាជវាំងវិញ ។ ព្រះវររាជមាតាបិតាឃើញដូច្នោះ ក៏រត់មកចុម្ពិតព្រះរាជបុត្រីពៅ ហើយទ្រង់វិយោគយ៉ាងយូរ ទើបទ្រង់មានបន្ទូលសួរពីរឿងឯទៀតៗ ។ ចំណែកព្រះរៀមទាំងពីរព្រះអង្គវិញ ក៏យំសោកសែរ ដោយនឹកខ្លាចប្អូនពៅធ្វើទណ្ឌកម្ម ព្រោះកំហុសនេះពិតជាធ្លាក់មកលើខ្លួន ។ ឯអាមាត្យ សេនាបតី ប្រជារាស្ត្រគ្រប់គ្នាមកថ្វាយពរសព្ទសាធុការនាងពៅនិងចៅរលាដូងយ៉ាងអស្ចារ្យ ។

ក្រោយដែលបានជួបនាងពៅដូច្នោះហើយ ព្រះរាជាបង្គាប់ឲ្យហៅបុរសប្ដីប្រពន្ធទុគ៌តនោះមក ទ្រង់ព្រះរាជទានភូមិមួយកន្លែងយ៉ាងធំ ហើយសង់ផ្ទះឲ្យនៅមានខ្ញុំបំរើឆ្វេងស្ដាំ ។ ព្រះរាជាទ្រង់ប្រទានសំពត់ហូលទៅវិញ ហើយទ្រង់ប្រទានវត្ថុគ្រប់បែបឲ្យបុរសប្ដីប្រពន្ធនោះទុកជារង្វាន់ ។ ព្រះរាជាទ្រង់ដាក់រាជ្យបង្វែរទៅឲ្យចៅរលាដូងឡើងសោយរាជ្យជំនួស ។ ចៅរលាដូងឡើងគ្រងរាជ្យប្រកបដោយសេចក្ដីក្សេមក្សាន្តតពូជវង្សរហូតមក ។

( ចប់ )

# តាមឯកសារក្រុមទំនៀមទម្លាប់ខ្មែរ

## ក្រមួនឈាបមាត់

(ត–ចប់)

លោក មា.ស-ហាំ វរមន្ត្រី

នាយការិយាល័យ នៅសាលាក្រុងភ្នំពេញ

រៀបរៀង

## ក)- វិធីស្លក្រមួនមាត់និងខាប់ដុតអង្កាម

កាលពីដើមរៀងរាបដរាបមក អ្នកប្រកបមុខរបរក្រមួនមាត់តែងទម្លាប់ស្ល ក្រមួនដាក់ក្នុងខាប់ដុតអង្កាម មកពីថាកាលជាន់ដើម គេរាប់អានក្រមួនណាស់ហើយគេរើសយកតែក្រមួនលេខ ១ ផង ៗ ក្រមួនមាត់ប្រភេទនេះ គេស្លច្រើនថ្ងៃ ថែទាំភ្លើងនិងកូររឹកជាញឹកញយ ឥតហ៊ានដើរទៅណាមកណាឲ្យឆ្ងាយពីកន្លែងដុតភ្លើងស្លទេ ខ្លាចក្រមួនខ្លោចដោយសារភ្លើងច្រើន ឬឆៅដោយភ្លើងតិច ៗ ក្រមួនមាត់ណាខ្លោចឬឆៅ គេសន្មតថាក្រមួនសំណល់លក់ពុំដាច់ទេ ៗ មុននឹងចាប់ស្លក្រមួនមាត់គេត្រូវប្រមូលវត្ថុធាតុដូចខាងក្រោមនេះ :

១- អង្កាមស្អិត ត្រូវជញ្ជូនមកទុកនៅក្នុងម្លប់កុំឲ្យមានទឹកចូល ឲ្យសោះ ៗ ចំនួនអង្កាម ត្រូវឲ្យមាន ២ តៅ ក្នុង ១ ខាប់ ក្រមួនបំរុងស្ល ៗ

**២. ខាប់** គេត្រូវរើសយកខាប់ណាដែលមានសាច់ក្រាស់រលីងផិត កុំឲ្យមានរន្ធធ្លុកម្ហូស កុំឲ្យពាំបែកប្រេះដោយសារកំដៅភ្លើង នៅពេលស្លក្រមួន ៗ ខាប់ត្រូវមានកំពស់ពី ០ម៣០ ទៅ ០ម៤០ និងទទឹងបាតក្រោមពី ០ម២៥ ទៅ ០ម៣០ ហើយដែលមានចំណុះពី ២៥ ទៅ៣០ នាឡិ ៗ នៅពេលស្លគេដាក់មិនឲ្យពេញតាមចំណុះខាប់ទេ គឺគេដាក់ឲ្យស្មើតែត្រឹមកំពស់ទ្វេភាគត្រី «២/៣» នៃខាប់ ៗ គ្របខាប់សោតទៀត ក៏ត្រូវរើសរកឲ្យមានទំហំល្មមមាត់ខាប់កុំឲ្យធំឬតូចជាង ៗ

**៣. វែក** គេត្រូវរកវែកសំពប់កូរក្រមួន ៗ វែកនេះមានសភាពដូចជាច្រវ៉ាអុំទូកដែរ តែមានទំហំតូចជាងនិងរាងមូលជាងច្រវ៉ាទូក ៗ វែកនេះគេធ្វើដោយឈើ ឬបន្ទាស់នោបឬស្សីគោសខាត់យ៉ាងស្អាតរលោង ៗ គេប្រើវែកឈើធំមានប្រវែង ០ម៧០ សំពប់កូរជ្រួយប្រេងក្រមួនស្ល ឲ្យដល់បាតខាប់ ៗ ចំណែកវែកតូចដែលធ្វើពីបន្ទាស់នោបឬស្សីប្រវែងប្រហែលជា ០ម២៥ នោះគេទុកសំពប់កូរវែកក្រមួនសើរៗ ខាប់ រួចយកទៅសៀតទុកពិនិត្យមើល ក្រមួនដែលជាប់នៅនឹងវែកនោះ តើក្រមួនស្លបានសភាពយ៉ាងណាហើយ? ដល់កំរិតណាហើយ? មានទំនងផលល្អ ឬអាក្រក់ ៗ បើពិនិត្យឃើញភ្លើងមិនគ្រប់គ្រាន់ គេដាក់អង្កាមថែម ៗ ប៉ុន្តែបើមានទំនងជាភ្លើងខ្លាំង គេបន្ថយភ្លើងឲ្យតិចទៅវិញ ៗ

**៤. ប្រេងសំរោង** វត្ថុធាតុដែលត្រូវយកទៅស្លក្រមួនមាត់នោះ មានប្រេងសំរោងមួយមុខ ដែលមិនអាចជៀសវាងបាន មិនយកទៅប្រើផ្សំពុំបាន ។ ចំនួនប្រេងដែលត្រូវលាយនោះទៀត ក៏មានភាគច្រើនជាងគេ គឺត្រូវលាយប្រេង ៥ ភាគ ក្រមួនសុទ្ធ ១ ភាគ ទើបបានកើតជាក្រមួនមាត់លេខ ១ ។ ប្រេងសំរោងឥតមានដាក់លក់ដូចវត្ថុដទៃទេ បើអ្នកណាត្រូវការស្លក្រមួន ត្រូវអ្នកនោះខំស្វះស្វែងដើរទៅរកបេះផ្លែសំរោងយកមកបុកបញ្ជាន់ពៀតយកប្រេងខ្លួនឯងទៅ ។

**ការបេះផ្លែសំរោង** ដើមសំរោងមានដុះតិចតួចស្តួចស្តើងណាស់ៗ គេឃើញច្រើនដុះនៅឆ្ងាយៗ តាមទីទួលអ្នកតាបង់បត់ ព្រៃខ្មោច ឬព្រៃស្រោង ឥតមានដាំនៅក្នុងភូមិផង របងជាមួយទីលំនៅគេទេ ព្រោះខ្មែរយើងជឿថា ឈើនេះជាជំរក ឬផ្ទះនៃខ្មោចបិសាច តែងធ្លាប់ពឹងពាក់អាស្រ័យនៅ ។ រុក្ខជាតិ នេះមានសាច់ឈើមានគុណភាពល្អប្រសើរ មានសម្បុរពងមាន់ គេតែងយកដើម ឬមែកធំៗទៅជ្រៀកជាក្ដារក្រាល ក្ដារជញ្ជាំង គ្រឿងផ្ទះ ឬធ្វើជាថែវប្រាក់សំពប់ថែវឬអុំទូក ដោយហេតុថា ឈើនោះស្រាល ស្វិតឈ្នះទឹក ហើយកម្រនឹងពុកផ្ដេសផ្ដាសផង ។

ខែបុស្ស មាឃរៀងរាល់ឆ្នាំ គេឃើញផ្លែសំរោងចាស់ល្មមនឹងបេះប្រឡេះយកគ្រាប់ទៅធ្វើជាប្រេងបាន ។ អ្នកស្វះស្វែងរកផ្លែសំរោងនោះពុំមែនបេះតែបេះផ្លែតាមអំពើចិត្តទេ គឺគេបេះតែដើមណាដែលធ្លាប់បេះពី

ឆ្នាំមុនៗមកទេ ។ ពិតមែនហើយតែដើមសំរោងដុះនៅដីឥតមានម្ចាស់ បង់ពន្ធជូនរាជការ តែជាដីដែលរូបអ្នកតា- អ្នកចាស់ស្រុក ធ្លាប់កាន់កាប់ អ្នកស្វះស្វែងបេះផ្លែសំរោងត្រូវតែទៅជំរាបសុំអ្នកម្ចាស់ខាងលើជាមុនសិន- ទើបបេះបាន ។

ការរៀបចំដំណើរចេញទៅបេះផ្លែសំរោងនោះ ត្រូវវៃលចម្ងាយពីផ្ទះ ទៅដើមសំរោងថា តើត្រូវធ្វើដំណើរអស់រយៈពេលខ្លីតែក្នុងមួយថ្ងៃវិលត្រ- ឡប់មកផ្ទះខ្លួនវិញ ឬអស់រយៈពេលដល់ទៅ ៤-៥ ថ្ងៃ ។ ចម្ងាយផ្លូវជិត ឆ្ងាយនេះ ហើយដែលជាមេគំនិតបំរុងរៀបចំដំណើរ គឺត្រូវវៃលលកពី :

១– ស្បៀងអាហារ «អង្ករ ម្ហូប» ចានឆ្នាំង- ប៉ាំងជុង ភួយ សំពត់ ដងទឹក ។

២– ប្រដាប់ប្រដាសំរាប់បេះសំរោង ចែការ កាំបិតធំ- តូច ពូថៅ ។ល។

៣– យានជំនិះ បើតាមទឹកគេត្រូវប្រើទូក ។ បើតាមដើងគោកគេ ត្រូវប្រើរទេះគោ សម្រាប់ដឹកនាំសំរោងដែលបានបេះចេញពីដើមរួចហើយ យកមកផ្ទះវិញ ។

កាលបើធ្វើដំណើរទៅដល់កន្លែងដើមសំរោងហើយ គេត្រូវជំរាប ម្ចាស់ដើមសំរោង ឬម្ចាស់ស្រុកជាដំណឹង គេអុចទៀន ធូបសំបួងសង្រួង សុំជោគជ័យក្នុងការបេះផ្លែសំរោង កុំឱ្យបិសាចមកបៀតបៀន គឺសុំបេះ

ផ្លែសំពេងឲ្យបានសេចក្ដីសុខ កុំឲ្យមានគ្រោះថ្នាក់ ។ តមកទៀតគេចាប់ឡើងលើដើមសំពេង ការផ្លែទីងបែចំលាក់មកដីត្រាតែអស់ផ្លែពីលើដើម ហើយគេឡើងទៅលើដើមសំពេងមួយថ្មីទៀត គេធ្វើដូច្នេះលុះត្រាតែអស់ផ្លែនៅគ្រប់ដើមហើយទើបឈប់ ។ ដូចបានដំរាបមកខាងលើស្រាប់ហើយថា បើដើមសំពេងស្ថិតនៅឆ្ងាយពីផ្ទះ គេបេះផ្លែប្រឡេះយកគ្រាប់ដឹកទៅផ្ទះ ។ ឯសំបក គេចោលឬទុកដកយកទៅថ្ងៃក្រោយ បើមានពេលទំនេរគួរមកដឹកយកបាន ។ បើផ្ទះនៅជិតទៅវិញ ហើយគេមានយានជំនិះគ្រប់-គ្រាន់ផង គេដឹកនាំផ្លែទាំងមូលទៅកាប់ប្រឡេះយកគ្រាប់នៅឯផ្ទះ ។ ព្រោះថាសំបកដែលហាលស្ងួតអាចយកទៅដុតធ្វើជាក្បូនទុកសម្រាប់ ប្រ-យោគសូត្រ ធ្វើទំពាំង កក់សក់ លាងខ្លួនប្រាណជំនួសសាប៊ូបាន ។

## ក)- ការបំបែកគ្រាប់ ផ្ទៀលយកសាច់ហាលនិងដាក់សង្កត់គាបយកប្រេង

ផ្លែសំពេងចាស់មានពណ៌បៃតងពីខាងក្រៅ ស្បៀងខ្ចីពីក្នុង គ្រាប់សម្បុរស ។ កាលបើដឹកនាំទៅដល់ផ្ទះសម្បែងហើយ គេដើរហៅប្រ-មូលក្មេង ចាស់ ប្រុស ស្រី ទំនេរឥតការធ្វើ មកជល់យកគ្រាប់ទៅផ្ទះរៀងខ្លួន ដើម្បីធាកបំបែកទិងធ្កៀលយកគ្រាប់ ហើយគិតឈ្នួលតាមចំនួនតៅៗ នៅពេលនោះ ឈ្នួលធាកទិងក្កិះធ្កៀលយកសាច់តម្លៃ ១ តៅតែ ០រ១៥ ៗ រយៈពេលធ្វើការក្នុងមួយតៅនេះ ជួនកាលកន្លះថ្ងៃ ជួនកាលពេញមួយថ្ងៃ

តាមការនៃអ្នកស៊ីឈ្នួល ជាអ្នកយឺត ឬអ្នករហ័សរហួន ។

អ្នកស៊ីឈ្នួល កាលបើយកគ្រាប់សំពេងមកដល់ផ្ទះហើយ គេយកប្រណាកទៅឆាកគ្រាប់បំបែកជា ២ រួចគេចាប់ដាក់ចែកទៅអ្នកបំរុងឆ្កឹះឆ្កៀលបកសំបកដទៃទៀត ។

តាមធម្មតា អ្នកឆាកផ្លែសំពេងជាអ្នករហ័សរហួនប្រសប់ជាងគេ ។ អ្នកឆាកបំបែកមួយរូប ត្រូវឆាកបំបែកបានចំនួនសំពេងគ្រប់គ្រាន់សម្រាប់អ្នកឆ្កឹះឆ្កៀល ៤-៥ រូប ។

បំណែកអ្នកឆ្កឹះឆ្កៀល គេត្រូវមានចង្កៀសគ្រប់គ្នា ម្នាក់ចង្កៀស១ ។

ចង្កៀសមានរូបរាងប្រហាក់ប្រហែលនឹងដែកពន្លាកនៃជាងឈើដែរ គឺមានផ្លែធ្វើពីដែកគោលតូច ដំឡែសំប៉ែតមានរាងចុងបន្តិច ។ គល់ផ្លែចង្កៀសគេរុំបូលទៅក្នុងដង ធ្វើពីមែកឫស្សីមានទំហំប៉ុនម្រាមដៃមនុស្សចាស់ ។ ចង្កៀស «ផ្លែនិងដង» មានប្រវែងពី ០ម០៨ ទៅ ០ម១០ ។

នៅពេលឆ្កឹះឆ្កៀល គេវាល់សំពេងនឹងកំប៉ុងទឹកដោះគោ ឬត្រ-ឡោកដូង គេយកមកដាក់តរនៅពីមុខ រួចគេចាប់ចង្កៀស គឺកាន់ចង្កៀសដៃស្តាំ ផ្លែសំពេងឆាកហើយនៅដៃឆ្វេង ។ គេយកចង្កៀសទៅដាក់ចូកខាងចុងសាច់សំពេង រួចគេឆ្កឹះបំបែកសាច់ឲ្យចេញពីសំបកហើយគេទុកដោយខ្លួនពីគ្នា ។

ដើម្បីឲ្យការត្អឹះត្អៀលយកសាច់បានឆាប់រហ័ស គេច្រើនប្រើវិធី
ត្អៀសយកសាច់ដោយប្រណាំងគ្នា និងបានជាកស្តុតាងសំគាល់ថា អ្នក
ណាប៉ុនប្រសប់ជាងអ្នកណា ។ ការភ្នាល់គ្នាគេពុំសូវមានដាក់ជាប្រាក់
កាសទេ ព្រោះថាល្បែងភ្នាល់នេះមានលេងតែក្នុងក្រុមគ្រួសារ ។ ប៉ុន្តែ
គេច្រើនផ្តន្ទាទោស បូតច្រមុះអ្នកចាញ់ ។

លុះគេត្អឹះត្អៀលយកសាច់សំពេងអស់ហើយ គេត្រូវនាំយកទៅ
ជូនម្ចាស់សំពេងយកប្រាក់ឈ្នួលម្តង រួចវាល់យកគ្រាប់សំពេងថ្មីមកចាត់
ចែង ត្អឹះត្អៀលតទៅទៀត គ្រាតែកាលណាអស់ផ្លែសំពេងទើបឈប់ៗ

ការត្អឹះត្អៀលផ្លែសំពេងចប់ហើយ គេត្រូវយកកន្ទេលទៅក្រាល
នៅកណ្តាលវាលល្ហមតែកំដៅព្រះអាទិត្យមានពេញមួយថ្ងៃយ៉ាងគ្រប់គ្រាន់
កុំឲ្យមានម្លប់បាំងពីលើឲ្យសោះ គឺថា បើហាលទៅហើយមានស្រមោល
ម្លប់មកបាំងគេទាញអូសកន្ទេលទៅកន្លែង ១ ថ្មីទៀត ដែលមានកំដៅ
ព្រះអាទិត្យ ។ សាច់សំពេងមុនហាល គេហៅថាសំពេងនៅសម្បុរស្រស់
តែដល់ហាលបានគ្រប់កំណត់ ២-៣ ថ្ងៃទៅ សាច់នោះប្រែជាមានពណ៌
លឿងចាស់ ឬទៅពណ៌ធម្មតាវិញ ។

កាលណាបើមានមេឃអាប់អួរបំរុងធ្លាក់ភ្លៀង ឬមានភ្លៀងធ្លាក់ជោក
ជាំ ឥតមានកំដៅព្រះអាទិត្យ គេមានមធ្យោបាយ ១ បែបទៀត គឺដាក់
ក្នុងចង្អេរឬចាក់រែកពាយឲ្យស្តើងលើចង្អេរដុតភ្លើងពីខាងក្រោម ។ ប៉ុន្តែវិធី

ខាងក្រោយនេះ គេពុំសូវយកមកនិយមទេ ដោយហេតុថាខាតប្រយោជន៍ច្រើន : រកទុស ចាំថែទាំក្មេង ។

## ១–ការ បុកជាន់ប្របាច់យកប្រេង

កាលណាសាច់សំពោងបានហាលស្ងួតអស់ហើយ ម្ចាស់សំពោងគេទៅជួលមនុស្សប្រមាណជា ៩-១០ នាក់ ដែលធ្លាប់ធ្វើសំពោងមកជួយប្របាច់ប្រេងតាមបយកប្រេង ។ ជាដំបូង គេដាំទឹកនឹងថ្នាំង ឬកូនឃ្ទះឲ្យពុះហើយ ទុកមួយអន្លើសិន ទើបយកសាច់សំពោងទៅបុកជាន់នឹងត្បាល់ទៀត ។ កាលបើជាន់នឹងត្បាល់បែកសាច់ខ្ទិចខ្ទីហើយ គេកកាយចេញពីត្បាល់ដាក់ក្នុងកញ្ជើ យកទៅដាក់ជិតអ្នកអង្គុយប្របាច់ប្រេង ។

ពួកអ្នកប្របាច់ គេកើបសាច់សំពោងខ្ទិចស្រេចហើយដាក់ចូលទៅក្នុងផើង ចំនួន ២-៣ ត្រឡោកម្តង រួចយកទឹកពុះច្របល់ប្រឡាយប្របាច់ត្រាណាតែ សាច់សំពោងលាយនឹងទឹកក្តៅនោះស្អិតលាយគ្នាចូលជាសាច់មួយ ទើបគេពូតប្របាច់ឲ្យស្រក់ប្រេងទៅក្នុងផើង រួចគេពូតជាពំនូតមួយប៉ុនកដៃមនុស្សចាស់ដាក់ទៅក្នុងកញ្ច្រែងមានទ្រាប់ស្លឹកចេក ៣ ឬ ៤ ជាន់នៅបាត ។

ក្រោយប្របាច់នឹងពូតជាពំនូតអស់ហើយ គេយកកញ្ច្រែងពំនូតនោះទៅដំកល់លើផើងហើយយកដុំថ្ម ឬដុំឈើធ្ងន់ៗ សង្កត់ពីលើឲ្យចេញប្រេងធ្លាក់ទៅក្នុងផើង ។ គន្លង ៥ ថ្ងៃក្រោយមក ប្រេងឈប់ស្រក់ចុះទៀត

ហើយ គេដាំទឹកយកពំនូតនោះទៅដាក់ជាន់កំទេចនឹងត្បាល់ជាន់មួយលើកទៀត ហើយប្រួចទឹកក្តៅបន្តិចៗ ទៅក្នុងត្បាល់ ។ លុះបុកបញ្ចាន់គ្រប់គ្រាន់ហើយ គេកកាយចេញពីត្បាល់យកមកច្របាច់ឲ្យស្រក់ប្រេង ហើយពូតពំនូត ដូចពំនូតលើកមុន រួចយកទៅសង្កត់ ៤ ឬ ៥ ថ្ងៃទៀត ។ របៀបបុកបញ្ចាន់កាកសំពេងដដែលៗនេះ គេធ្វើតែបីលើកទេ រួចគេកកាយកាកនោះចោលឈប់លែងប្រើការគេទៀត ។

ប្រេងសំពេងមានជាតិដូចប្រេងធម្មតា តែស្អិត ធ្ងន់ជាងប្រេងដទៃៗទៀត ។ គេទទួលទានពុំបានទេ ។ គេពុំអាចយកប្រេងសំពេងទៅលាបជំនួសប្រេងសម្រាប់តាក់តែងកងកាយបានទេ ដោយវាមានក្លិនមិនល្អ តែប៉ុន្តែគេអាចយកទៅប្រើលាយនឹងកំបោរជុំតឲ្យផុស ប្រើជាថ្នាំកែពេកសម្រាប់លាបកមរមាស់ឲ្យបានជាសះធុតឆាប់បាន ។

សារុបសេចក្តីទៅថា ការតាក់តែងធ្វើប្រេងសំពេងឥតមានដាក់ដាំដុតភ្លើងចំអិនបីដូចជាប្រេងដូង ឬប្រេងដទៃទៀតទេ គឺគេគ្រាន់តែច្របាច់លាយនឹងទឹកក្តៅ រួចសង្កត់កើតជាប្រេងសំពេងទៅហើយ ។

## ៥–ក្រមួនសុទ្ធ

វត្ថុធាតុមួយមុខទៀត គឺក្រមួនឃ្មុំសុទ្ធដែលគេទិញពីផ្ទះផ្សារ ។ ក្រមួននេះគេរើសតែក្រមួនសុទ្ធ ហើយមានសម្បុរសផង ។ ឯសម្បុរ

ក្រហាមគេពុំសូវយកទេ ព្រោះស្ទូបានជាក្រមួនមាត់ក្ងរកែទៅមិនបាន សម្បុរសតាមសេចក្ដីត្រូវការនៃលោកអ្នកប្រើប្រាស់ ។

## ក្រមួនមាត់ទន់រអិល "បែបទី ៣"

បើគេចង់បានក្រមួនមាត់រអិល ឬក្រមួនមាត់លេខ ២ គេត្រូវយកវត្ថុធាតុ ១ មុខទៀត គឺប្រេងដូងសុទ្ធមកលាយ មានភាគស្មើនឹងប្រេងសំពេង ហើយដាក់ក្រមួនសុទ្ធ ១/៥ ភាគរួចស្ងួចធម្មតាទៅ ។

ប្រេងដូងទិញនៅផ្សារពុំសូវបានសុទ្ធទេ មុននឹងប្រើប្រេងដូងនេះ គេត្រូវយកទៅដាក់ក្នុងខ្ទះដុតភ្លើងចំរាញ់ឲ្យវាងទឹកអស់ សល់តែជាតិប្រេងដូងសុទ្ធ ។

**ការរៀបចំមុនដុតភ្លើង:** កាលណាគេបានលាយប្រេងសំពេង ប្រេងដូង ក្រមួនសុទ្ធដាក់ចូលក្នុងខាប់រួចអស់ហើយ គេយកខាប់នោះទៅដាក់តម្រៀបគ្នាជាជួរ ឃ្លាតពីគ្នាឲ្យបាន ០ម៍៥០ ពីខាប់មួយទៅខាប់មួយទៀត ។ គេស្ងួមួយលើកមួយលើកគឺមានចំនួនពី ៣ ទៅ ៦ខាប់ ។ ការស្ងួក្រមួនគេច្រើនធ្វើនៅក្រោមផ្ទះ ហើយធ្វើរបងព័ទ្ធពីក្រៅកុំឲ្យមនុស្ស ឬសត្វចេញ- ចូលទៅទីនោះបាន ។ លុះតម្រៀបខាប់តាមកន្លែងហើយ ទើបគេយកអង្កាមស្ងួតទៅដាក់ជុំវិញខាប់នោះ បានកំពស់ត្រៀបនឹងមាត់ខាប់ រួចហើយគេយកដុប ៣ សរសៃដុតបង្ហុយឲ្យស្ងួក្រមួនបានល្អ-

ផលល្អ ។ តមកគេយកដុំខសក្អើនទៅសើកក្នុងពាំងទូកអង្កាមកប់ខាប់ឲ្យគ្រប់ពាំងទូក ។ គេយកផ្ទិតបក់ ឬបំពង់ផាត់ផ្លុំឲ្យភ្លើងនេះកាត់ទៅអង្កាម ត្រាតែឆេះអង្កាមហើយទើបម្ចាស់ដើរចេញ ។

**វិធីដុតភ្លើង:** ដំបូងគេត្រូវលៃបែបណា ឲ្យការចាប់ផ្ដើមដុតភ្លើងឲ្យទាន់ពេលព្រឹកព្រហាម ដើម្បីនឹងឲ្យបានក្រមួនសុទ្ធ នឹងប្រេងរលាយចូលគ្នាឲ្យទាន់មុនពេលយប់ ។

ក្រោយពីការដុតជាដំបូងនោះមក គេយកវែកដំកូរកឡដល់បាតខាប់ កុំឲ្យខ្មោចឬឡើងបាយដុំៗ ។ ការស្ងួនេះ ជាការប្រឹតប្រៀនណាស់ អ្នកស្ងួពុំហ៊ានដើរចោលយូរពេកទេ ព្រោះថា បើភ្លើងច្រើនពេកត្រូវបន្ថយចេញខ្លះ ។ បើភ្លើងតិចវិញ ត្រូវថែមអង្កាមឲ្យបានភ្លើងល្មម ។ រយៈពេលស្ងួចំនួន ៤ ថ្ងៃ ៤ យប់ ទើបក្រមួនឆ្អិនល្អ ។

របៀបកូរវិត ពេលថ្ងៃគេកូរ ៤ លើក ពេលយប់ ៣ លើក ។ វែកគេប្រើដំកូរកឡដល់បាតខាប់ ។ វែកតូចសំរាប់ដួលយកទឹកក្រមួនមកទុកឲ្យស្ងួត ហើយលុញមើល លក្ខណៈក្រមួនតើបានដល់សភាពណាហើយ តើគួរល្មមដាក់ភ្លើងថែម ឬ បន្ថយភ្លើងវិញ ។

## ១) វិធីស្ងួក្រមួនផងខ្វះដុតខុស

វិធីស្ងួក្រមួនមាត់បែបទី ២ នេះ គឺគេស្ងួឲ្យបានទាន់ចិត្ត ។ ឲ្យបានក្រមួនឆ្អិនក្នុងរយៈវេលាតែ ៣ ម៉ោងប៉ុណ្ណោះ ។ ការស្ងួរបៀបនេះ អ្នក

ស្លជាមនុស្សរហ័សរហួនប៉ុនប្រសប់ញាប់ដៃ-ជើង ទើបហ៊ានស្ល ៗ បើពុំនោះទេ មុខជាខ្លោចឬឡើងបាយខូចក្រមួនជាពុំខាន ៗ

ជាដំបូង គេថ្លឹងប្រេងសំរោង ប្រេងដូង ក្រមួនសុទ្ធ តាមវិធីលាយដូចដំរាបខាងដើមស្រាប់ ៗ រួចហើយគេយកប្រេងនិងក្រមួនទៅដាក់ក្នុងខ្ទះស្ពាន់ ឬដែក ដាក់លើចង្ក្រានដុតសធម្មតា ៗ គេកូរវឹកទីងវៃក្លើងជានិច្ច ត្រាតែក្រមួនឆ្អិនទើបដាក់ពីចង្ក្រានឈប់តែម្តង ៗ

សូមជំរាបថា ការស្លក្រមួននេះ បើស្លទៅហើយមានខ្លោចឬបាយដុំៗ គេតែងយកក្រមួនមាត់នៃខាប់ឯទៀត ដែលមានភាពល្អមកកូរកំលាយឲ្យច្របូកច្របល់គ្នាឲ្យបានក្រមួនមាត់ប្រហាក់ប្រហែលគ្នាងាយលក់ចេញ ៗ

## វិធីអប់ក្រមួនឲ្យក្រអូប

ក្រមួនមាត់ស្លឆ្អិនហើយ មានសម្បុរល្បៀងចាស់ ខះរឹងជាប់បាតខាប់ ឬខ្ទះ ទឹងមានក្លិនប្រេងសំរោងលាយក្រមួនសុទ្ធ ៗ ដល់ពេលគេត្រូវការអប់ឲ្យមានក្លិនក្រអូប គេត្រូវឆ្កឹះកាយរំលែកសាច់ក្រមួនក្នុង ១ ខាប់ជា ៣ ឬ ៤ ជើង ដើម្បីឲ្យធូរកម្លាំងក្នុងការកាយ វែកញែកទឹងឲ្យមានក្លិនផ្កា ងាយចូលចាប់សព្វសាច់ក្រមួនផង ៗ

បើគេស្លក្រមួនច្រើនខាប់ គេត្រូវឆ្កឹះកកាយយកទៅអប់មួយខាប់ឲ្យក្រអូបគ្រប់គ្រាន់រួចយកទៅលក់ ទើបគេចាប់អប់មួយខាប់បន្តបន្ទាប់ទៅទៀត ត្រាតែកាលណាអស់ក្រមួន ៗ

របៀបអប់ក្រមួននោះ គេត្រូវជ្រើសរើសរកកន្ទេងក្នុងបន្ទប់ផ្ទះ កន្ទុកកន្ទៀតដែលមានក្រាលក្តារយ៉ាងជិត ឥតមានឃើញប្រហោងពីខាងក្រោម ៗ នៅលើក្តារ គេក្រាលកន្ទេលមួយជាន់ និងក្រាលស្លឹកចេក ៣-៤ ជាន់ពីលើថែមទៀត ៗ

នៅថ្ងៃអប់ក្រមួនជាដំបូង គេត្រូវយកផើងក្រមួនមកដាក់ហាលទឹងកំដៅព្រះអាទិត្យពីព្រឹកដល់ថ្ងៃត្រង់ដើម្បីឲ្យក្រមួនរាវទន់ងាយស្រួលកូរវឹក ៗ ពេលថ្ងៃរសៀលជ្រេ គេទៅបេះយកផ្ការំដួល ប្តូរំចេកពីដើមរួចយកមកប្រស់ទឹក ទុកមួយអន្លើសិន ៗ គេយកផើងក្រមួនហាលថ្ងៃមកកូរវឹកឲ្យទន់សព្វសាច់ វែកពាយឲ្យស្តើង ធ្វូតកាត់ឲ្យមានចំនួន ៨ បង្អួរ រួចគេទុកមួយអន្លើឲ្យក្រមួនត្រជាក់ ៗ ទើបគេយកផ្ការំដួល ប្តូរំចេកទៅគរជាពំនូកតូចៗ នៅកន្ទេងបំរុងអប់ឲ្យស្រប ទៅតាមចំនួនផើងក្រមួនដែលបានកូរវឹករួចហើយ ៗ ក្រោយមកទៀត គេយកផើងក្រមួនទៅផ្កាប់គ្របពីលើគំនរផ្កាឲ្យជាប់គ្នារាំ ៗ គេពិនិត្យមើលកុំឲ្យមានចំហ ការពារកុំឲ្យក្លិនផ្កាចេញទៅក្រៅបានឲ្យសោះ ៗ

ព្រឹកឡើងគេយកផើងទាំងនោះមកកូរវឹកម្តងទៀត រួចយកទៅផ្កាប់លើគួងផ្កាដូចដើមវិញ ៗ ពេលរសៀល គេទៅបេះផ្កាជាថ្មីយកមក ៗ ការកូរវឹកក្រមួនទីងផ្លាស់ផ្កាជាថ្មីមានធ្វើជារៀងរាល់ថ្ងៃ គ្រាតែក្រមួនជាប់ក្លិនផ្កាជាប់ក្រអូបគ្រប់កន្ទេងឥតចន្លោះទើបគេឈប់អប់ ៗ

វិធីធ្វើក្រមួនមាត់នេះ សូមសន្មតមកជាចប់ត្រឹមនេះ ៗ

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា នូ កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស់បើបានអាន
និងចេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ
យូរ—អ៊ុន

ទៀវហ៊ុយឃើញដូច្នោះ ក៏លើកទាហានថយចេញមកវិញ ហើយឲ្យបោះបន្ទាយចម្ងាយពីគ្នាប្រហែល ១០០ សិន (៤គីឡូ) លុះវេលាព្រឹកឡើងក៏លើកទៅមុខបន្ទាយឲ្យទាហានស្រែកជេរជាពាក្យទ្រគោះមាក់ងាយដូចម្តេច ទៀវខាប់ក៏មិនបានចេញតដៃ ឲ្យទាហានរក្សាសើនបន្ទាយជាមាំមួន ហើយទៀវខាប់ឡើងទៅលេងភ្លេងតូរ្យតន្ត្រីចាប៉ីទ្រនៅលើភ្នំ ទៀវហ៊ុយក៏ប្រើទាហានឲ្យស្រែកជេរទៀវខាប់ជាពាក្យអសុរោះរាល់ពេល ទៀវខាប់ក៏បានចុះមកតយុទ្ធនាគ្នាសោះ ទៀវហ៊ុយឃើញដូច្នោះក៏នាំទាហានវិលចូលបន្ទាយវិញ លុះពេលព្រឹកទៀវហ៊ុយក៏នាំទាហានទៅឲ្យស្រែកជេរទៀវខាប់ប្រកាសម្តេច ៗ ទៀវខាប់ក៏នៅសម្ងំស្ងៀមក្នុងបន្ទាយ ចេះតែលេងភ្លេងមហោរីនៅលើភ្នំ ។

លុយគង់ឃើញដូច្នោះ ក៏នាំទាហានចូលរាយរំលាយបន្ទាយផេក

នៀមជាដរាប ទៀវខាប់ក៏ឲ្យទាហានចោលដុំថ្មចេញមកពីក្នុងបន្ទាយ ត្រូវទាហានទៀវហ៊ុយរបួសពិការជាច្រើន ទៀវហ៊ុយឲ្យថយចេញមកវិញ ហើយឲ្យទាហានស្រែកជេរប្រមាថទៀវខាប់ជាច្រើន ទៀវខាប់ក៏បង្គាប់ទាហានឲ្យជេរតបមកវិញថា អាទៀវហ៊ុយជាអ្នកលក់ស្រា ទៀវហ៊ុយខឹងណាស់មិនដឹងនឹងធ្វើយ៉ាងម្ដេចសោះ តាំងតែការុងប្រុងនឹងច្បាំងគ្នាក្នុងទីនោះអស់រពង ៥០ ថ្ងៃ ទៀវហ៊ុយផឹកស្រាស្រវឹងហើយក៏ឲ្យទាហានស្រែកជេរទៀវខាប់គ្រប់វេលា ទៀវខាប់ក៏មិនចេញតច្បាំងសោះ ។

ឯបណ្ដាទាហានដែលនាំស្បៀងមកជូនទៀវហ៊ុយឃើញដូច្នោះ លុះត្រឡប់ទៅស្រុកសែឈួនវិញ ក៏យកសេចក្ដីនោះទៅពណ៌នាជំរាបឡៀវពីថា ទៀវហ៊ុយតាំងកគ្នានឹងទៀវខាប់គ្រប់ ៥០ ថ្ងៃហើយ មិនបានតយុទ្ធគ្នាសោះ ទៀវហ៊ុយនោះចេះតែផឹកស្រាស្រវឹងក្លែងឲ្យទាហានទៅស្រែកជេរទៀវខាប់គ្រប់វេលា ទៀវខាប់ក៏មិនបានចេញច្បាំងសោះ ។

ឡៀវពីឮដូច្នោះក៏ប្រឹក្សានឹងខុងបេងថា ទៀវហ៊ុយទៅធ្វើការសឹកសង្គ្រាម បើចេះតែផឹកស្រាស្រវឹងដូច្នោះ យើងនឹងគិតប្រការដូចម្ដេច! ខុងបេងថាដែលទៀវហ៊ុយធ្វើដូច្នេះ ព្រោះមិនមានស្រា (ខ្លាំង) ក្នុងកងទ័ព សូមឲ្យចាត់ស្រា (បិតខ្លាំង) ៥០ ផុទិនផ្ញើទៅចុះ ឡៀវពីថា បើទៀវហ៊ុយផឹកស្រាស្រវឹងគ្រប់វេលាណា ក៏រមែងខូចការគ្រប់គ្រា ហេតុម្ដេចលោកខឹងចង់ឲ្យផ្ញើស្រាទៅឲ្យទៀត ទឹងមិនផឹកស្រវឹងខ្លាំងឡើងទេឬ! ការ

សង្គ្រាមដែលទៅធ្វើនោះ នឹងមិនខូចអសារទៅហើយ ឬ ។

ខុងបេងអស់សំណើចហើយថា លោកជាបងប្អូនបានរួមសុខទុក្ខនឹងគ្នាមកយូរហើយ ហេតុអ្វីនៅមិនស្គាល់ចិត្តទៀវហ៊ុយវេលានេះ កាលពីដើមឡើយហ៊ុយជាមនុស្សច្រើសច្រេនងអង់អាចកាចសាហាវណាស់មែន តែកាលគ្រាលើកទ័ពមកវាយយកស្រុកសៃឈ្លួននេះ ខ្ញុំសំគាល់ឃើញថាទៀវហ៊ុយលះព្យុហៈកំណាចកាចសាហាវនោះអស់ហើយ មានគរម្រេះចេះចាប់ងៀមង៉ាន់បានដោយប្រាជ្ញា ក៏ជានិមិត្តប្រកបដោយបុណ្យសម្ភាររបស់លោកគ្រប់គ្រងទំនងឲ្យទៀវហ៊ុយ ចេះក្លែងនាំទាហានចេញទៅដេរទៀវទាប់នោះ ព្រោះជាកលឧបាយ ។

ឡើយពីថា ខ្ញុំនៅមិនទាន់ទុកចិត្តសោះ ត្រូវឲ្យអ៊ុយអៀនលើកទាហានទៅជួយទៀត ហើយក៏ឲ្យចាត់ស្រាបញ្ជូនទៅឲ្យទៀវហ៊ុយផ្ទុកពេញរទេះ មានទង់ជាតិអក្សរថា ឲ្យទៀវហ៊ុយខំយកចិត្តគិតធ្វើការឲ្យមានជ័យជំនះដល់ទៀវទាប់ ឲ្យបានអ៊ុយអៀនទទួលបណ្តាំ ហើយក៏លាឡើយពីនាំទាហានឲ្យបររទេះដឹកស្រាទៅដល់បន្ទាយទៀវហ៊ុយគ្រប់ប្រការ ។

ទៀវហ៊ុយឮដូច្នោះ ក៏មានចិត្តសោមនស្សណាស់ ទើបបង្គាប់លុយគងនឹងអ៊ុយអៀនថា យើងនឹងលៀងទាហានឲ្យមានចិត្ត កំរើកសប្បាយអ្នកទាំង ២ នាយចូលចាំមើលឲ្យជាសុខសប្បាយចុះ បើកាលណាឃើញយើងលើកទង់ក្រហមឡើង ត្រូវឲ្យនាំទាហានចូលទៅព្រួតវាយបន្ទាយទៀវទាប់

ជាប្រញាប់ចុះ ហើយឲ្យចងរូបយន្តបដូចជារូបទៀវហ៊ុយ ហើយលាក់ទុក លុះពេលល្ងាចក៏ឲ្យយកស្រាមកលៀងទាហានទាំងពួង រួចឲ្យរាំយកគងឃោះស្រែកហ៊ោអឹងកងនៅក្នុងបន្ទាយ ។

ឯទាហានទៀវទាប់ ក៏លបចេញទៅមើលឃើញគលការហើយក៏វិលទៅប្រាប់ទៀវទាប់ៗដឹងហើយ ក៏នាំទាហានដែលទៅប្រាប់នោះ លបទៅមើលលើកំពូលភ្នំក្បែរបន្ទាយ ឃើញទៀវហ៊ុយអង្គុយផឹកស្រាឲ្យទាហានជាល់គ្នា ទៀវទាប់ក៏ត្រឡប់ទៅបន្ទាយវិញហើយគិតថា ទៀវហ៊ុយមិនបានឃើញយើងចេញច្បាំង បានជាមានចិត្តកំរើកលេងល្បែងសប្បាយមិនមានចិត្តគោតញញើតយើងសោះ គិតដូច្នេះហើយ ក៏បង្គាប់ទាហានថា ក្នុងពេលយប់នេះ យើងនឹងលើកទាហានចេញទៅប្លន់បន្ទាយទៀវហ៊ុយ ឲ្យទាហានក្នុងបន្ទាយបងថៅនឹងបន្ទាយបងសេក លើកចូលមកវាយខ្ទប់ប្រសព្វគ្នាទាំងឆ្វេង-ស្តាំ ។

លុះដល់ពេលយប់ខែភ្លឺច្បាស់ ទៀវហ៊ុយក៏ឲ្យយករូបយន្តបំពាក់អាវអង្គុយកាន់ពែងស្រាបែបប្រុងនឹងផឹក មានទាហានចូលទៅចាំបំរើជាច្រើននាក់ ឯខ្លួនទៀវហ៊ុយនោះ នៅពួនលាក់ខ្លួនមិនឲ្យឃើញ ហើយឲ្យអ៊ុយអៀន លុយគងចាត់ថែងទាហានត្រៀមទុកព្រម ។

ឯទៀវទាប់នោះ លុះនាំទាហានទៅដល់មុខបន្ទាយទៀវហ៊ុយ ឃើញរូបទៀវហ៊ុយ នៅអង្គុយផឹកស្រា ក៏សំគាល់ថាជាទៀវហ៊ុយប្រាកដ

ទៀវខាប់ក៏ប្រញាប់បរពលចូលទៅ តាមព័ទ្ធវាយបន្ទាយ ធ្លាយចូលទៅបាន ក៏បរសេះបំពានទៅដល់យល់ទៀវហ៊ុយអង្គុយផឹកស្រា ក៏លើកលំពែងឡើងចាក់ធ្លាក់ រូបទៀវហ៊ុយពីលើកៅអី លុះក្រឡេកទៅឃើញច្បាស់ជារូបយន្តមិនចេះស្តីក៏ភ័យណាស់ ក្រឡាស់បរសេះវេះថយមកក្រោយវិញនឹងចូលបន្ទាយ ទៀវហ៊ុយ ពួនឃើញច្បាស់ ក៏ស្ទុះចេញមកដុតផាវជាសញ្ញា បណ្តាទាហានទាំងប៉ុន្មានក៏ដុតភ្លើងឡើងពេញក្នុងបន្ទាយ ទៀវហ៊ុយក៏ឡើងសេះចេញទៅហើយស្រែកថាអញឯណេះគឺទៀវហ៊ុយ ហើយក៏បរសេះស្ទុះចូលទៅច្បាំងប្រកាប់គ្នានឹងទៀវខាប់បាន ៣០ ក្បួន ។

ខណៈកាលទៀវហ៊ុយ នឹងទៀវខាប់ ជាប់ដៃច្បាំងគ្នានោះ ទាហានទាំង ២ បន្ទាយក៏លើកចេញមកជួយ ព្រួតវាយខ្ទប់ប្រសព្វគ្នា ទទួលអ៊ុយអៀន នឹងលុយគង់ចេញទៅស្ទាក់ពីមុខជាប់ ហើយអ៊ុយអៀននឹងលុយ-គង់ ក៏បរសេះចូលប្រកាប់សម្លាប់ទាហានទាំង ២ កងនោះ បែកខ្ចាត់ខ្ចាយអស់ អ៊ុយអៀននឹងលុយគង់ ក៏លើកតាមទៅ ហើយវាយទំលាយយកបន្ទាយទៀវខាប់បាន ហើយក៏យកភ្លើងដុតបន្ទាយទាំង ៣ នោះឆេះឡើងព្រមគ្នា ។

ទៀវខាប់ឃើញដូច្នោះក៏ដឹងថា បន្ទាយទាំង ៣ នោះវិនាសអស់ហើយដោយកលឧបាយទៀវហ៊ុយ ក៏បំផាយសេះរត់ទំលុះចេញទៅត្រង់គយអ៊ួនថៅក្ជួន ទៀវហ៊ុយនោះ លុះបានជ័យជំនះហើយ ក៏ឲ្យបំរើសេះកាន់សំបុត្រទៅប្តឹងឡៀពីតាមមុខពងការ ឡៀពីបានទទួលដំណឹងជីង

ការណ៍ហើយ ក៏ត្រេកអរណាស់ និយាយថា ទៀវហ៊ុយស្រវឹងស្រានេះនាំជាកលឧបាយ ដូចពាក្យខុងបេងថាមែន ៗ

ឯទៀវទាប់នោះខូចអស់ទាហានប្រមាណ ២០.០០០ នាក់ ទើបនាំទាហានដែលសល់ ១០.០០០ ទៅតាំងបន្ទាយនៅគយអ៊ួនឡៅក្អួន ហើយឲ្យទាហានទៅប្តឹងឡោហាងឲ្យលើកមកជួយ ឡោហាងបានដឹងហើយក៏ខឹងណាស់ថា ការនេះយើងបានហាមឃាត់ហើយមិនព្រមស្តាប់តាមពាក្យយើង ខំចចេសចចេងទៅច្បាំងនឹងទៀវហ៊ុយទាល់តែខូចការដូច្នេះ ថែមឲ្យយើងលើកទ័ពទៅជួយទៀត ឡោហាងក៏បង្គាប់ទាហាននោះថា ឲ្យទៀវ-ទាប់ប្រញាប់ លើកទ័ពទៅច្បាំងនឹងទៀវហ៊ុយទៀត ខំយកជ័យជំនះវិញឲ្យបាន ទាហាននោះក៏ត្រឡប់ទៅប្រាប់ទៀវទាប់តាមពាក្យឡោហាងថា ៗ

ទៀវទាប់ បានស្តាប់ក៏គិតព្រួយវិតក្កណាស់ ទើបបំបែកទាហាន ១ កងឲ្យទៅពួនបង្កប់នៅផ្លូវតូចក្បែរជើងភ្នំខគយ ហើយបង្គាប់ថា យើងនឹងលើកទៅច្បាំងនឹងទៀវហ៊ុយទៀត បើទៀវហ៊ុយដេញយើងមកតាមផ្លូវនេះ ក៏ឲ្យអស់អ្នកពល់គ្នាលើកចេញមកស្ទាក់យកជ័យជំនះឲ្យបាន លុះពេលព្រឹក ទៀវទាប់ក៏លើកទាហានចេញពីបន្ទាយ ប្រទះលុយគង់លើកទ័ពមក ទៀវទាប់ក៏បរសេះចូលច្បាំងនឹងលុយគង់បាន៥ក្បួន ទៀវទាប់ធ្វើជាថយរត់ លុយគង់មិនបានដឹងកលឧបាយ ក៏ដេញតាមទៅដល់ផ្លូវតូច ដែលទាហានទៀវទាប់ពួនបង្កប់នៅក្បែរផ្លូវនោះ ទាហានទាំងពួងក៏ដេញព្រមគ្នាមកស្កាត់ស្ទាក់លុយគង់ជាប់ ៗ (នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

(ក)

លោក ឌ. តាម ស្រាវជ្រាវ និង រៀបរៀង

រីឯទសកក្រ្តអសុរា លុះក្រឡេកមើលឃើញនាងមណ្ឌោគិរីកាលណា ក៏ចាប់ចិត្តស្នេហាទឹកថា នាងនេះល្អលើសអស់ស្រីនៅស្ថានសួគ៌ទៀត និងយកមកផ្ទឹមឲ្យត្រឹមស្មើពុំបាន អសុរាក៏លើកដៃប្រណម្យបង្គំក្រាបលាសម្ដេចព្រះបរមចក្រាធិបតីហើយ ក៏ពនាំហោះទៅកណ្ដាលវេហាស៍មក ក៏មានចិត្តនោះស្រឡាញ់ណាស់ ក៏កៀកកាយឧនថើបប្រឡែងលេងលើវេហាស៍នភាល័យ មិនគិតអ្វីសោះឡើយ លុះតែហៀរហោះមក ក៏កន្លងព្រះនគរខិតខិនបុរីរាជស្ថានព្រះបាទក្រុងពាលីពានរ ជាបុត្រសម្ដេចព្រះកោសីយ គ្រានោះទក្រុងពាលីមានបុណ្យក្លាហាន ស្ដេចគង់ត្រង់សីហបញ្ជរបង្អួចរតនវេក្ខា ព្រមទាំងពួកពលសេនាអាមាត្យមុខមន្ត្រីតូចធំគាល់ហៅនៅបំរើដេរដាសពាសពេញត្រៀបត្រា រង់ចាំបង្គាប់កិច្ចរាជការជាទីក្ដង ទីប្រជុំគាល់ ៗ លុះព្រះបាទក្រុងពាលីក្រឡេកមើលតាមទ្វារបង្អួចទៅឯអាកាស ឃើញមានយក្សអសុរីពស្រីហោះកន្លងនគរហើយ ព្រះអង្គក៏ទ្រង់ខ្ញាល់ក្រេវក្រោធ ទន្ទ្រាំព្រះបាទាហើយស្ដីថា បើអាទសកក្រ្តនេះវាព្រហើនណាស់វាមើលងាយអញ វាមិនខ្លាចអំណាចបុណ្យអានុភាពអញសោះឡើយ ស្រេចហើយ ក្រុងពានរក៏ចាប់យកព្រះខ័នពេជ្រ ស្រេចហើយក៏ខាំមាត់សង្កៀតធ្មេញក្រវីអាវុធសំដែងឫទ្ធិតេជៈហោះទៅគិតកាប់សម្លាប់ឲ្យបានដូច

សេចក្ដីប្រាថ្នាហោង ។ លុះហោះទៅបានដល់ក្រឡេកយល់ឃើញនាង
នោះល្អល្អះត្រចះត្រចង់ មុខមូលដូចដួងព្រះច័ន្ទ ពានរក៏បង្កើតសេចក្ដី
ស្រឡាញ់ពេញចិត្តណាស់ហើយក៏ស្រែកថា ម្នាលទសកណ្ឋអសុរអើយ
រីខ្លួនអញនេះក៏កប់ថា ជាអគ្គប្រុសទីងគេមួយដែរ ដូចម្ដេចក៏ឯងនេះ
ព្រហើនមាក់ងាយ មិនមានកោតក្រែងមុខយើងនេះដល់តិចសោះឡើយ
បានជាឯងពស្រីហោះកន្ទុំដែននគរអញនេះ អញនឹងប្រហារជីវិតឲ្យ
មរណាក្នុងគ្រានេះឯងហោង ។

កាលនោះ រីឯទសកណ្ឋយក្សនោះ លុះស្រាប់ឃើញក្រុងពាលី
ពានរហោះមកតាំងពាំងពីមុខដូច្នោះហើយ កាលនោះ រីឯទសកណ្ឋអសុរ
ក៏ក្រេវក្រោធពេកខ្លាំង ក៏ត្រាស់ថា ចឹ! ចឹ! មើលអាជាតិតិរច្ឆានសន្ដាន
ថោក ម្ដេចមកធ្វើខ្លាំងពូកែអួតអាងកាងក្រទាឲ្យហួសយសស័ក្ដិ រីឯអាកាស
ជាស្ថានខាងលើនេះ សំរាប់ជាទីទេវសុភបុទ្ធពិធ្យាធរកិន្នរនាគគន្ធព្វសុ-
បណ្ណគ្រុឌមហាឥសីមហាបក្សា តែងតែហើរហោះផ្ចុះដោយផ្លូវវេហាស៍
អាកាស ឥឡូវនេះអញពប្រពន្ធអញ ហោះមកតាមអាកាសវេហាស៍ ជា
ទីតាមចិត្តអញ ក៏មិនបានមកជាន់លើក្បាលអាស្វាឯងពីកាលណា កុំថាតែ
អាឯងមកតាំងពាំងពីមុខចង់ច្បាំងនឹងអញ អញក៏មិនខ្លាចគង់តែនឹងឃើញថ្វី
ដៃឥឡូវនេះហោង ។

រីឯក្រុងពាលីពានរិន្ទ្រ លុះឮសំដីអសុរថាឲ្យអាក្នាដូច្នោះហើយ ក៏

ឆ្លើយតបទៅវិញថា ណែវើយអសុរអាឯងម្តងនេះ អាឯងគង់តែស្លាប់នឹងដៃអញពុំខានឡើយ ប្រពន្ធនេះអាឯងកុំស្មានទឹកថាជាប្រពន្ធអាឯងឡើយ នាងនេះជាប្រពន្ធរបស់អញទេ ថាហើយក៏គ្រវីព្រះខ័នពេជ្រ ស្ទុះចូលទៅគកាំងច្បាំងនឹងទសគ្រ្តអសុរ ជាវិកវរកោលាហលទៅវិញទៅមក ប្រឡុកប្រឡងល្បងឫទ្ធាអានុភាព កាលនោះទសគ្រ្តអសុរពប់គកាំងច្បាំងនឹងក្រុងពាលីយូរបន្តិចទៅ ក៏ថមថយកំលាំងពលំតាំងឫទ្ធិវិជ្ជាការ ដៃមួយពាន ដៃ ១៩ ក៏កាន់គ្រឿងសស្ត្រាវុធគ្រប់ដៃ កាំងវាយសំពងទៅពាលី ៗ ពាលីក៏គេចកែប្រែ ចាប់គ្រឿងសស្ត្រាវុធជាប់អស់ហើយ ក៏ពាលីស្ទុះទៅចាត់ចាក់ត្រូវត្រង់អង្គអសុរជាច្រើនដងច្រើនគ្រា ក្រុងទសគ្រ្តអសុរក៏ថយកំលាំងឫទ្ធា ក្រុងពាលីក៏ដណ្តើមយកនាងមណ្ឌាគីរីទៅបាន រីក្រុងទសគ្រ្តក៏ទឹកស្តាយនាងណាស់ ស្រក់ទឹកព្រះនេត្រ ណាមួយទឹកស្តាយនាងណាស់ ណាមួយទឹកខឹងក្តៅទឹងពាលីណាស់ ហើយក៏ប្តូរស៊ូជីវិតមិនខ្លាចស្លាប់ឡើយ គិតហើយក៏ស្ទុះចូលទៅគកាំងច្បាំងដណ្តើមយកនាងមកវិញ កាលនោះឯក្រុងពាលី ដៃឆ្វេងពនាងមណ្ឌាគីរី ដៃខាងស្តាំកាន់ព្រះខ័នកាល់ការកាយមិនឲ្យត្រូវអង្គព្រះអគ្គបាន ហើយក៏លើកជើងឡើងធាក់ត្រូវអាទសកណ្ឋច្រេកច្រោកជាដំណាំក្រខួន មិនតែម៉្នោះឡើយ ក៏ឲ្យកចំអកចំអន់ ញាក់មុខញាក់មាត់ញេញញេញញៀកចិញ្ចើម ហើយថាណែអសុរអាឯងមានមុខ ១០ដៃនោះ ២០ ទំសំពង់វាយអញ អញចាញ់អាឯង

តែប្រពន្ធអាឯងនោះមកនៅឯដៃអញវិញ ណែអាមុខងាប់ប្រពន្ធអាណា នេះថាតែម្ល៉េះហើយ ក្រុងពាលីក៏ខឹងជើបប្រហារចំមិចម្ដូល បញ្ឈួលបញ្ឈឺចិត្តក្រុងអាសុរថែមទៀត ៗ រីឯក្រុងទសកណ្ឋអសុរ ក៏ទាល់គំនិតទាល់ប្រាជ្ញា ទាំងឫទ្ធិទៀតក៏ទន់ទាប អាប់ជាងគេផង ទឹងប្ដូលតតាំងច្បាំងក៏ពុំបាន ម្ល៉េះហើយក៏ហោះរត់ចេញទៅហោង ៗ

កាលនោះទើបក្រុងពាលីឫទ្ធិក្លាហាន ក៏បានឃើញទសកណ្ឋអសុរយកក្សា ក៏តាលតាញ់ដៃ គេចរត់ទៅផុតបោះហើយ ក៏ពយកនាងមណ្ឌោគិរីមកឯពស្ថានលុះបាមកដល់កាលណោះហើយ ស្ដេចក៏ដាក់នាងឲ្យអង្គុយលើខែនទិព្វមន្ទីរមណ្ឌបហើយ ទើបមានព្រះឱង្ការសួរទៅថា ម្នាលនាងដ៏ចំរើនជួនចិត្តអើយ ដូចម្ដេចឡើយក៏នាងបានមកដៃអសុរគប្រិយ ហើយខ្លួននាងឯង តើនាមឈ្មោះអ្វីប្រាប់បងឲ្យបានដឹងផង ៗ មួយទៀតប្អូនឯង តើជាបុត្រស្ដេចណា ពង្សវង្សត្រកូលនាងនោះដូចម្ដេច ឬនាងជាស្រីទេពកញ្ញានៅស្ថានសួគ៌ា ចូរនាងប្រាប់មកឲ្យបងបានដឹងក្នុងគ្រានេះហោង ៗ កាលនោះ រីឯនាងមណ្ឌោគិរីក៏ទឹកភ្នាស់អៀនអន់ ក៏ឱនកាយក្រាបថ្វាយបង្គំហើយ ក៏ទូលតបថា ខ្លួនខ្ញុំម្ចាស់នេះឈ្មោះនាងមណ្ឌោគិរី ជាកូនលោកតាមហាឥសីទាំង ៤ ព្រះអង្គទ្រង់ព្រួចិញ្ចឹមជីវិតខ្ញុំម្ចាស់ ហើយព្រះអង្គក៏នាំយកខ្លួនខ្ញុំម្ចាស់ មកថ្វាយឲ្យនៅជាខ្ញុំបំរើបាទសម្ដេចព្រះមហាលោកនាថឥស្សរាធិរាជស្ថានកៃលាស ហើយទ្រង់ប្រើទសមុខមារឲ្យជំរុំ

ស្ពានកៃលាសគិរីត្រង់ស្រេចកាលណាហើយ ក្រុងអសុរកទូលសុំយក សម្តេចព្រះឧមា ទើបព្រះមហាឥសូរលោកា ទ្រង់ព្រះរាជទានខ្ញុំម្ចាស់នេះ មកជំនួសជួសអង្គអគ្គមហេសីសម្តេចព្រះឧមាភោគវត្តី បានជាអសុរខ្ញុំម្ចាស់ហ៊ានមកសូមទ្រង់ជ្រាប ។ កាលនោះរីក្រុងពានរពាលី ក៏បាន ទ្រង់ព្រះសណ្តាប់ស្តាប់វាទីនារីទូលដូច្នោះហើយ ក៏លោមលួងនាងថា អូន អើយរីអាទសកណ្ឋយក្សនោះ វាមិនគួរជាគូរមកវាសនានឹងអូនឯងទេ នេះ ជាបុព្វបុណ្យបងនិងអូនបានកសាងមុនមក ទើបវាបណ្តាលឲ្យវាពាំពៅនាំអូន មកជួបនឹងបងហោង ។ ណ្ហើយចុះបងនឹងចិញ្ចឹមជប់លៀងនាងឲ្យធ្វើជា ឯកអគ្គលើស្រីស្នំក្រមការទាំងពួង ។ កាលនោះក្រុងពានរពាលីថាតែ ម៉្លោះ ហើយក៏ស្ទុះទៅចាប់ឱបក្រសោបថ្នមបីដាក់លើភ្លៅថើបអង្អែលប-ពោសអស់អង្គហើយ ក៏ទ្រង់រួមរសសង្វាសនាការរួចស្រេចកាលណាហើយ រីនាងមណ្ឌោគិរីសោមនស្សរួបស្នេហានឹងពានរកាលណាហើយ ក៏ភ្លេចភ្លាំងនឹកទៅដល់ សម្តេចព្រះឥសូរទិង នាងឧមាភោគវត្តី ស្រីស្នំក្រមការ ហើយភ្លេចទាំងក្រុងអសុរផង ហើយនាងក៏ខំស្វាហាប់បំរើក្រុងពាលី ជាទីបរមសុខក្សេមក្សាន្តសំរាន្តកាយហោង ។

កាលនោះរីក្រុងទសកណ្ឋអសុរ លុះមកដល់ប្រាសាទពិមានស្ពានអាគ្នាកាលណាហើយ អសុរក៏ចូលទៅផ្ទំក្នុងទីសយនា ហើយក៏ទ្រង់ព្រះកន្សែងសោយសោកាខ្ទួញថា ឱអញអើយ អញមានបុត្តអានុភាព

គ្នាហានបានពប់សាសាធ្វើការថ្វាយ សម្ដេចព្រះឥស្សូរជាម្ចាស់លើសិរសា ទៀយលំបាកណាស់ ទំលើកគុំកៃលាសឡើងតម្កើងទំរាំតែត្រង់ ស្មើរតែទីងផាច់ឲ្យលស្លាប់ សម្ដេចព្រះមហាលោកា ក៏ទ្រង់ព្រះរាជតានទានមួយឲ្យមកមិនទាន់បានដល់នគរ ហើយមានសា្លព្រៃចង្រៃចិត្តថា កាចយោរយៅដណ្ដើមយកទៅបាន នុអញអើយមិនគួរឡើយ មកបាញ់បុត្រអាគ្រង់ពាលីជាសត្វតិរច្ឆាន នុនាងមណ្ឌាគិរីអើយ ប្អូនអើយមិនគួរឡើយមកឃាតពីទ្រង់បង់ទៅឡើយ គ្រង់អសុរក៏ទ្រង់សោកាទំនួញទួញសព្វគ្រប់ សន្ទប់សន្ទឹងរឹងតែទុក្ខថែមពុំក្សេមក្សាន្តបានគ្រាន់បើឡើយ ។ រីនាងអគ្គនាគជាអគ្គមហេសីទូវស្រីកំណាន់ស្រីង៉ាជាបវរ លុះឃើញគ្រង់អសុរស្ដេចមកដល់កាលណាហើយ ក៏មានដួងព្រះភក្ត្រានោះ ក្រៀមក្រំពុំសោយក្រយាស្ងោយឡើយ ហើយស្ដេចយាងចូលទៅផ្ទុំយំសោកបោកខ្លួនដួលបោះហើយ វិហ្វងនារីកំណាន់ ក៏នាំគ្នាចូលទៅគាល់បំរើបក់ផ្លិតថ្វាយដោយមុខក្រ-ស្ងួនគ្នាក់ង៉ាតែពល់គ្នាទៅហោង ។

កាលនោះ ទីគ្រង់ទសកគ្គេឃើញអស់អ្នកអស់នាងស្រីស្នំបំរើថ្វាយយូរនាន ក៏ពិនិត្យមើលរូបដោមលោមពណ៌ហើយ ទ្រង់ស្ដាប់សំលាក់សំឡេងស្រីស្នំប្រៀងជ្រួចគ្រលួចឡើងក៏មិនពិរោះ ទាំងរូបនោះក៏មិនល្អដូចនាងមណ្ឌាគិរីឡើយ ក៏បណ្ដាលដួងចិត្តនោះមួម៉ៅក្ដៅថើមប្រមាត់ ក៏ត្រោតចុះពីទៃនទំព្រសយនាសនៈ ទ្រង់ព្រះបាតាសទ្ទីកសន្ទាប់ញាប់ញ័រ ហើយ

ទ្រង់មានព្រះឱង្ការត្រាស់ថា ណែ៎មេពួកចង្រៃកាឡកណ្ណីទាំងអស់គ្នា រត់ចេញឲ្យអស់ទៅតែនៅហើយ អញនឹងកាប់សម្លាប់បំបាត់ជីវិតឲ្យក្ស័យឥឡូវនេះហោង ៗ ត្រាស់ថាដូច្នោះហើយ ក៏ចាប់យកព្រះខ័នពេជ្រគ្រីគ្រវាសហើយទ្រង់ស្រែកសព្ទសំឡេងនោះឮខ្លាំងដូចរន្ទះទាំង ៧ ដេញកាប់ស្រីស្រឹង្គារជាចលាចល កាលនោះ រីអស់ស្រីស្នំក្រមបរិវារទាំងពួងក៏ភិតភ័យរត់រត់ព្រោងព្រាយ ប្រញាយយកតែអាយុតែរៀងខ្លួន ហើយនិយាយថ្លែងទុក្ខប្រាប់គ្នាថា ក្រែងអស្សុកទៅធ្លាក់ផ្ទៃនរកយំសោកបោកខ្លួនបំភាសនទៀលទៅវិញទៅមក ព្រោះតែនាងមណ្ឌោគិរី មិនចេញឲ្យសេនាអាមាត្យមុខមន្ត្រីគាល់ហៅឡើយ ជាទុក្ខយូរអង្វែងមកណាស់ហើយលុងលុះតែកន្លងបានដល់ ៧ ខែ សោយតែទុក្ខ ទុក្ខជានិច្ចជានិរន្តរ៍ ៗ

កាលនោះ កុម្ភកាណ៌ជាមហាឧបរាជនិងក្រុងពិភេក្សអស្សុកជាប្អូនទសកណ្ឋ ឃើញសម្ដេចព្រះជេដ្ឋាវង្វេងវិកវត្តព្រើលផ្ដាស ខុសចរិតក្រិត្យវិយោបថមិនដូចពីដើម មិនចេញមកឲ្យសេនាបតីមុខមន្ត្រីចូលគង់គាល់ដូច្នោះហើយ ក៏មានចិត្តនោះព្រួយតែកល់គ្នា លុះបានថែងហេតុកាលណាហើយ ទើបមកប្រឹក្សានឹងគ្នាជំនុំទៅឃើញថា ការនេះមានតែយើងទៅនិមន្តព្រះសិទ្ធាមហាគោបុត្រ អាចារ្យមកល្បងលោមនិយាយសួរការឲ្យបានដឹង ជំនុំព្រមគ្នាហើយ ក៏ចាត់សេនាយក្សមួយឲ្យទៅនិមន្តព្រះមហាឥសីគោបុត្រ ឲ្យស្ដេចនិមន្តមកជាឆាប់ ៗ រីសេនាជាបុរីនោះ

លុះឮតម្រាស់ប្រើអាត្មាដូច្នោះហើយ ពុំលង់ឡើយលើកកំបង់អង្គអញ្ជលី ហើយហោះទៅឯព្រៃហេមពាន្តព្រះមហាឥសីគង់នៅនោះហោង លុះដល់អាស្រមបរមសាលាព្រះមហាគោបុត្រហើយ ក៏ចូលទៅក្រាបបង្គំទូលសេចក្ដីថា សម្ដេចព្រះអនុជមហាបពិត្រព្រះចៅក្រុងលង្កា ឲ្យមកនិមន្តព្រះមហាអាចារ្យឥឡូវនេះ ព្រោះត្បិតសម្ដេចព្រះជេដ្ឋាទសកណ្ឋអសុរពជាចមកំពូលលង្កាទ្វីបនោះមិនសប្បាយ ៗ កាលនោះ ព្រះមហាឥសីគោបុត្របានស្ដាប់ដំណឹងការណ៍ដូច្នោះហើយ ក៏រៀបស្បៀងស្បង់ទ្រង់ជតាស្បៃស្បែកខ្លាគ្រប់គ្រឿងបរិក្ខារស្រេចម្នីម្នាជាឆាប់ចាប់យកឈើច្រត់ បានហើយក៏ហោះមកជាមួយនឹងពលសេនាបំរើមកហោង ៗ លុះមកដល់ក្រុងលង្កាទ្វីបហើយក៏ស្ដេចនិមន្តមកគង់លើគ្រែអាសនៈហើយ រីឯព្រះហស្ដនោះ ក៏កាន់ផ្ចិតនិងយាមមិនលែងឡើយ ហើយទ្រង់ផ្អែកទម្រេតទៅលើខ្នើយពូថៅយ៉ាងល្អ ៗ កាលនោះ ក្រុងទសកណ្ឋយក្ស លុះឃើញព្រះមហាឥសីនិមន្តមកដូច្នោះហើយ ក៏មានមនោចិត្តនោះត្រេកអរសោទរសោមនស្សណាស់ក៏ឱនកាយក្រាបថ្វាយបង្គំព្រះអាចារ្យហើយដកដង្ហើមធំយំក្រាបទូលទៅព្រះ-មហាឥសីថា ខ្ញុំព្រះករុណាដែលបានធ្វើជាការថ្វាយសម្ដេចព្រះចមកៃ-លាសបានទ្រង់ព្រះពរទាននាងមណ្ឌោគីរីឲ្យមកខ្ញុំព្រះករុណា ក៏ឡូវនេះអាពាលីវមកដណ្ដើមយកទៅពីខ្ញុំព្រះករុណា ៗ ដូច្នេះសូមព្រះអាចារ្យមេត្តាជួយយកឲ្យបាននាងមក ទើបខ្ញុំព្រះករុណានេះ នឹងមានជីវិតរស់នៅ

បានធ្វើជាសិស្សតទៅហោង ។

កាលនោះ ព្រះមហាឥសីគោបុត្រក៏បានស្តាប់ពាក្យ អសុរពោលពណ៌នាសព្វគ្រប់ប្រការហើយ ក៏ញញឹមឆ្លើយតបពាក្យទៅវិញថា ឱ! ការតែប៉ុណ្ណេះទេ មហាពជកុំព្រួយព្រះទ័យឡើយ សេចក្តីត្រង់នោះទុកដាក់ឲ្យអាត្មាភាពចុះ មិនក្រអឺឡើយ បើចង់បាននាងមណ្ឌាគិរីយកមកវិញនោះ មានតែទៅនិយាយនឹងមហាឥសីអង្គុត ជាគ្រូអាចារ្យគេ ឲ្យលោកមេត្តាជួយនិយាយសុំប្រហែលជានឹងបាន បើឯងកុំព្រួយចិត្តកើតទុក្ខធ្វើអ្វី ចូរបើឯងទៅឯមហាឥសីអង្គុតចុះ នឹងសម្រេចដូចក្តីប្រាថ្នាហោង ។ មហាឥសីក៏ថ្វាយព្រះពរលាវិលទៅអាស្រមកុដិវិញហោង កាលនោះ ក្រុងអសុរបានស្តាប់ព្រះពុទ្ធដីកាព្រះអាចារ្យហើយ ក៏ត្រេកអរណាស់ទើបតែងអង្គទ្រង់គ្រឿងគ្រប់ស្រេចហើយ អសុរក៏ហោះយាត្រាត្រាច់ត្រង់តម្រង់ទៅ ឯអាស្រមសាលាព្រះមហាឥសីអង្គុតនោះហោង ។ លុះហោះមកដល់ហើយ ក៏ចូលមកក្រាបថ្វាយបង្គំយំសោកបោកកាយជាខ្លាំងណាស់ ។

កាលនោះ ព្រះមហាឥសីអង្គុតឃើញទសកណ្ឋអសុរមកយំស្រែកកាលណាហើយ ព្រះមហាឥសីអង្គុតព្រះអង្គក៏ទឹកឆ្ងល់សង្ស័យក្នុងព្រះទ័យហើយទើបមានព្រះពុទ្ធដីកាសួរទៅថា ហេតុដូចម្តេចអសុរក៏បានជាឯងមកដល់ហើយក៏យំសោកបោកខ្លួនដូច្នេះ ៗ មានហេតុកេទប្រការអ្វី ចូរស្រដីប្រាប់មកអញឲ្យបានដឹងផង ។ កាលនោះ ទសកណ្ឋអសុរក៏លើកហត្ថ

ទាំងពីរក៏ក្រាបប្រណម្យបង្គំទូលតាមហេតុតាំងតែអំពីដើមដល់ចុងរឿងទៅ
រួចហើយក៏ទូលព្រះពុទ្ធដីកាថា ខ្ញុំព្រះករុណានេះ គ្មានទីពឹងមានតែទ្រង់
ព្រះករុណាជាទីពឹង ជួយសង្គ្រោះទុក្ខដោះឲ្យបាន សូមទាននិមន្តទៅនិ-
យាយយកនាងមណ្ឌាគិរីពីពាលីមកវិញឲ្យទានខាងតែបាន ប្រៀបឧបមា
បីដូចជួយជប់ជន្មជីវិតខ្ញុំព្រះករុណាឲ្យបានរស់គង់គ្រានេះហោង ៗ អសុក
ពោលពណ៌នាហើយ ក៏ក្រាបខ្ញួញយំសោកបោកខ្លួនទៅទៀតហោង ៗ
ទើបអង្គព្រះមុនីឥសីសិទ្ធ ក៏បានស្តាប់ទសកក្រ្តអសុកហើយ ព្រះអង្គទ្រង់
រំពឹងគិតពិចារណាទៅថា យើ! ក្រុងពាលី ដូចម្តេចក៏ហ៊ានធ្វើដល់ម៉្លឹងមិន
ខ្លាចខុស នាងនេះគឺព្រះឥស្សរព្រះរាជទានឲ្យគេទេតើ ម្តេចឡើយក៏
ហ៊ានដណ្តើមយកមក ៗ ការនេះឃើញថាមិនស្រួលឡើយ ទ្រង់គិត
ឃើញដូច្នោះហើយ ទើបមានព្រះពុទ្ធដីកាថា ណ្ហើយចុះក្រុងអសុក ឯង
កុំព្រួយចិត្តកើតទុក្ខឡើយ ការនេះអញរ៉ាប់ជានាទៅយកពីពាលីមកឲ្យ ចូរ
ឯងនៅចាំនឹងទីអាស្រមកុដិនេះចុះ ៗ ថាហើយព្រះមហាឥសី យក
គ្រឿងមកស្លៀកពាក់ស្រេចហើយ ក៏ហោះទៅឯនគរវិតវិនបុរីរាជធានី
ហោង ៗ លុះមកដល់ស្ថានវិតវិនបុរីហើយ ក៏និមន្តចូលទៅកាន់ស្ថាន
ពិមានហោង ៗ គ្រានោះ រីឯក្រុងពាលីក្រឡេកមើលទៅឃើញព្រះម-
ហាឥសីសិទ្ធាជាគ្រូអាចារ្យនិមន្តមកដូច្នោះហើយ ក៏ស្តេចចុះចាកពីបល្ល័ង្ក
រតនមណី ក៏នមស្ការវន្ទិយព្រះអាចារ្យ ហើយនិមន្តឲ្យឡើងគង់លើគ្រែ

អាសនៈហើយ ទើបទូលពុទ្ធដីកាប្រាស្រ័យទៅព្រះអាចារ្យថា ព្រះគុណជាម្ចាស់និមន្តមកនេះ តើមានបើរកការអ្វី ៗ កាលនោះ ព្រះមហាឥសីអង្គត់ ក៏បានស្តាប់ក្រុងពាលីសួរដូច្នោះហើយ ក៏ថារូបអាត្មាភាពនេះ ក៏មិនសប្បាយមានសេចក្តីថប់បារម្ភណាស់ ត្បិតក្រុងទសកណ្ឋយក្សវាទៅរុកគួនអាត្មាគ្រប់ពេលវេលាជារវល់ខ្លាំងណាស់ ហើយវាយំសោកបោកខ្លួនថា ខ្លួនវាបានទៅតម្រង់ភ្នំស្ពានកៃលាសបានត្រង់ កាលនោះអង្គព្រះឥសូរបានប្រទាននាងមណ្ឌោគិរីនេះឲ្យជារង្វាន់ដល់វា ហើយវាពាំហោះមកដោយវេហាស៍ កាលនោះហើយម្តេចឡើយ ក៏ឯងទៅច្បាំងដណ្តើមយកមកធ្វើជាប្រពន្ធខ្លួនឯងវិញ ឥឡូវនេះអញមកសុំនាងមណ្ឌោគិរីពីឯងទៅវិញ ការនេះតែដឹងដល់ព្រះឥសូរលោកាទៅកាលណាហើយ នឹងមានសេចក្តីខុសពុំខាន ហើយនាងនេះ ក៏ជាប្រពន្ធគេផង ដូចជាខ្លួនបាឯងនេះក៏ពូជពង្សវង្សទេវេទ មិនគួរឡើយមកចង់បានភ្លើងវិញមិនខ្លាចក្តៅ ខ្ទះអ្វីស្រីស្នំក្រមការគេរគោកគង់គាល់បំរើជាប្រក្រតី ៗ កាលនោះទើបពានរិទ្ធជាបុត្រព្រះឥន្ទ្រកោសិយ បានស្តាប់សេចក្តីព្រះមហាឥសីថា ដូច្នោះហើយក៏នឹកក្នុងព្រះចិន្តាថា រីឯនាងមណ្ឌោគិរីនេះរូបឆោមល្អណាស់ នឹងរកស្រីឯណាមកផ្ទឹមប្រៀបពុំស្មើឡើយ ឥឡូវនេះអញនឹងមិនប្រគេនព្រះអាចារ្យនេះក៏ពុំបានក្រែងតូចព្រះទ័យ បើនឹងឲ្យទៅក៏សែនស្តាយណាស់ គិតហើយទើបតបសព្វវាចាទៅនឹងព្រះអាចារ្យវិញថា អាទសកណ្ឋនេះចិត្តវាព្រហើន

ខ្លាំងណាស់ ពុំហ៊ានសុំយកសម្តេចទុមាគោគវត្តី ហើយមិនតែប៉ុណ្ណោះឡើយ ពុំហ៊ានពនាងមណ្ឌាគិរីនេះកាត់លែងនគរខ្ញុំទៀតមិនមានគោតត្រកូលសោះឡើយ ទើបបានជាខ្ញុំព្រះករុណានេះ ទឹកខឹងទឹងពណាស់ បានជាដណ្តើមយកពមក អើបើឥឡូវនេះថាទឹងមានទោសភ័យ ខ្ញុំព្រះករុណាក៏ប្រគេនព្រះករុណា ប៉ុន្តែនាងសោតក៏ទ្រង់មានគភ៌មកបានពាក់កណ្តាលឆ្នាំហើយ មិនដឹងបើទឹងគិតដូចម្តេចបានព្រះគុណ ត្បិតកូនខ្ញុំព្រះករុណានៅក្នុងពោះនាងផង រីឯចិត្តខ្ញុំព្រះករុណានេះ មិនចង់ឲ្យពប្រឡំបូលជាតិទឹងខ្ញុំ ការនេះស្រេចតែព្រះតេជព្រះគុណទ្រង់ព្រះមេត្តាប្រោស ៗ កាលនោះព្រះមហាឥសីអង្គគត់ក៏បានស្តាប់ហើយ ទើបឆ្លើយថា នោះកុំថប់បារម្ភឡើយ រីបុត្រដែលនៅក្នុងគភ៌នាងនោះ សុំអាត្មាទឹងគិតឲ្យបានស្រួល ទឹងវះពោះយកកុមារដាក់ទៅទឹងពោះពពែហោង មិនឲ្យអន្តរាយដល់ជីវិតទេ ទើបក្រុងពាលីបានស្តាប់ព្រះអាចារ្យថាហើយ ក៏ទាល់គិះគុះក្នុងព្រះចិន្តាឯណាដែលស្តាយនាងណាស់ គិតៗទៅទឹងទទឹងរឹងមិនឲ្យក្រុងទាស់ទឹងពជហឫទ័យព្រះមហាឥសី គិតហើយក៏ដកដង្ហើមធំថប់គ្រប់ប្រការហើយទូលតបព្រះពុទ្ធដីកាថា ការនេះស្រេចនៅលើព្រះគុណស្រាប់ ចាំហើយក៏ប្រាប់ទៅស្រីបំរើប្រើឲ្យទៅហៅនាងមណ្ឌាគិរីមក ៗ

គ្រានោះ រីនាងស្រីស្នំក្រមការដែលនៅបំរើឆ្វេងស្តាំប្រចាំការ លុះបានព្រះឱង្ការប្រើឲ្យទៅហៅហើយ ក៏លើកករបង្គំហើយទៅ លុះបាន

ដល់មណ្ឌលទីនាងហើយ ក៏បង្គំទូលថា សម្តេចព្រះស្វាមីស្តេចត្រាស់ឲ្យហៅទៅជាធាប់តាមបង្គាប់ហោង ។ កាលនោះ រីនាងមណ្ឌោគិរីបានដឹងសេចក្តីថា ព្រះស្វាមីទ្រង់ត្រាស់ឲ្យហៅដូច្នោះហើយ នាងក៏លាមកមួយរំពេចនឹងស្រីបំរើ លុះមកដល់ហើយ ក៏ក្រាបបង្គំគាល់ព្រះភស្តាស្វាមីថាស្តាប់ព្រះឱង្ការហោង ។ ទើបអង្គក្រុងពាលីបានឃើញនាងមកដល់ហើយ ក៏មានចិត្តនោះអាល័យស្រឡាញ់ណាស់ ក៏ដកដង្ហើមធំ ហើយទើបមានមធុរសវាចាថា ម្នាលនាងដ៏មានភក្ត្រដ៏បវរដួងចិត្តអើយ ក៏ឥឡូវនេះអង្គព្រះអាចារ្យលោកមកសុំនាងយកទៅឲ្យអសុរវិញ បងទាល់គំនិតហើយប្អូនអើយចូរនាងទៅនឹងព្រះអាចារ្យចុះ ត្បិតអង្គសម្តេចព្រះមហាឥស្សូរឥស្ស-រាធិបតីលោកទ្រង់ប្រទានឲ្យទៅអាទេសភក្ត្រអសុរ រីឯខ្លួនប្អូនឯងក៏ទៅនៅនឹងវា វាក៏នឹងតម្កើងតាំងឡើងជាធំកំពូលលើអស់ស្រីស្នំក្រមការផងទាំងពួង ធ្វើជាឯកអគ្គមហេសីក្នុងក្រុងបុរីលង្កាទ្វីប រីឯបុត្រាបង បងសូមវះពោះយកកូនគ្រាន់ទុកមើលមុខតាងខ្លួននាងភក្ត្រអក កុំឲ្យបងរលឹកពេកឡើយហើយចុះចូរអ្នកប្អូនកុំតូចចិត្តទោមស្រពោសចិន្តានឹងបងឡើយ ។

កាលនោះ រីនាងមណ្ឌោគិរី នាងក៏បានស្តាប់ហើយ នោះនាងក៏ទ្រង់ព្រះកន្សែងសោយសោកហើយទួញថា ឱ! ព្រះស្វាមីម្ចាស់ប្តីអើយ មិនមានអាណិតចិត្តខ្ញុំម្ចាស់សោះឡើយ បានជាមកកាត់សេចក្តីអាល័យក៏មកលើឯខ្លួនខ្ញុំម្ចាស់ឲ្យទៅក្រុងអសុរវិញ កាលដើមឡើយស្តេចបានព្រះបន្ទូល

ទីន៍ខ្ញុំម្ចាស់ថា ទីន៍បិតាមខ្ញុំម្ចាស់ឲ្យធ្វើជាអគ្គមហេសីជាធំលើសលើស្រីស្នំក្រមការផង៍ទាំងពួង ឥឡូវនេះមកប្រែក្រឡះក្រឡាប់បានជាលើកខ្ញុំម្ចាស់ឲ្យទៅក្រុងអសុរាវិញ ។ ឱ! ខ្លួនខ្ញុំអើយម្ដេចឡើយក៏មកអភព្វដល់ម្ល៉េះ កើតមកជាស្រីហើយមានប្ដីដល់ពីរបីដូចជាស្រីកាឡកិណី អស់ស្រីទាំង-ឡាយថាតែម៉្លោះហើយ នាងក៏ទ្រង់សោយសោកាអាមោកខ្លាំងក្រៃមហិមា លុះទាល់តែដល់សន្លប់បាត់ស្មារតីទៅហោង ។

កាលនោះ ទើបអង្គព្រះមហាឥសីអង្គុយឃើញនាងមណ្ឌាគិរីសោកាសន្លប់បាត់ស្មារតីដូច្នោះហើយ មហាឥសីក៏ហៅទៅពាលីឲ្យយកព្រះខ័នពេជ្រមកទីន៍វះពោះនាង វិក្រុងពាលីក៏ប្រគេនប្រគល់ព្រះខ័នពេជ្រមកមហាឥសីស្រេចហើយ ។ ព្រះមហាឥសី ក៏វះពោះយកព្រះរាជកុមារបានមកហើយ ព្រះមហាឥសីក៏យកទៅដាក់ក្នុងពោះសត្វពពែវិញ ។ ស្រេចហើយព្រះមហាឥសីក៏សូត្រសេកទិព្វព្រះមន្តព្រះគាថាផ្លុំទៅ ហេតុតែព្រះមន្តវិជ្ជាព្រះគាថាមហាឥសីផ្លុំត្រូវខ្លួនហើយ នាងក៏រស់ភ្ញាក់ស្មារតីវិញហោង ។

(នៅមានត)

# វិវត្តន៍នៃអក្សរខ្មែរ

(ត)

លោក ឌ. តាម រៀបរៀង

ទី៣— ព្យញ្ជនៈបែបទី ៣



ទី៤— ព្យញ្ជនៈបែបទី ៤



ទី៥— ព្យញ្ជនៈបែបនេះក្លាយចេញពីបែបទី ៤



ទី៦— ព្យញ្ជនៈនេះមិនគាត់ឃ្លៀងឃ្លាតពីបែបទី ៥ ទេ



ទី៧ - ព្យញ្ជនៈបែបទី ៧ ច្រើនភាគដែង



ទី៨– ព្យញ្ជនៈនេះមានចារនៅលើសាស្ត្រាស្លឹករឹតខ្វះ



ទី៩– ព្យញ្ជនៈនេះមាននៅសិលាចារិកដ៏យននូអង្គរវត្ត



ទី១០– បែបសម័យបច្ចុប្បន្ន

*បែបព្យញ្ជនៈ សម័យនេះលោកអ្នកបានឃើញស្រាប់ហើយ ខ្ញុំមិនបាច់យកមកបង្ហាញទៀតទេ ។*

# អក្សរខ្មែរនៅសិលាចារឹកបាន់ជ័យ

*បន្ទាប់ពីសិលាចារឹកវត្តកាញទៅ ខ្ញុំសុំបង្ហាញរូបរាងអក្សរដែលនៅសិលាចារឹកបានជ័យ ។ តាមការស្រាវជ្រាវរបស់លោក ហ្សក មាស្ប៉េរ៉ូ* (George Maspéro) *ថាព្យញ្ជនៈដែលចាស់ជាងគេបង្អស់ គឺនៅសិលា-*

ចារឹកហាន់ជ័យ ។ តែបើតាមការអង្កេតរបស់អ្នកប្រាជ្ញខ្មែរវិញថា សិលាចារឹកដែលចាស់ជាងគេបង្អស់ គឺសិលាចារឹកវ៉ូកាញ់ ។ សូមលោកពិនិត្យមើលអក្សរសិលាចារឹកនៅហាន់ជ័យ :

អក្សរនៅសិលាចារឹក ហាន់ជ័យ



បែបព្យញ្ជនៈខាងលើនេះ នៅក្នុងចវគ្គ សម័យសតវត្សទី ៦ របស់លោក ហ្ស៊ក ម៉ាស្ប៉េរ៉ូ មិនឃើញមានតួ ឈ ទេ ។ ដវគ្គមិនឃើញមាន ឌ ទេ ឯបវគ្គវិញមិនឃើញមានព្យញ្ជនៈ ផ ដែរ ។

សូមលោកពិនិត្យមើលតារាងបែបអក្សរព្រាហ្មី ហើយមកប្រៀបធៀបជាមួយសិលាចារឹកនេះ តើមានលំនាំដូចគ្នាម្ដេចខ្លះ ?

ក) - ព្យញ្ជនៈ

១- ព្យញ្ជនៈ គ សម័យសិលាចារឹកហាន់ជ័យ ឃើញមានលំនាំដូចព្រាហ្មីមែន ។ ហើយអក្សរ គ ក្រិក ក៏មានលំនាំដូចគ្នាដែរ ។

២- ព្យញ្ជនៈ ថ បែបព្រាហ្មីរាងមូល តែមានគូសកណ្ដាល ឯសម័យសិលាចារឹកហាន់ជ័យវិញ តួនេះរាងមូលទ្រវែងហើយមានគូសកណ្ដាលដូចគ្នាដែរ ឯចំណែកក្រិកវិញគូសខ្វែងកណ្ដាល ។

៣. ព្យញ្ជនៈ យ បែបព្រាហ្មីក្តាយ មានពន្ធដូចគ្នាបេះបិទទៅនឹងអក្សរខ្មែរបែបហាន់ជ័យ ។

៤. ព្យញ្ជនៈ ទ បែបព្រាហ្មី និងសិលាចារឹកហាន់ជ័យ ក៏ស្រដៀងគ្នាដែរ ។

៥. ព្យញ្ជនៈ វ បែបហាន់ជ័យនិងព្រាហ្មីមានសណ្ឋានដូចគ្នា ។

ការប្រៀបធៀបអក្សរខ្មែរទៅនឹងអក្សរឥណ្ឌាឃើញថា សម័យអក្សរខ្មែរនៅសិលាចារឹកហាន់ជ័យ ដែលចូលមកប្រទេសកម្ពុជា ពិតជាអក្សរសម័យព្រាហ្មីនៅប្រទេសឥណ្ឌាមែន ។

១) ស្រៈខ្លះនៅសម័យសិលាចារឹកហាន់ជ័យ

១- ស្រៈ អិ សម័យសិលាចារឹកហាន់ជ័យមានពីរបែប :

ក)-  = មាសន្ទែរវិណាសហ

ខ)-  = យាធំ សុវណ៌របិតំ

តាមការសង្កេតទៅឃើញថា ស្រៈ អិ សម័យជាមួយគ្នានោះមិនដូចគ្នាទេ ។ (ក) ស្រៈ អិ មានសណ្ឋានដូចជាជើង ្រ (ខ) ស្រៈ អិ មានសណ្ឋានដូចនិគ្គហិត ។

២- ស្រៈ អី សម័យសិលាចារឹកហាន់ជ័យក៏មានការឃ្លៀងឃ្លាតដែរ

ក-  = ជាជ្ជូលីតិ

១)  = ភាសិទ្ធីក្ឫតមិទំ = ន + អក្ឫតំ + ឥទំ

ស្រៈ អី (ក) មានសណ្ឋានដូចជានិគ្គហិតដែរ តែមានគូសកណ្ដាល ឯស្រៈ អី (ខ) មានសណ្ឋានដូចជាសំយោគសញ្ញាផ្ទុយ ។

៣- ស្រៈ អុ និស្ស័យមានសណ្ឋានដូចជាស្រៈ អុ សម័យបច្ចុប្បន្ន នេះមួយបែប ឃ្លៀងឃ្លាតមួយបែប ។

ក)  = មាឍាមាលុមិ

១)  = អន្ដស្យមុត្ដ

ស្រៈ អុ (ក) មានសណ្ឋានដូចជើង ញ ស្រៈ អុ (ខ) មានសណ្ឋាន ដូចបច្ចុប្បន្ន ។ ចំណែកជើង ថ្ង វិញ មានសណ្ឋានដូចស្រៈ អី តែស្រៈ អី នៅខាងលើព្យញ្ជនៈ ។

៤- ស្រៈ អូ និស្ស័យមានរបៀបដូច្នេះ

១-  = យស្យ សៃឝ្យរជោធូត

៥- ស្រៈ អេ នៅសម័យសិលាចារឹកហាក់ដូចជា ឃើញមានឃ្លៀងឃ្លាត បន្តិច តែកង់នៅដូចគ្នា

ក)  = ស្វាមិគោបើ គុរុស្មេយ

១) ជិតមន្ទីរគង្វៀន = ជិតមន្ទីរគង្វៀន

ស្រៈ អេ (ក) ស្ថិតនៅលើព្យញ្ជនៈខ្វះ អែបទីងព្យញ្ជនៈខ្វះ

ស្រៈ អេ (១) នៅអែបទីងព្យញ្ជនៈ

៦– ស្រៈ អៃ មានសណ្ឋានប្លែកគ្នាបន្តិចដូច្នេះ

ក) យក្ស សៃក្សរជោធូត = យក្ស សៃក្សរជោធូត

១) ទ្វិហាមសហ៊ៀយស្បៀរ = ទ្វិហាមសហ៊ៀយស្បៀរ

៧- ស្រៈ អោ មានសណ្ឋានដូច្នេះ

ឧ. សោមាន្ទយោប្រសូតស្យ = សោមាន្ទយោប្រសូតស្យ

៨- ស្រៈ អៅ ស្រៈនេះមានសណ្ឋានភ្ជាប់ខ្លួន ហេតុមកដល់សព្វថ្ងៃ

នេះ ៗ

ឧ. សោមសៀរមៃយោធិជៅ = សោមសៀរមៃយោធិជៅ

៩- ស្រៈសុទ្ធ អ (សូមមើលតាពងអក្សរព្រាហ្មី) មានសណ្ឋានដូច

ស្រៈ អ ព្រាហ្មី ៗ

១.  =អត្តស្យមុត្តា ទ្រៅហ្យា

១០ ស្រះ ឳ, សុទ្ធស្រះដៀងព្យញ្ជនៈ ទ ។

១.  =ឱមាត្រ្យុភង្គជិហ្មោម្មិ

១១- ស្រះ ឬ ស្រះដៀងនឹងជើងព្យញ្ជនៈ ង សព្វថ្ងៃ ។

១.  =បតិភាសិទ្ធហីកត្តាមិ

ខ្ញុំសូមជូនប្រយោគខ្លះ ដែលមាននៅក្នុងសិលាចារឹកហាន់ជ័យទុក ជូនឲ្យលោកអ្នកហាត់អានខ្ទីអក្សរសិលាចារឹក : សូមជ្រាបថា ប្រយោគទាំងនេះមិនមែនជាភាសាខ្មែរទេ គឺជាភាសាសំស្ក្រឹត(១) ដូច្នេះស្រះខ្មែរសម័យសព្វថ្ងៃខ្លះដែលមិនឃើញមាន ។



១) អក្សរនេះខ្ញុំផ្តិតចេញពីសៀវភៅ Inscription Sanscrite de Han Chey របស់លោក M. Auguste Bath

បែបសរសេរតាមខ្មែរសព្វថ្ងៃ

១- ជិតមិន្ទុវតំសេទ្រ　　មុទ្ធនិ គង្គាំ ពការយៈ

ឧមាក្រុកង្គិជិហេត្ថម្និ　　មាលា មាលុមិរាមលាមិ ។

២- រាជា ត្រីកវវម្ទេត្តិ　　បតិពសិទ្ធហីភូតាមិ

អប្បធម្យមហាសត្វៈ　　តុង្គោ មេរុរិវាបរៈ ។

៣- សោមាន្វយេប្រសូតស្ស　សោមស្សេវ បយោទិតៅ

កេនាបិ យស្ស តេជស្តុ ជាផ្វលិតិ សទាហាវេ ។

សេចក្ដីប្រែជា ខ្មែរនេះ របស់ព្រះមហាប៉ាង ខាត់

១- ជយោ! ព្រះឥស្សូរមានត្បូងប្រដាប់ដោយមកុដពោលគឺ ព្រះចន្ទ ហើយទ្រព្រះគង្គា ដែលមានគង្គាញ់ដំណាក់ស្រក់ចុះមកបំ ការក្រឡេក ភ្នែកនៃឧមា ប្រាកដដូចជាមាលាវល្លិ៍ទិមល

(ប្រយោគខាងលើនេះ គេសរសើរគុណព្រះឥស្សូរនឹងនាងឧមា តែប្រយោគខាងក្រោម គេប្រសិទ្ធិពរបំពោះព្រះបាទភវវរ្ម័ន)

២- ព្រះរាជា ស្រីកវវទ្ធ័ ជាម្ចាស់ទ្រទ្រង់នូវផែនដី ជាមហាសត្វឥត មាននរណាឈ្នះបាន ទ្រង់ប្រសើរប្រាកដដូចជាភ្នំព្រះសុមេរុមួយផ្សេង ទៀត ។

៣- ទ្រង់ប្រសូតក្នុងត្រកូលសោម ព្រះអង្គមានតេជ ក្លឹសន្ទោសនៅ ក្នុងសង្គ្រាមគ្រប់កាល ឥតមានអ្នកណាដល់ ប្រាកដដូចជាតេជ នៃព្រះ ចន្ទ្រដែលភ្លឺផ្ទេកក្នុងមហាសមុទ្រដ៏ជ្រាលជ្រៅ ។ (នៅមានត)

## ផ្នែកកំណត់និងប្រវត្តិការណ៍

# ពិធីបុណ្យបូជាព្រះសព ព្រះសុមង្គលសីលាចារ្យ

## ទិត-ទឹម

ភជាគណៈថ្នាក់ចត្វា អតីតចៅអធិការវត្តដំណាក់និងអតីតមេគណ ខេត្តសៀមរាប ។

ពិធីបុណ្យបូជាព្រះសពព្រះសុមង្គលសីលាចារ្យ ទិត-ទឹម អតីតមេគណ ខេត្តសៀមរាប ចាប់ផ្ដើមឡើងពីថ្ងៃព្រហស្បតិ៍ ៩ កើតខែផល្គុណ ឆ្នាំរោង ឆស័ក ព.ស. ២៥០៧ រហូតដល់ថ្ងៃសុក្រ ៤ រោចខែឆ្នាំដដែល (១១ មីនាដល់ ២១ មីនា ១៩៦៥) ។

ពិធីបុណ្យនេះបានប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃសម្ដេចព្រះប្រមុខរដ្ឋជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក ។ យើងសូមជូនកម្មវិធីយ៉ាងសង្ខេបដូចតទៅ :

### ថ្ងៃព្រហស្បតិ៍ ៩ កើត ខែផល្គុណ (១១-៣-៦៥)

ជាថ្ងៃចូលពិធីបុណ្យ នៅក្នុងបរិវេណនៃឈាបនដ្ឋានវត្តដំណាក់ ។

### ថ្ងៃសុក្រ ១០ កើត (១២-៣ ៦៥

ម៉ោង ១៩.០០ - គណៈកម្មការបុណ្យនិមន្តព្រះសង្ឃចំនួន ៥០ អង្គ ចំរើនព្រះបរិត្ត សំដែងធម្មទេសនារួចហើយនិមន្តព្រះ-



ឈាបនដ្ឋានសំរាប់បូជាព្រះសពព្រះសុមង្គលសីលាចារ្យ ទិត ទឹម អតីតមេគណ

ខេត្តសៀមរាប ។ ឈាបនដ្ឋាននេះទុកសំរាប់សាធារណជន ។

សពចុះទៅដំកល់លើបុស្បកដ៏វិចិត្រនៅមុខកុដិធំដោយ
មានពុទ្ធបរិស័ទនិងក្មេងពិណពាទ្យក្មេងខ្វង់យនប្រគំគមផងផង ។

## ថ្ងៃសៅរ៍ ១១ កើត (១៣-៣-៦៥)

ម៉ោង ៧-០០ - ប្រគេនបោគ្គុជំពោះព្រះសង្ឃ ។

ម៉ោង ១០-៣០ - វេរភត្តប្រគេនចំពោះព្រះសង្ឃ ។

ម៉ោង១៤-០០ - ជួបជុំពុទ្ធបរិស័ទគ្រប់ប្រភេទ ព្រមទាំងញាតិមិត្តសិស្សានុសិស្សជួបជុំនមស្ការគ្រ័យប្រណាមសង្វេប ហើយនិមន្តព្រះសង្ឃបង្សុកូល ។ លោកអ្នកតំណាងគណៈកម្មការបុណ្យថ្លែងសុន្ទរកថា ។

ម៉ោង១៥-០០ - ហែក្បួនព្រះសពចេញពីវត្ត ព័ទ្ធក្រុងសៀមរាប ហើយត្រឡប់មកដំកល់កុងឈាបនដ្ឋានវត្តដំណាក់វិញ ។

ម៉ោង១៩-០០ - ចំរើនព្រះបរិត្ត រួចនិមន្តព្រះសុមង្គលសីលាចារ្យកែ- អឿន មេគណវត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប សំដែងធម្មទេសនាតាមសមគួរដល់កាលវេលា ។

## ថ្ងៃអាទិត្យ ១២ កើត (១៤-៣-៦៥)

ពេលព្រឹក - ដូចថ្ងៃទី ១៣ មីនា ១៩៦៥ ។

ពេលល្ងាច - ម៉ោង ១៩-០០ ចំរើនព្រះបរិត្ត រួចសម្ដេចព្រះពោធិវង្ស ហួត តាត សំដែងព្រះធម្មទេសនា ។

ថ្ងៃច័ន្ទ ១៣ កើត ១៥-៣-៦៥)

ពេលព្រឹក - ដូចថ្ងៃទី ១៣ មីនា ១៩៦៥ ។

ពេលល្ងាច - ម៉ោង ១៩-០០ ចំរើនព្រះបរិត្ត រួចព្រះមុនីកោសល សួរ-ហាយ សំដែងធម្មទេសនា ។

ថ្ងៃអង្គារ ១៤ កើត (១៦-៣-៦៥)

ពេលព្រឹក - ដូចថ្ងៃទី ១៣ មីនា ១៩៦៥ ។

ពេលល្ងាច - ម៉ោង ១៩-០០ ចំរើនព្រះបរិត្ត រួចព្រះធម្មចរិយាត្រិទ្ធ កែវ អ៊ុំ សំដែងធម្មទេសនា ។

- ថ្ងៃពុធ ១៥ កើត (១៧-៣-៦៥)

ពេលព្រឹក - ដូចថ្ងៃទី ១៣ មីនា ១៩៦៥ ។

ពេលល្ងាច - ម៉ោង ១៩-០០ ចំរើនព្រះបរិត្ត រួចសម្តេចព្រះវនរ័តមេគណខេត្ត បាត់ដំបង សំដែងធម្មទេសនា ។

- ថ្ងៃព្រហស្បតិ ១ រោច (១៨-៣-៦៥)

ពេលព្រឹក - ដូចថ្ងៃទី ១៣ មីនា ១៩៦៥ ។

ពេលល្ងាច ម៉ោង ១៩-០០ ចំរើនព្រះបរិត្ត រួចសំដែងធម្មទេសនា

- ថ្ងៃសុក្រ ២ រោច (១៩-៣-៦៥)

ពេលព្រឹក - ដូចថ្ងៃទី ១៣ មីនា ១៩៦៥ ។

ពេលរសៀល - ម៉ោង ១៤-០០ សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ស្តេច
យាងដល់ចំណតអាកាសយានសៀមរាប តាមអា-
កាសចរក្រុមខ្មែរកម្ពុជា ។

ពេលល្ងាច - ម៉ោង ១៩-០០ ចំរើនព្រះបរិត្ត រួចសំដែងធម្មទេសនា

## - ថ្ងៃសៅរ៍ ៣ រោច (២០-៣-៦៥)

ពេលព្រឹក - វេរភត្តចំពោះព្រះសង្ឃ ។

ពេលរសៀល - ម៉ោង ១៥-០០ ជួបជុំពុទ្ធបរិស័ទ សិស្សានុសិស្ស
នៅឈាបនដ្ឋាន ។

ម៉ោង ១៧ - សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ទ្រង់យាងដល់ឈាបនដ្ឋាន

ម៉ោង១៧-៣០ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់ស្តេចយាងដល់ ។

- ពិធីថ្វាយព្រះភ្លើង
- អុជរន្ទាកាំជ្រួច

ម៉ោង ២០-០០ សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ទ្រង់ព្រះរាជទានព្រះធម្ម
- ទេសនា ។

## - ថ្ងៃអាទិត្យ ៤ រោច (២១-៣-៦៥)

ពេលព្រឹក - រាប់បាត្រធ្វើបុណ្យ ។

ពេលរសៀល ម៉ោង ១៤-០០ សំដែងធម្មទេសនាសង្គាយនាត្រៃ ៣
- ដោយព្រះគ្រូចៅអធិការវត្តស្វាយ វត្តរាជបូណ៌ វត្តពោធិ-
បន្ទាយជ័យ ជាកិច្ចបង្ហើយបុណ្យ ។

# ជីវប្រវត្តិ

## ព្រះសុមង្គលសីលាចារ្យ ទិត ទឹម មេគណវត្តដំណាក់

ខេត្តសៀមរាប

ព្រះសុមង្គលសីលាចារ្យព្រះនាម ទិត- ទឹម ជាអតីតមេគណខេត្តសៀមរាបអង្គនេះ លោកជាបុត្ររបស់ឧបាសក ទិតព្រិន និងឧបាសិកា ប៉ា សម្ភពនៅថ្ងៃអាទិត្យ ១១ កើតខែស្រាពណ៍ឆ្នាំជូត ព.ស. ២៤៣២ គ.ស. ១៨៨៨ នៅភូមិគោកគ្រោច ឃុំខ្នាត ស្រុកពួកខេត្តសៀមរាប អាយុបាន១៣ ឆ្នាំ បានចូលទៅសិក្សាចំណេះវិជ្ជាក្នុងសំណាក់លោកគ្រូព្រះនាមអ៊ិត ជាចៅអធិការវត្តដំណាក់សៀមរាប លុះអាយុបាន ១៣ ឆ្នាំបានបួសជាសាមណេរក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ព្រះនាម អ៊ិត ដដែល បួសបាន៣ វស្សា សាមណេរ ទឹម ក៏លាចាកសិក្ខាទៅជាឃរាវាសវិញ លុះអាយុ ២២ ឆ្នាំ ក៏បានចូលមកសុំឧបសម្បទាជាភិក្ខុភាវៈនៅថ្ងៃព្រហស្បតិ៍ ១១ កើត ខែពិសាខឆ្នាំចទោស័ក ព.ស. ២៤៥៣ គ.ស. ១៩១០ ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ព្រះនាម អ៊ិត ឯកម្មវាចាចារ្យព្រះនាម កុយ ១ ព្រះនាម ឈិត១ ។

លោកបានទទួលការសិក្សាព្រះត្រៃបិដកមុនដំបូងនៅសាលាព្រះរាជដំណាក់មុខនាគអង្គរវត្ត ខេត្តសៀមរាប ក្នុងសំណាក់ព្រះពុទ្ធវង្ស ព្រះនាម "ម៉ុ" ជាធម្មាចារ្យបង្រៀន ។ ភិក្ខុ ទិត- ទឹម សិក្សាបានតែ ៣ ឆ្នាំ ក៏ត្រូវរាជការលើកយកសាលាបាលីនេះទៅតាំងឯរាជធានីភ្នំពេញវិញ ភិក្ខុ



ព្រះសុមង្គលសីលាចារ្យ រាជាគណៈ មេគណ ទិត ទឹម ចៅអធិការ វត្តដំណាក់ សៀមរាប
ជាតិថ្ងៃអាទិត្យ ខែស្រាពណ៍ ឆ្នាំឆ្លូវ ព.ស. ២៤៣១ សុគតនៅថ្ងៃអាទិត្យ ១២ រោច បឋមាសាឍ
ឆ្នាំឆ្លូវត្រីស័ក ព.ស. ២៥០៤ ត្រូវនឹងថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ១៩៦១ វេលាម៉ោង ១៤ ។

ទិត ទឹម ក៏ត្រូវខកខានមិនបានសិក្សាតទៅទៀត ត្រឡប់មកនៅវត្តដំណាក់វិញ ជួយបំពេញកិច្ចការកសាងកុដិសាលាទីសេនាសនៈ ក្រោមអធិបតីភាពព្រះឧបជ្ឈាយ៍ដូចភិក្ខុឯទៀតៗ ដែរ ។

ភិក្ខុ ទិត ទឹម អង្គនេះ មានចិត្តគំនិតអធ្យាស្រ័យព្រមទាំងកិរិយាមារយាទសមរម្យគួរជាទីស្រឡាញ់រាប់អាននៃព្រះឧបជ្ឈាយ៍ ព្រមទាំងភិក្ខុសាមណេរក្នុងវត្តគ្រប់ៗ រូប ព្រមទាំងឧបាសកឧបាសិកាចំណុះជើងវត្តទាំងមូល ក៏មានការគោរពរាប់អានលោកគ្រប់ៗគ្នា ។

ព្រោះហេតុនេះហើយបានព្រះឧបជ្ឈាយ៍ព្រះនាម អ៊ិត ក៏បានតាំងភិក្ខុ ទឹម នេះឲ្យឡើងជាគ្រូសូត្រហូតដល់ប្រគល់មុខការកាន់កាប់ភិក្ខុ សាមណេរ ព្រមទាំងក្មេងនៅក្នុងវត្តនៅលើលោកគ្រូសូត្រនេះទាំងអស់ ។ លុះឧបជ្ឈាយ៍ព្រះនាម អ៊ិតនេះអនិច្ចធម្មទៅ លោកគ្រូសូត្រ ទឹម ក៏បានទទួលមុខងារជាចៅអធិការគ្រប់គ្រងវត្តដំណាក់នេះមក ។ល។ លោកបានទទួលតំណែងជាព្រះគ្រូបាឡាត់គណខេត្តសៀមរាប ក្នុងឆ្នាំ ១៩៦៦ បានទទួលតំណែងជាមេគណខេត្ត មានងារជាព្រះសុមង្គលសីលាចារ្យពជាគណមេគណក្នុងឆ្នាំ ១៩៧១ ។ ល ។

ព្រះតេជព្រះគុណមេគណ ទិត ទឹម បានធ្វើសេចក្តីចំរើនឲ្យកើតមានឡើងក្នុងខេត្តសៀមរាបនេះ ទាំងផ្លូវពុទ្ធចក្រនិងអាណាចក្រគួរឲ្យ

សរសើរ ៗ ដោយហេតុដែលលោកបានចំណាយកម្លាំងកាយ- វាចានិងកម្លាំងចិត្តរបស់លោកឲ្យបំរើប្រយោជន៍ជាតិនិង សាសនាដោយគ្មានសំចៃកម្លាំងនេះហើយ បានជាសរីរៈកាយរបស់លោក ក៏ត្រូវដល់នូវការទ្រុឌទ្រោមគ្រាំគ្រា និងពដព្យាធិក៏ចេះតែកើតមានជាលំដាប់នៅដើមឆ្នាំ ព.ស. ២៥០០ រោគមហារីក ក៏បានចាប់កំណើតកើតក្នុងបំពង់កលោក ដែលបណ្តាលឲ្យទៅជាដុំមួយមានទម្ងន់ធ្ងន់ គួរឲ្យតក់ស្លុតជាទីបំផុត ៗ ឧបាសក ឧបាសិកា សិស្សានុសិស្សទាំងគ្រហស្ថទាំងបព្វជិត ក៏មិនមានព្រងើយកន្តើយឡើយ បាននិមន្តលោកទៅព្យាបាលនៅភ្នំពេញ ក៏មិនបានផលគួរជាទីគាប់ចិត្តឡើយ ៗ

ទីបំផុតក្រុមពុទ្ធបរិស័ទនិងសិស្សគណទាំងអស់ ក៏បាននិមន្តលោកទៅព្យាបាលនៅទីក្រុងបរទេស គ្រូពេទ្យបានធ្វើការវះកាត់យករោគមហារីក ដែលកើតនៅក្នុងបំពង់កលោកនេះចេញបាន ទើបបានជាសះស្បើយរោគនេះ ប៉ុន្តែបែរជាវិបត្តិនូវសទ្ទសញ្ញា មានថេរៈដីកាមិនត្ក ៗ លោកនៅព្យាបាលក្នុងបរទេសនេះអស់វេលាចំនួន ៣ ខែ ១៨ ថ្ងៃ ទើបបានត្រឡប់មកគង់នៅវត្តដំណាក់ដូចដើមវិញ លោកនៅបានចំនួន ៤ ឆ្នាំ ក៏ស្រាប់តែអកុសលកម្ម ចូលមកផ្តាច់ផ្តិលៈ ជីវិតិន្ទ្រីយ៍របស់លោកឲ្យបានដល់នូវ អសញ្ញកម្មគឺអនិច្ចធម្មនៅនាវេលាម៉ោង ១៤ នាថ្ងៃអាទិត្យ

១២ កើត ខែបឋមាសាឍ ឆ្នាំឆ្លូវត្រីស័ក ព.ស. ២៥០៤ ត្រូវនឹងថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ១៩៦១ ក្នុងសភាពដ៏សែនស្ងប់ស្ងាត់ កណ្ដាលចំណោមនៃពពួកបរិស័ទ ដែលកំពុងតែអង្គុយគាល់ត្រៀបត្រា ទាំងលើសាលាទឹងលើកុដិ ផុតសេចក្ដីសង្ឃឹម ទឹកមុខឆ្ងាប់ញញឹម ក៏បានប្រែក្លាយទៅជាក្រៀមក្រំគ្រប់ៗគ្នាក្នុងគ្រានោះឯង ។

## ចប់ជីវប្រវត្តិ

X X

X

រូបំ ជីរតិ មច្ចានំ

នាមគោត្តំ ន ជីរតិ

រូបកាយសព្វសត្វ វិនាសបង់បាត់

កេរ្តិ៍ឈ្មោះគង់នៅ ។

# ការតាំងចៅអធិការ-គ្រូសូត្រក្នុងព្រះរាជអាណាចក្រកម្ពុជា

– ព្រះតេជព្រះគុណ មៀន យួន នាមឆាយាឥន្ទកេសរ កើតពី គ.ស. ១៨៩៤ អាយុ ៦៩ ឆ្នាំ វស្សា ៤៧ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តសិរីសាគរ ឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៦៤៩ ចុះថ្ងៃទី ២៣-១-៦៤ ។

– ព្រះតេជព្រះគុណ ប្រាក់ គន នាមឆាយាមិត្តថេរ កើតពី គ.ស. ១៩០០ អាយុ ៦២ វស្សា ៤០ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តសិរីសាគរ ឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៦៥០ ចុះថ្ងៃទី ២៣-១-៦៤ ។

– ព្រះតេជព្រះគុណ ឧ យូះ នាមឆាយាមន្តធម្ម កើតពី គ.ស. ១៩២១ អាយុ ៤១ ឆ្នាំ វស្សា ១៨ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តសិរីសាគរ ឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣ ៦៥១ ចុះថ្ងៃទី ២៣-១-៦៤ ។

– ព្រះតេជព្រះគុណ មាស យួន នាមឆាយាញាណគុត្តោ កើតពី គ.ស. ១៩៣៥ អាយុ ២៨ ឆ្នាំ វស្សា ៧ បានតែងតាំងជាចៅអធិការ នៅវត្តកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ លេខសញ្ញាប័ត្រ ៣ ៦៥២ ចុះថ្ងៃទី ២៣-១-៦៤ ។

– ព្រះតេជព្រះគុណ ជា នុ នាមឆាយាសុវណ្ណបញ្ញា កើតពី គ.ស. ១៨៩១ អាយុ ៧២ ឆ្នាំ វស្សា ៥១ បានទទួលតែងតាំងជាចៅអធិការ នៅវត្តកោតវៀន ឃុំព្រៃពួច ស្រុកភ្នំពេញ ខេត្តកណ្ដាល លេខសញ្ញាបត្រ ៣.៦៥៣ ចុះថ្ងៃទី ២៣-១-៦៤ ។

– ព្រះតេជព្រះគុណ ពោត សុខ នាមឆាយាកេសរមង្គល កើតពី គ.ស ១៨៩៣ អាយុ ៧០ ឆ្នាំ វស្សា ៥០ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំ នៅវត្តកោតវៀន ឃុំព្រៃពួច ស្រុកភ្នំពេញ ខេត្តកណ្ដាល លេខសញ្ញាបត្រ ៣ ៦៥៤ ចុះថ្ងៃទី ២៣-១-៦៤ ។

– ព្រះតេជព្រះគុណ ប៉ុល ក៉ង់ នាមឆាយាមង្គលត្ថេ កើតពី គ.ស. ១៩០៤ អាយុ ៥៩ ឆ្នាំ វស្សា ១៣ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តកោតវៀន ឃុំព្រៃពួច ស្រុកភ្នំពេញ ខេត្តកណ្ដាល លេខសញ្ញាបត្រ ៣.៦៥៥ ចុះថ្ងៃទី ២៣-១-៦៤ ។

– ព្រះតេជព្រះគុណ ប៊ុច សាម នាមឆាយាឥន្ទត្ថេរ កើតពី គ.ស. ១៩២៩ អាយុ ៣៤ ឆ្នាំ វស្សា ៨ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំ នៅវត្តសំបួរមាស ឃុំដង្កោ ស្រុកភ្នំពេញ ខេត្តកណ្ដាល លេខសញ្ញាបត្រ ៣.៦៥៦ ចុះថ្ងៃទី ២៣-១-៦៤ ។

– ព្រះតេជព្រះគុណ តាត ប្រាក់ នាមឆាយាព្រហ្មកេសរ កើតពី គ.ស. ១៩២៩ អាយុ ៣៥ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រ

ឆ្វេង នៅវត្តសំបួរមាស ឃុំដង្កោ ស្រុកភ្នំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៦៥៧ ចុះថ្ងៃទី ២៣-១-៦៤ ។

– ព្រះតេជព្រះគុណ ជុំ សេ នាមឆាយាព្រហ្មសរ កើតពី គ.ស ១៨៧៩ អាយុ ៨៤ វស្សា ៦៣ បានទទួលតែងតាំងជាចៅអធិការនៅវត្តជ្រោយបទុម ឃុំដង្កោ ស្រុកភ្នំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៦៥៨ ចុះថ្ងៃទី ២៣-១-៦៤ ។

– ព្រះតេជព្រះគុណ មាស សារី នាមឆាយាពុទ្ធបញ្ញា កើតពី គ.ស. ១៩១៥ អាយុ ៤៨ វស្សា ៣ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំ នៅវត្តជ្រោយបទុម ឃុំដង្កោ ស្រុកភ្នំពេញ ខេត្តកណ្ដាល លេខសញ្ញា-ប័ត្រ ៣.៦៥៩ ចុះថ្ងៃទី ២៣-១-៦៤ ។

– ព្រះតេជព្រះគុណ យិន ណុប នាមឆាយាឥន្ទត្ថេរ កើតពី គ.ស. ១៩០៥ អាយុ ៥៨ វស្សា ២ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តជ្រោយបទុម ឃុំដង្កោ ស្រុកភ្នំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៦៦០ ចុះថ្ងៃទី ២៣-១-៦៤ ។

– ព្រះតេជព្រះគុណ ពុត នួន នាមឆាយាវិសាលសរ កើតពី គ.ស. ១៩១៣ អាយុ ៥០ វស្សា ២៨ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំ នៅវត្តសិរីវន្នា ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៦៦១ ចុះថ្ងៃទី ២៣-១-៦៤ ។

-ព្រះតេជព្រះគុណ សុខ ធួន នាមធាយាចក្ខុសំវរោ អាយុ ៣៤ វស្សា ១០ បានទទួលតែងតាំងជាចៅអធិការ នៅវត្តត្បែង ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ លេខសញ្ញាប័ត្រ ៣.៦៦២ ចុះថ្ងៃទី ២៣-១-៦៤ ។

-ព្រះតេជព្រះគុណ យ៉ង់ ងឹម នាមធាយាឋានការោមោ អាយុ ៣០ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តត្បែង ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ លេខសញ្ញាប័ត្រ ៣.៦៦៣ ចុះថ្ងៃទី ២៣ ១-៦៤ ។

-ព្រះតេជព្រះគុណ រស់ ថាន់ នាមធាយាសក្កពោ អាយុ ២៥ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តត្បែង ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ លេខសញ្ញាប័ត្រ ៣.៦៦៤ ចុះថ្ងៃទី ២៣-១-៦៤ ។

-ព្រះតេជព្រះគុណ ព្រំ ស៊ុត នាមធាយាធម្មរក្ខោ អាយុ ៤៤ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាចៅអធិការ នៅវត្តកាន់ទ្រង់ ឃុំក្តុកកុង ស្រុកបន្ទាយមាស ខេត្តកំពត លេខសញ្ញាប័ត្រ ៣.៦៦៥ ចុះថ្ងៃទី ៣១-១-៦៤ ។

-ព្រះតេជព្រះគុណ យឹម សុខ នាមធាយាពុទ្ធថេរ អាយុ ៤២ ឆ្នាំ វស្សា ២២ បានទទួលតែងតាំងជាចៅអធិការ នៅវត្តអង្គជុំ ឃុំឈើង

ស្រុកពញាឮ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៦៦៦ ចុះថ្ងៃទី១-២-៦៤។

– ព្រះតេជព្រះគុណ កាំ កាទ នាមឆាយាធម្មត្ថេរ កើតពី គ.ស. ១៩២៨ អាយុ ៣៥ ឆ្នាំ វស្សា ១៥ បានទទួលតែងតាំងជាចៅអធិការ នៅវត្តអង្គតាឯក ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ លេខសញ្ញាប័ត្រ ៣.៦៦៧ ចុះថ្ងៃទី ១-២-៦៤ ។

– ព្រះតេជព្រះគុណ ទូ ម៉ុម នាមឆាយាឥន្ទសុវណ្ណ ឆ្នាំរោង អាយុ ៤៨ វស្សា ២៨ បានទទួលតែងតាំងជាចៅអធិការ នៅវត្តសរសៃ ឃុំអង្គាញ់ ស្រុកទ្រាំង ខេត្តតាកែវ លេខសញ្ញាប័ត្រ ៣.៦៦៩ ចុះថ្ងៃទី ១៤-១-៦៤។

– ព្រះតេជព្រះគុណ ម៉ក់ ឆេង នាមឆាយាពុទ្ធត្ថេរ ឆ្នាំមមី អាយុ ៣៤ ឆ្នាំ វស្សា ១៤ បានទទួលតែងតាំងជាចៅធិការ វត្តបន្ទោង ឃុំស្រង៉ែ ស្រុកសៀមរាប ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣.៦៦៩ ចុះថ្ងៃទី ១៤-១-៦៤ ។

– ព្រះតេជព្រះគុណ ទូច ផាក់ នាមឆាយាឧទ្ទត្ថេរ កើតពី គ.ស. ១៩០៦ អាយុ ៥៨ វស្សា ៣៧ បានទទួលតែងតាំងជាចៅអធិការ នៅវត្តទួលសាលា ឃុំអន្លង់រមៀត ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៦៧០ ចុះថ្ងៃទី ២៨-២-៦៤ ។

– ព្រះតេជព្រះគុណ យូរ ប៊ុន នាមឆាយាធម្មថេរ ឆ្នាំរកា អាយុ ៤៣ ឆ្នាំ វស្សា ២៣ បានទទួលតែងតាំងជាចៅអធិការ នៅវត្តស្បែង ឃុំវិហារ-

ល្អ ស្រុកពញាឮ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣.៦៧១ ចុះថ្ងៃទី ២៨-២-៦៤ ។

-ព្រះតេជព្រះគុណ កែវ ឌិន នាមឆាយាពុទ្ធជោត កើតពី គ.ស. ១៩០៧ អាយុ ៥៦ វស្សា ៣៦ បានទទួលតែងតាំងជាចៅអធិការ នៅវត្តពិសីឧត្តម ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣.៦៧២ ចុះថ្ងៃទី ២៨-២-៦៤ ។

-ព្រះតេជព្រះគុណ ជុំ លា នាមឆាយាឥន្ទសរ កើតពី គ.ស. ១៩០០ អាយុ ៦៣ វស្សា ៤២ បានទទួលតែងតាំងជាចៅអធិការ នៅវត្តគ័បារ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ លេខសញ្ញាប័ត្រ ៣.៦៧៣ ចុះថ្ងៃទី ២៨-២-៦៤ ។

-ព្រះតេជព្រះគុណ ចាន់ សារេត នាមឆាយាចិត្តសាពេ កើតឆ្នាំថោះ អាយុ ២៦ ឆ្នាំ វស្សា ៦ បានទទួលតែងតាំងជាចៅអធិការ នៅវត្តទទ្ធិញាកម ឃុំថ:លាបរិវ៉ត ស្រុកថ:លាបរិវ៉ត ខេត្តស្ទឹងត្រែង លេខសញ្ញាប័ត្រ ៣.៦៧៤ ចុះថ្ងៃទី ១៥-៤-៦៤ ។

-ព្រះតេជព្រះគុណ ខឹម រឹ នាមឆាយាធម្មជោតិ កើតពី គ.ស. ១៩២៨ អាយុ ៣៦ ឆ្នាំ វស្សា ១៥ បានទទួលតែងតាំងជាចៅអធិការ នៅវត្តសុវណ្ណបទុម ឃុំក៉ាន ស្រុកសៀមរាប ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣.៦៧៥ ចុះថ្ងៃទី ១៥-៤-៦៤ ។

– ព្រះតេជព្រះគុណ ជា ហាក់ នាមឆាយាធម្មទិសិត កើតពី គ.ស. ១៩៣៩ អាយុ ២៥ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្ត សុវណ្ណបទុម ឃុំវ៉ារិន ស្រុកទិង ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣.៦៧៦ ចុះថ្ងៃទី ១៥-៤-៦៤ ។

– ព្រះតេជព្រះគុណ គ្រុត ជិញ នាមឆាយាធម្មទិសិតោ កើតពី គ.ស. ១៩៤២ អាយុ ២២ ឆ្នាំ វស្សា ១ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តសុវណ្ណបទុម ឃុំវ៉ារិន ស្រុកទិង ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣.៦៧៧ ចុះថ្ងៃទី ១៥-៤-៦៤ ។

– ព្រះតេជព្រះគុណ កុង អេង នាមឆាយាវិរបណ្ឌិតោ កើតពី គ.ស ១៩២៩ អាយុ ៣៤ ឆ្នាំ វស្សា ១២ បានទទួលតែងតាំងជាចៅអធិការ នៅវត្តខ្នារ ឃុំខ្នារសេ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៦៧៨ ចុះថ្ងៃទី ១៥-៤-៦៤ ។

– ព្រះតេជព្រះគុណ ប្រាក់ ធឹម នាមឆាយាវីរប្បញ្ញោ កើតពី គ.ស. ១៩៣៦ អាយុ ២៧ ឆ្នាំ វស្សា ៧ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តខ្នារ ឃុំខ្នារសេ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៦៧៩ ចុះថ្ងៃទី ១៥-៤-៦៤ ។

– ព្រះតេជព្រះគុណ ទួន នឿន នាមឆាយាគន្ធសីលោ កើតឆ្នាំ ថោះ អាយុ ២៣ ឆ្នាំ វស្សា ៣ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅ-

វត្តខ្នារ ឃុំខ្នារសេ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣ ៦៨០ ចុះថ្ងៃទី ១៥-៤ ៦៤ ។

– ព្រះតេជព្រះគុណ អ៊ុច សាក់ឥហោ នាមធាយាស្ថិតត្ថេរ កើតឆ្នាំច អាយុ ៣០ វស្សា ១០ បានទទួលតែងតាំងជាចៅអធិការ នៅវត្តស្វាយមីង ឃុំអំពិលតាពក ស្រុកកោះសូទិន ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៦៨១ ចុះថ្ងៃទី ១៥-៤-៦៤ ។

– ព្រះតេជព្រះគុណ អ៊ុយ ប្រាក់ នាមធាយាចន្ទសារ កើតពី គ.ស. ១៩២១ អាយុ ៤៣ វស្សា ២៣ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តដំណាក់អំពិល ឃុំដំណាក់អំពិល ស្រុកក្ដុំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៦៨២ ចុះថ្ងៃទី ២៣-៤-៦៤ ។

– ព្រះតេជព្រះគុណ ញឹប ប៉ាន់ នាមធាយាពុទ្ធសរោ កើតពី គ.ស. ១៩២២ អាយុ ៤២ ឆ្នាំ វស្សា ២២ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តដំណាក់អំពិល ឃុំដំណាក់អំពិល ស្រុកក្ដុំពេញ ខេត្តកណ្ដាល លេខ ៣.៦៨៣ ចុះថ្ងៃទី ២៣-៤-៦៤ ។

– ព្រះតេជព្រះគុណ សៅ អឿ នាមធាយាសាសនបណ្ឌិត កើតពី គ.ស. ១៩១៩ អាយុ ៤៥ ឆ្នាំ វស្សា ២៤ បានតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តអរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៦៨៤ ចុះថ្ងៃទី ២៣-៤-៦៤ ។

- ព្រះតេជព្រះគុណ សៀ សុខ នាមឆាយាសុន្ទរប្បញ្ញោ កើតពី គ.ស. ១៩១៧ អាយុ ៤៦ ឆ្នាំ វស្សា ២២ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តដំណាក់អំពិល ឃុំដំណាក់អំពិល ស្រុកក្សុំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៦៨៥ ចុះថ្ងៃទី ២៣-៤-៦៤ ។

- ព្រះតេជព្រះគុណ ជុំ អ៊ូ នាមឆាយាវិមលប្បញ្ញា កើតពី គ.ស. ១៩១៩ អាយុ ៤៥ វស្សា ២៤ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំ នៅវត្តជុំ ឃុំគោករកា ស្រុកក្សុំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣ ៦៨៦ ចុះថ្ងៃទី ១៧-៤-៦៤ ។

- ព្រះតេជព្រះគុណ ប៉ៅ ស៊ិន នាមឆាយាធម្មធរោ កើតពី គ.ស. ១៩៣៥ អាយុ ២៩ វស្សា ៨ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តជុំ ឃុំគោករកា ស្រុកក្សុំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៦៨៧ ចុះថ្ងៃទី ១៧-៤-៦៤ ។

- ព្រះតេជព្រះគុណ មូល មៀន នាមឆាយាធម្មសិរីបញ្ញា អាយុ ៥៣ វស្សា ២៩ បានទទួលតែងតាំងជាចៅអធិការ នៅវត្តព្រែង ឃុំព្រែង ស្រុកបាត់ដំបង ខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣.៦៨៨ ចុះថ្ងៃទី ១០-៦-៦៤ ។

- ព្រះតេជព្រះគុណ លឹក វុន នាមឆាយាធម្មសរោ អាយុ ២៤ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំ នៅវត្តព្រែង ឃុំព្រែង

ស្រុកបាត់ដំបង ខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣.៦៨៩ ចុះថ្ងៃទី ១០-៦-៦៤ ។

—ព្រះតេជព្រះគុណ សោម សំផន នាមឆាយាកល្យាណធម្មោ អាយុ ៤៤ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តព្រៃង ឃុំព្រៃង ស្រុកបាត់ដំបង ខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣.៦៩០ ចុះថ្ងៃទី ១០-៦ ៦៤ ។

—ព្រះតេជព្រះគុណ កាក ហុក នាមឆាយាធម្មសុវណ្ណ កើតពីឆ្នាំរកា អាយុ ៤៣ វស្សា ២២ បានទទួលតែងតាំងជាចៅអធិការ នៅវត្តពិគិទ្ធាកម ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣ ៦៩១ ចុះថ្ងៃទី ១០-៦-៦៤ ។

—ព្រះតេជព្រះគុណ ពម យ៉េន នាមឆាយាកណ្ហវណ្ណោ កើតពី គ.ស. ១៩៤១ អាយុ ២៣ វស្សា ៣ បានទទួលតែងតាំងជាចៅអធិការ នៅវត្តព្រៃខ្វត ឃុំប្រេស ស្រុកស្វាយទាប ខេត្តស្វាយរៀង លេខសញ្ញា-ប័ត្រ ៣.៦៩២ ចុះថ្ងៃ ១០-៦-៦៤ ។

—ព្រះតេជព្រះគុណ មន់ ព្រឹម នាមឆាយាព្រហ្មវិរយោ កើតពី គ.ស. ១៩៣៤ អាយុ ៣០ វស្សា ១០ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តព្រៃខ្វត ឃុំប្រេស ស្រុកស្វាយទាប ខេត្តស្វាយរៀង-លេខសញ្ញាប័ត្រ ៣.៦៩៣ ចុះថ្ងៃទី ១០-៦-៦៤ ។

– ព្រះតេជព្រះគុណ ជុំ យ៉ាន់ នាមឆាយាគុត្តសីលោ កើតពី គ.ស. ១៩៤៣ អាយុ ២១ វស្សា ១ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តព្រៃខូត ឃុំព្រេស ស្រុកស្វាយទាប ខេត្តស្វាយរៀង លេខសញ្ញាប័ត្រ ៣.៦៩៤ ចុះថ្ងៃទី ១០-៦-៦៤ ។

– ព្រះតេជព្រះគុណ ប៊ូ ឃឹម នាមឆាយាបញ្ញាវិសារទោ កើតឆ្នាំច អាយុ ៣០ វស្សា ១១ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តជ័យមង្គល ឃុំជ្រៃឃ្មុំ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង លេខសញ្ញាប័ត្រ ៣.៦៩៥ ចុះថ្ងៃទី ១០-៦-៦៤ ។

– ព្រះតេជព្រះគុណ ម៉ី ប៊ិត នាមឆាយាមន្តថេរ កើតពី គ.ស. ១៩០៥ អាយុ ៥៩ វស្សា ៣០ បានទទួលតែងតាំងជាចៅអធិការ នៅវត្តកំត្រង់ ឃុំកំពង់តាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង លេខសញ្ញាប័ត្រ ៣.៦៩៦ ចុះថ្ងៃទី ១០-៦-៦៤ ។

– ព្រះតេជព្រះគុណ ពុក កេក នាមឆាយាកិតត្តេរ កើតពី គ ស. ១៨៩៤ អាយុ ៦៩ វស្សា ៤៧ បានទទួលតែងតាំងជា គសូត្រស្ដាំ នៅវត្តទេពធិតារាម ឃុំកំពង់ឆ្នាំង ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង លេខសញ្ញាប័ត្រ ៣.៦៩៧ ចុះថ្ងៃទី ១០-៦-៦៤ ។

– ព្រះតេជព្រះគុណ រ៉ា ហម នាមឆាយាគន្ធត្តេរ កើតពីគ ស. ១៨៩៦ អាយុ ៦៧ ឆ្នាំ វស្សា ៤៧ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង

នៅវត្តទេពធិតារាម ឃុំកំពង់ឆ្នាំង ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង លេខសញ្ញាប័ត្រ ៣ ៦៩៨ ចុះថ្ងៃទី ១០-៦-៦៤ ។

- ព្រះតេជព្រះគុណ ប្រាក់ មិន នាមធាយាសុវណ្ណជោតិ អាយុ ៥២ ឆ្នាំ វស្សា ២៧ បានទទួលតែងតាំងជាចៅអធិការ នៅវត្តមុនីរតនារាម ឃុំពាមកាំង ស្រុកលើកដែក ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣.៦៩៩ ចុះថ្ងៃទី ១១-៦-៦៤ ។

- ព្រះតេជព្រះគុណ ប្រាក់ សែម នាមធាយាបញ្ញាបទីបោ អាយុ ២៨ ឆ្នាំ វស្សា ៧ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តមុនីរតនារាម ឃុំពាមកាំង ស្រុកលើកដែក ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣ ៧០០ ចុះថ្ងៃទី ១១-៦-៦៤ ។

- ព្រះតេជព្រះគុណ គីម ធី នាមធាយាញាណធរោ អាយុ ២៤ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តមុនីរតនារាម ឃុំពាមកាំង ស្រុកលើកដែក ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣ ៧០១ ចុះថ្ងៃទី ១១-៦-៦៤ ។

- ព្រះតេជព្រះគុណ គុល កួង នាមធាយាឥន្ទសរវិនយ កើតពី គ.ស. ១៩០៣ អាយុ ៦១ វស្សា ៤០ បានទទួលតែងតាំងជាចៅអធិការ នៅវត្តរតនរង្សី ឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣ ៧០២ ចុះថ្ងៃទី ១៨-៦-៦៤ ។

- ព្រះតេជព្រះគុណ ករ ឆោម នាមឆាយាចន្ទត្ថេរ កើតពី គ.ស. ១៩៣៩ អាយុ ២៤ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តអង្គតាឯក ឃុំតាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ លេខសញ្ញាប័ត្រ ៣.៧០៣ ចុះថ្ងៃទី ២៣-៦-៦៤ ។

- ព្រះតេជព្រះគុណ អ៊ិក យួន នាមឆាយាសុវណ្ណត្ថេរ កើតពី គ.ស.១៩៣៩ អាយុ ២៤ វស្សា ៣ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តអង្គតាឯក ឃុំតាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ លេខសញ្ញាប័ត្រ ៣.៧០៤ ចុះថ្ងៃទី ២៣-៦-៦៤ ។

- ព្រះតេជព្រះគុណ ម៉ែន សុន នាមឆាយាសត្ថានុរក្ខិតោ កើតឆ្នាំច អាយុ ៣០ វស្សា ១០ បានទទួលតែងតាំងជាចៅអធិការ នៅវត្តព្រែក-ឬស្សី ឃុំព្រែកឬស្សី ស្រុកល្វាឯម ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៧០៥ ចុះថ្ងៃទី ៨-៧-៦៤ ។

- ព្រះតេជព្រះគុណ ខក វន់ នាមឆាយាសុវណ្ណត្ថេរ កើតឆ្នាំថោះ អាយុ ៤៩ បានតែងតាំងជាចៅអធិការ នៅវត្តចំប៉ាចារ ឃុំអង្គពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ លេខសញ្ញាប័ត្រ ៣.៧០៦ ចុះថ្ងៃទី ១១-៧-៦៤ ។

- ព្រះតេជព្រះគុណ គន់ យួន នាមឆាយាឥន្ទត្ថេរ កើតឆ្នាំកុរ អាយុ ៥៤ វស្សា ៣២ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តព្រៃទទឹង

ឃុំព្រៃទទឹង ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង លេខសញ្ញាប័ត្រ ៣.៧០៧ ចុះថ្ងៃទី ៩-៨-៦៤ ។

—ព្រះតេជព្រះគុណ ទឹប ចន នាមឆាយាចន្ទត្ថេរ កើតឆ្នាំខាល អាយុ ២៧ វស្សា ៦ បានតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តព្រៃទទឹង ឃុំព្រៃទទឹង ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង លេខសញ្ញាប័ត្រ ៣.៧០៨ ចុះថ្ងៃទី ៩-៨-៦៤ ។

—ព្រះតេជព្រះគុណ ធឹម សាន នាមឆាយាសន្ទត្ថិកាមោ កើតពី គ.ស. ១៩៣៩ អាយុ ២៥ វស្សា ៥ បានទទួលតែងតាំងជាចៅអធិការ នៅវត្តកូសាលា ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៧០៩ ចុះថ្ងៃទី ៩-៨-៦៤ ។

—ព្រះតេជព្រះគុណ ប៊ុន ប៊ុត នាមឆាយាធីរសុក កើតពីឆ្នាំមមែ អាយុ ៣៣ វស្សា ១៣ បានទទួលតែងតាំងជាចៅអធិការ នៅវត្តដីរស ឃុំព្រះអង្គីល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង លេខសញ្ញាប័ត្រ ៣.៧១០ ចុះថ្ងៃទី ៩-៨-៦៤ ។

—ព្រះតេជព្រះគុណ ប៊ុន នូ នាមឆាយាអត្តកនោ កើតឆ្នាំថោះ អាយុ ២៥ វស្សា ៥ បានទទួលតែងតាំងជាចៅអធិការ នៅវត្តកោះកែវមុនីសែ ឃុំកោះស្នែង ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង លេខសញ្ញាប័ត្រ ៣ ៧១១ ចុះថ្ងៃទី ៩-៨-៦៤ ។

— ព្រះតេជព្រះគុណ អ៊ុំ កិន នាមឆាយាធម្មវិសុទ្ធោ កើតពីឆ្នាំជូត អាយុ ៤១វស្សា ២១ បានទទួលតែងតាំងជាចៅអធិការ នៅវត្តក្រាំងក្រូច ឃុំដើមរុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ លេខសញ្ញាប័ត្រ ៣.៧១២ ចុះថ្ងៃទី ២៣-៨-៦៤ ។

— ព្រះតេជព្រះគុណ ដួង ហេង នាមឆាយាចន្ទត្ថេរ កើតពី គ.ស. ១៩០៨ អាយុ ៥៦ វស្សា ១៨ បានទទួលតែងតាំងជាចៅអធិការ នៅវត្តជោតិតារាម ឃុំក្អមសំណលើ ស្រុកលើកដែក ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៧១៣ ចុះថ្ងៃទី ២៣ ៨-៦៤ ។

— ព្រះតេជព្រះគុណ អ៊ុំ ហៃ នាមឆាយាសុវណ្ណកេសរ កើតពីគ.ស ១៩៣៩ អាយុ ២៥ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តជោតិតារាម ឃុំក្អមសំណលើ ស្រុកលើកដែក ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣ ៧១៤ ចុះថ្ងៃទី ២៣-៨-៦៤ ។

— ព្រះតេជព្រះគុណ ហេង ម៉ាង នាមឆាយាមហាន្ទត្ថេរ កើតឆ្នាំឆ្លូវ អាយុ ២៨ វស្សា ៧ បានទទួលតែងតាំងជាចៅអធិការ នៅវត្តដងទង់ ឃុំពាមល្វែក ស្រុកពញាឮ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៧១៥ ចុះថ្ងៃទី ១៥-៩-៦៤ ។

— ព្រះតេជព្រះគុណ យូ ប៊ូន នាមឆាយាឥន្ទបញ្ញា កើតពីឆ្នាំថោះ អាយុ ២៥ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តព្រែក

បាក់ន៍ ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣.៧១៦ ចុះថ្ងៃទី ១៥-៩-៦៤ ។

— ព្រះតេជព្រះគុណ ប្រាក់ សុក នាមឆាយាត់ទ្ធញាណ កើតពីឆ្នាំម្សាញ់ អាយុ ២៣ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តព្រែកបាក់ន៍ ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣.៧១៨ ចុះថ្ងៃទី ១៥-១១-៦៤ ។

— ព្រះតេជព្រះគុណ យិន សឹម នាមឆាយាសុវណ្ណសរ កើតឆ្នាំពេន អាយុ ៤៦ វស្សា ៤១ បានទទួលតែងតាំងជាចៅអធិការ ពោធិរុក្ខា ឃុំព្រៃទទឹង ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង លេខសញ្ញាប័ត្រ ៣.៧១៨ ចុះថ្ងៃទី ១៥-១១-៦៤ ។

— ព្រះតេជព្រះគុណ វ៉ ពិន នាមឆាយាបទុមត្ថេរ កើតពីគ.ស. ១៨៩១ អាយុ ៧១ វស្សា ៥០ បានទទួលតែងតាំងជាចៅអធិការ នៅវត្តអង្គរជ័យ ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៧១៩ ចុះថ្ងៃទី ២៧-១១-៦៤ ។

— ព្រះតេជព្រះគុណ អន ធិន នាមឆាយាឥន្ទត្ថេរ កើតពី គ.ស. ១៩០១ អាយុ ៦៣ វស្សា ៣៩ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តអង្គរជ័យ ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៧២០ ចុះថ្ងៃទី ២៧-១១-៦៤ ។

– ព្រះតេជព្រះគុណ ប្រាក់ ឌឹម នាមឆាយាមង្គលត្ថេរ កើតពី គ.ស. ១៩០១ អាយុ ៦៣ វស្សា ៣៧ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តអង្គរជ័យ ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៧២១ ចុះថ្ងៃ ២៦-១១-៦៤ ។

– ព្រះតេជព្រះគុណ ចាប ប៊ូ នាមឆាយាសុវណ្ណត្ថេរ កើតពីឆ្នាំរោង អាយុ ៦០ វស្សា ៣៥ បានទទួលតែងតាំងជាចៅអធិការ នៅវត្តបទុមកេសរ ឃុំតាមក្រស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៧២២ ចុះថ្ងៃ ២៧-១១-៦៤ ។

– ព្រះតេជព្រះគុណ ព្រំ កែវ នាមឆាយាសិរីបញ្ញា កើតឆ្នាំខាល អាយុ ៦២ វស្សា ២៨ បានទទួលតែងតាំងជាចៅអធិការនៅវត្តគិរីសោភ័ណារាម ឃុំក្រាំងស្គា ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង លេខសញ្ញាប័ត្រ ៣.៧២៣ ចុះថ្ងៃ ២៧-១១-៦៤ ។

– ព្រះតេជព្រះគុណ គង់ ណន នាមឆាយាសុខិតោ កើតឆ្នាំវក អាយុ ៣២ វស្សា ១១ បានតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តគិរីសោភណារាម ឃុំក្រាំងស្គា ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង លេខសញ្ញាប័ត្រ ៣.៧២៤ ចុះថ្ងៃទី ២៧-១១-៦៤ ។

– ព្រះតេជព្រះគុណ ជួប ឆាំ នាមឆាយាយានសង្វរ កើតឆ្នាំមមី អាយុ ២២ វស្សា ១ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តគិរីសោ-

គណាពម ឃុំក្រាំងស្គ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង លេខសញ្ញាប័ត្រ ៣.៧២៥ ចុះថ្ងៃ ២៧ ១១-៦៤ ។

–ព្រះតេជព្រះគុណ កើត ប៉ៅ នាមធាយាព្រហ្មត្ថេរ កើតពីគ.ស. ១៩២៥ អាយុ ៣៩ វស្សា ១៩ បានទទួលតែងតាំងចៅអធិការ នៅវត្តត្រពាំងជុំ ឃុំសែប ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង លេខសញ្ញាប័ត្រ ៣.៧២៦ ចុះថ្ងៃ ២៧-១១-៦៤ ។

– ព្រះតេជព្រះគុណ ដោក អៀម នាមធាយាព្រហ្មត្ថេរ កើតពី គ.ស. ១៩១៥ អាយុ ៤៩ វស្សា ២៨ បានទទួលតែងតាំងជាចៅអធិការ នៅវត្តបាសិទ្ធិក្រោម ឃុំឈ្មាំង ស្រុកពញាឮ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៧២៧ ចុះថ្ងៃ ២៧-១១-៦៤ ។

– ព្រះតេជព្រះគុណ សេន អ៊ិន នាមធាយាអគ្គធម្មោ កើតពី គ.ស ១៩៣១ អាយុ ៣៣ វស្សា ១២ បានទទួលតែងតាំងជាចៅអធិការ នៅវត្តមហាពជដ្ឋាន ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣ ៧២៨ ចុះថ្ងៃទី ២៧-១១-៦៤ ។

– ព្រះតេជព្រះគុណ យក់ វ៉ន នាមធាយាធម្មកេសរ កើតពី គ.ស. ១៩០៤ អាយុ ៥៩ វស្សា ៣៤ បានទទួលតែងតាំងជាចៅអធិការ នៅវត្តអម្ពវនាពម ឃុំស្វាយសាច់ភ្នំ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៧២៨ ចុះថ្ងៃទី ១៣-១២-៦៤ ។

—ព្រះតេជព្រះគុណ សួន ហោ នាមឆាយាឥន្ទជោតធម្មត្ថេរ កើតពី គ.ស. ១៩១០ អាយុ ៥៣ វស្សា ៣២ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តអម្ពវនារាម ឃុំស្វាយសាច់ភ្នំ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៨៣០ ចុះថ្ងៃទី ១៣-១២-៦៤ ។

—ព្រះតេជព្រះគុណ សាយ យុន នាមឆាយាសិរិធម្មត្ថេរ កើតពី គ.ស. ១៩១៧ អាយុ ៤៦ វស្សា ២៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង នៅវត្តអម្ពវនារាម ឃុំស្វាយសាច់ភ្នំ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៧៣១ ចុះថ្ងៃទី ១៣-១២-៦៤ ។

—ព្រះតេជព្រះគុណ កែវ យុត នាមឆាយាចន្ទកេសរ កើតពី គ.ស. ១៩០៩ អាយុ ៥៥ ឆ្នាំ វស្សា ៣៣ បានទទួលតែងតាំងជាចៅអធិការ នៅវត្តអារាមស្វាយ ឃុំស្វាយពោធិ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៧៣២ ចុះថ្ងៃទី ១៣-១២-៦៤ ។

—ព្រះតេជព្រះគុណ នង សុត នាមឆាយាថេតសេដ្ឋោ កើតពី គ.ស. ១៩៣៨ អាយុ ២៦ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ នៅវត្តអារាមស្វាយ ឃុំស្វាយពោធិ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៧៣៣ ចុះថ្ងៃទី ១៣-១២-៦៤ ។

(នៅមានត)